# ការអធិប្បាយ

# ដំណឹងល្អទាំងបី



លោកបណ្ឌិត យ៉ូន ស៊ុន ផាក

អ្នកបកប្រែ៖ វ៉ាយ យ៉ុង ជុន

Cambodia Reformed Faith Institute

# បុព្វកថា

លោកគ្រូខាងព្រលឹងវិញ្ញាណរបស់ខ្ញុំ លោកបណ្ឌិត យ៉ូន ស៊ុន ផាក (1905 -1988) ជាគម្រូនៃសាសនវិទ្យាខាងកំណែទម្រង់ និងជីវិតដែលថ្វាយបង្គំខាងពួកបរិសុទ្ធរបស់ខ្ញុំនៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំ ពីព្រោះព្រះបានដឹកនាំខ្ញុំទៅជួបគាត់នៅក្នុងពេលសិក្សានៅសាលាគម្ពីរនៅប្រទេសកូរ៉េ មហាវិទ្យាល័យព្រះគម្ពីរចុងស៊ីន (BA) និងសាលាសាសនវិទ្យាហាប់ដុង នៅប្រទេសកូរ៉េ (M.Div.) និង សាលាសាសនវិទ្យាវេសមីនស្ទើរកាលីហ្វ័រញ៉ា (D. Min 1906) បន្ទាប់ពីនោះមក ចិត្តរបស់ខ្ញុំប្រាថ្នាចង់យកតម្រាប់តាមគាត់នៅក្នុងការបម្រើព័ន្ធកិច្ចរបស់ព្រះ។ ឥលូវនេះ នៅក្នុងរយៈពេលធ្វើព័ន្ធកិច្ចនៅប្រទេសកម្ពុជា ខ្ញុំចង់យកគម្រូតាមគាត់នៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំ ពីព្រោះខ្ញុំស្រឡាញ់ចិត្តដែលស្មោះត្រង់របស់គាត់ទៅកាន់ព្រះគម្ពីរ។ ប៉ុន្តែ ខ្ញុំគិតថាខ្ញុំមិនអាចប្រៀបធៀបជាមួយនឹងគាត់បានទេ។

ដូច្នេះ យោងតាមលំហូរនៃដួងចិត្តរបស់ខ្ញុំ ជាដំបូង ខ្ញុំធ្វើការបកប្រែនូវសាសនវិទ្យាតាមបទគម្ពីរទៅភាសាអង់គ្លេស ហើយក៏បកប្រែការអធិប្បាយចំនួន 68 នៅក្នុងការពន្យល់បទគម្ពីរវិវរណៈរបស់គាត់ទៅជាភាសាអង់គ្លេស ដើម្បីត្រៀមនឹងបកទៅជាភាសាខ្មែរសម្រាប់ក្រុមជំនុំខ្មែរដោយក្រុមអ្នកបកប្រែផងដែរ។

ក្នុងអំឡុងពេលខ្ញុំបកប្រែការអធិប្បាយទាំងនេះ ខ្ញុំបានមើលឃើញនូវមនសិការមួយថា លោកគ្រូរបស់ខ្ញុំពិតជាស្រឡាញ់ព្រះបន្ទូលរបស់ព្រះ ជាព្រះគម្ពីរអស់ពីចិត្តមែន។ ដោយសារជំនាញរបស់ខ្ញុំគឺជាការអធិប្បាយដោយវែកញែកអត្ថន័យ ទើបខ្ញុំប្រាកដពីទស្សនៈរបស់គាត់នៅក្នុងការសិក្សាសេចក្តីពិត។ ហើយខ្ញុំមានអារម្មណ៍ថា ការអធិប្បាយរបស់គាត់ប្រៀបដូចជាកំណប់នៃសេចក្តីពិតមែន។

ខ្ញុំមានគម្រោងនឹងចែកចាយនូវការបង្រៀនរបស់គាត់នៅក្នុងក្រុមជំនុំកម្ពុជា។ ដូច្នេះខ្ញុំមានគម្រោងខ្លះសម្រាប់ ប្រជុំនូវការបង្រៀនរបស់ចុងអាំ ការបង្រៀនកាល់វីន និងប្រជុំនៃសៀវភៅដំណើរធម្មយាត្រារបស់ពួកបរិសុទ្ធ ជាដើម នៅក្នុងប្រទេសកម្ពុជា។

សូមឱ្យព្រះគុណរបស់ព្រះបាននៅជាមួយនឹងអ្នកអាននៅពេលបានចូលមកក្នុងពិភពដែលគោរពកោតខ្លាចដល់ព្រះរបស់ចុង អាំ តាមរយៈការអធិប្បាយរបស់គាត់។

នៅក្នុងព្រះគ្រីស្ទ

លោកបណ្ឌិត វ៉ាយ យ៉ុង ជុន ប្រធាននៃ CRFI

## លំដាប់លំដោយនៃដំណឹងល្អទាំងបី

ការអធិប្បាយ 1 ពង្សាវតាររបស់ព្រះយេស៊ូវ (ម៉ាថាយ 1:1-6)

ការអធិប្បាយ 2 ការមិនមានជំនឿរបស់សាការី (លូកា 1:5-25)
ការអធិប្បាយ 3 ព្រះដែលធ្វើឱ្យមនុស្សឆ្មើងឆ្មៃត្រូវអាម៉ាស់ (លូកា 1:46-55)
ការអធិប្បាយ 4 អំពីគ្រីស្ទាស់ (ម៉ាថាយ 1:1-25)
ការអធិប្បាយ 5 អំពីកំណើតព្រះយេស៊ូវដោយក្រមុំព្រហ្មចារី (ម៉ាថាយ 1:18-25)
ការអធិប្បាយ 6 សេចក្ដីសន្យារបស់ព្រះ (លូកា 1:72-73)
ការអធិប្បាយ 7 ស៊ីម៉ូន និងអាន់ណា (លូកា 2:21-39)
ការអធិប្បាយ 8 កំណើតរបស់ព្រះគ្រីស្ទ និងការឆ្លើយតបរបស់មនុស្ស (ម៉ាថាយ 2:1-12)
ការអធិប្បាយ 9 ការបីយ៉ាងដែលមកតាមក្រោយការបៀតបៀនរបស់ហេរ៉ូឌ (ម៉ាថាយ 2:1-23)
ការអធិប្បាយ 10 ព្រះយេស៊ូវដែលយាងឡើងទៅក្រុងយេរូសាឡិមនៅពេលទ្រង់ព្រះជន្ម ១២វស្សា (លូកា 2:41-51)
ការអធិប្បាយ 11 ធ្វើនៅក្នុងសេចក្ដីសុចរិត (លូកា 3:11-14)
ការអធិប្បាយ 12 អំពីការដែលព្រះយេស៊ូវទទួលការជ្រមុជទឹក (ម៉ាថាយ 3:13-17, ម៉ាថាយ 1:9-11, លូកា 3:21-22)
ការអធិប្បាយ 13 សិទ្ធិអំណាចនៃបទគម្ពីរ (ម៉ាថាយ 4:1-11)
ការអធិប្បាយ 14 ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះដែលគ្មានកំហុសសោះឡើយ ( ម៉ាថាយ 4:1-11)
ការអធិប្បាយ 15 ភស្តុតាងដែលសមហេតុផលដែលបទគម្ពីរជាព្រះបន្ទូលរបស់ព្រះ ( ម៉ាថាយ 4:1-11)
ការអធិប្បាយ 16 ការលន់តួបាប និងសេចក្ដីជំនឿ (ម៉ាកុស 1:14-15 ម៉ាថាយ 4:17)

ការអធិប្បាយ 17  សេចក្ដីជំនឿ (ម៉ាកុស 1:14-15, ម៉ាថាយ 4:17)

ការអធិប្បាយ 18  ព្រះយេស៊ូវត្រូវបានគេបដិសេធនៅស្រុកណាសារ៉ែត (លូកា 4:16-30)

ការអធិប្បាយ 19  អំពីការត្រាស់ហៅពួកសាវក (ម៉ាថាយ 4:18-22, ម៉ាកុស 1:16-20)

ការអធិប្បាយ 20 ការបង្រៀន និងអំណាចមួយចំនួន (ម៉ាថាយ 4:23-25 8:14-17 ម៉ាកុស 1:21-39 លូកា 4:31-44)

ការអធិប្បាយ 21  ចូរយើងរៀនពីការអធិស្ឋានរបស់ព្រះអម្ចាស់ (ម៉ាកុស 1:35-39)

ការអធិប្បាយ 22 អំពីការផ្ដល់សេចក្ដីមេត្តា (ម៉ាថាយ 5:7)

ការអធិប្បាយ 23 អំពីការបង្កើតសន្តិភាព (ម៉ាថាយ 5:9)

ការអធិប្បាយ 24  អំពីការពិតដែលបានបៀតបៀនដល់ព្រះយេស៊ូវ (ម៉ាថាយ 5:10-12) ការអធិប្បាយ 25  ចូរមានអំណរនៅក្នុងការបៀតបៀន (ម៉ាថាយ 5:10-12)

ការអធិប្បាយ 26  ការស្អប់ដែលបង្ហាញចេញមកដោយបណ្ដាសាអារក្ស (ម៉ាថាយ 5:21-26)

ការអធិប្បាយ 27  ភ្លើងនៃឋាននរក (ម៉ាថាយ 5:22)

ការអធិប្បាយ 28  អាសនានៃសេចក្ដីសុខសាន្ត (ម៉ាថាយ 5:23-26)

ការអធិប្បាយ 29  ការប្រែចិត្ត និងដង្វាយ (ម៉ាថាយ 5:23-26)

ការអធិប្បាយ 30  ការមិនអត់ធ្មត់ និងសាសនាគ្រឹស្ត (ម៉ាថាយ 5:38-42)

ការអធិប្បាយ 31  អំពីដង្វាយ (ម៉ាថាយ 6:19-21)

ការអធិប្បាយ 32 ការទាមទារបីយ៉ាង (ម៉ាថាយ 16:19-34)

ការអធិប្បាយ 33 ចូរកុះបារម្ភ (ម៉ាថាយ 5:9)
ការអធិប្បាយ 34 ទុក្ខព្រួយរបស់អ្នកជឿព្រះគ្រីស្ទ (ម៉ាថាយ 6:31-34)
ការអធិប្បាយ 35 ព្រះដែលឆ្លើយតបជាក់នូវការអធិស្ឋាន (ម៉ាថាយ 7:7-11)
ការអធិប្បាយ 36 សេចក្ដីជំនឿរបស់មនុស្សឃ្លង់ (ម៉ាថាយ 8:1-4, ម៉ាកុស 1:40-45, លូកា 5:12-16)
ការអធិប្បាយ 37 សេចក្ដីជំនឿដែលធ្វើឱ្យមនុស្សឃ្លង់បានជាសះស្បើយ (ម៉ាថាយ 9:1-8, ម៉ាកុស 2:1-12, លូកា 17-26)
ការអធិប្បាយ 38 សេចក្ដីមេត្តារបស់ព្រះ និងការប្រែចិត្តរបស់មនុស្ស (ម៉ាថាយ 9:13)
ការអធិប្បាយ 39 អំពីការតប (ម៉ាថាយ 9:14-17, ម៉ាកុស 2:18-22, លូកា 6:1-5)
ការអធិប្បាយ 40 អំពីការរក្សាថ្ងៃសប្ប័ថ (ម៉ាថាយ 12:1-8, ម៉ាកុស 2:23-28, លូកា 6:1-5)
ការអធិប្បាយ 41 ព្រឹត្តិការណ៍ដែលប្រោសបុរសម្នាក់ដែលស្វិតដៃ (ម៉ាថាយ 12:9-21) ការអធិប្បាយ 42 សេចក្ដីជំនឿរបស់មេទ័ព (ម៉ាថាយ 8:5-13 លូកា 7:2-10)
ការអធិប្បាយ 43 ការប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយនៅទីក្រុងណេន ( លូកា 7:11-17)
ការអធិប្បាយ 45 អំពីការរៀនពីព្រះគ្រីស្ទ (ម៉ាថាយ 11:25-30)
ការអធិប្បាយ 46 គំនិតអំពីអង្គដែលផ្សះផ្សា ជាព្រះគ្រីស្ទ និងជាមនុស្ស (1) (ម៉ាថាយ 11:25-30)
ការអធិប្បាយ 46 គំនិតអំពីអង្គដែលផ្សះផ្សា ជាព្រះគ្រីស្ទ និងជាមនុស្ស (2) (ម៉ាថាយ 11:25-30)

ការអធិប្បាយ 47 គំនិតអំពីអង្គដែលផ្សះផ្សា ជាព្រះគ្រីស្ទ និងជាមនុស្ស (3) (ម៉ាថាយ 11:25-30)

ការអធិប្បាយ 48 គំនិតអំពីអង្គដែលផ្សះផ្សា ជាព្រះគ្រីស្ទ និងជាមនុស្ស (4) (ម៉ាថាយ 11:25-30)

ការអធិប្បាយ 49 ចូរមកឯខ្ញុំ (ម៉ាថាយ 11:28-30)

ការអធិប្បាយ 50 ពួកបរិសុទ្ធដែលចាក់ប្រេងនៅលើព្រះបាតរបស់ព្រះយេស៊ូវ (លូកា 7:36-5)

ការអធិប្បាយ 51 អំពីការផ្សាយដំណឹងល្អផ្ទាល់របស់ព្រះយេស៊ូវ (លូកា 8:1-3)

ការអធិប្បាយ 52 គ្រោះថ្នាក់នៃការប្រមាថព្រះវិញ្ញាណបរិសុទ្ធ (ម៉ាថាយ 12:22-37, ម៉ាកុស 3:20-30, លូកា 11:14-26)

ការអធិប្បាយ 53 គោលការណ៍នៃការមិនព្រមជឿរបស់ពួកផារីស៊ី និងពួកអាចារ្យ (ម៉ាថាយ 12:38-45)

ការអធិប្បាយ 54 ការបង្រៀនតាមរយៈការប្រៀបធៀបនៃការសាបគ្រាប់ពូជ (ម៉ាថាយ 13:1-23)

ការអធិប្បាយ 55 អំពីគ្រាប់ពូជ និងបំណាស់ (ម៉ាថាយ 13:24-30, 36-43)

ការអធិប្បាយ 56 ប្រស្នានៃគ្រាប់ពូជល្អិត និងប្រស្នានៃមេដំបែរ (ម៉ាថាយ 13:31-33 ម៉ាកុស 4:30-32, លូកា13:18-21)

ការអធិប្បាយ 57 ប្រស្នានៃការទិញត្បូង និងកំណប់ (ម៉ាថាយ13:44-46)

ការអធិប្បាយ 58 ប្រស្នានៃការនេសាទត្រី (លូកា 13:47-50)

ការអធិប្បាយ 59 ការទួញសោករបស់ព្រះអម្ចាស់សម្រាប់សាវកដែលមានជំនឿតិច (ម៉ាថាយ 8:23-24)

ការអធិប្បាយ 60 ការប្រោសមនុស្សអារក្សចូលនៅតំបន់គេរ៉ាស៊ីន (ម៉ាថាយ 8:28-34, ម៉ាកុស 5:1-20, លូកា 8:26-39)

ការអធិប្បាយ 61 ការអស្ចារ្យពីរកើតឡើងដោយរបៀបតែមួយ (ម៉ាថាយ 9:18-26, ម៉ាកុស 5:21-43, លូកា 8:40-56)
ការអធិប្បាយ 62 ការប្រោសមនុស្សខ្វាក់ពីរនាក់ឱ្យជា (ម៉ាថាយ 9:27-34)
ការអធិប្បាយ 63 ទ្រង់ត្រូវបានបដិសេធម្តងទៀតនៅណាសារ៉ែត (ម៉ាថាយ 13:53-58, ម៉ាកុស 6:1-6)
ការអធិប្បាយ 64 អំពីទីសម្គាល់ (ម៉ាថាយ 10:1)
ការអធិប្បាយ 65 ពួកបរិសុទ្ធដែលជួបនូវការមិនយុត្តិធម៌ (ម៉ាថាយ 10:26-31)
ការអធិប្បាយ 66 ការមានទំនុកចិត្តនៅចំពោះព្រះដោយសារមានសេចក្តីកោតខ្លាចដល់ព្រះ (ម៉ាថាយ 10:28)
ការអធិប្បាយ 67 ចូរកុំខ្លាចគ្រប់ការទាំងអស់ដោយជឿលើព្រះ (ម៉ាថាយ 10:28-33)
ការអធិប្បាយ 68 ចូរកុះខ្លាច (ម៉ាថាយ10:28)
ការអធិប្បាយ 69 សេចក្តីស្លាប់នៃយ៉ូហានបាប់ទីស្ទ (ម៉ាថាយ 14:13-21 ម៉ាកុស 6:14-29, លូកា 9:7-9)
ការអធិប្បាយ 70 គោលការណ៍នៃកិច្ចការដែលបង្ហាញពីអំណាចដ៏អស្ចារ្យ (ម៉ាថាយ 14:13-21 ម៉ាកុស 6:30-44 លូកា 9:10-17)
ការអធិប្បាយ 71 អំពើបាបនៃអ្នកកាន់សាសនាដែលពុករលួយ (ម៉ាថាយ 15:1-10)
ការអធិប្បាយ 72 សេចក្តីជំនឿនៃស្ត្រីសាសន៍កាណានម្នាក់ (ម៉ាថាយ 15:21-28, ម៉ាកុស 7:24-30)
ការអធិប្បាយ 73 ការប្រោសមនុស្សថ្លង់ឱ្យជា (ម៉ាកុស 8:22-26)
ការអធិប្បាយ 74 ការប្រោសមនុស្សខ្វាក់នៅបេតសៃដា (ម៉ាកុស 8:22-26)
ការអធិប្បាយ 75 ទ្រឹស្តីនៃព្រះមេស៊ី (ម៉ាថាយ 16:13-21)
ការអធិប្បាយ 76 អ្នកដែលសម្លឹងទៅកាន់សិរីរុងរឿងរបស់ព្រះជាម្ចាស់ (ម៉ាថាយ 17:1-8)
ការអធិប្បាយ 77 អំពីការផ្លាស់ប្រែរបស់ព្រះយេស៊ូវ (លូកា 9:28-36)

ការអធិប្បាយ 78 អំពីការបណ្តេញអារក្សចេញពីបុរសដែលអារក្សចូល (ម៉ាថាយ 17:14-20)

ការអធិប្បាយ 79 សេចក្តីជំនឿ (ម៉ាថាយ 17:20)

ការអធិប្បាយ 80 ម្នាក់ដែលធ្វើកិច្ចការរបស់ព្រះជាម្ចាស់ដោយគ្មានការអធិស្ឋាន (ម៉ាកុស 9:14-29)

ការអធិប្បាយ 81 ទំនាយនៃការសុគត និងការរស់ឡើងវិញរបស់ទ្រង់ (ម៉ាថាយ 17:22-23, ម៉ាកុស 9:30-32 លូកា 9:44-45)

ការអធិប្បាយ 82 ការប្រកបដែលចេះបត់បែន ដែលអ្នកប្រកាសដំណឹងល្អគួរមានទៅកាន់មនុស្សនៅក្នុងលោកិយ (ម៉ាថាយ 18:1-4)

ការអធិប្បាយ 83 អំពីការបន្ទាបខ្លួន (ម៉ាកុស 18:1-4)

ការអធិប្បាយ 84 គោលការណ៍នៃការទទួលយក (ម៉ាកុស 9:38-41 លូកា 9:49-50)

ការអធិប្បាយ 85 សេចក្តីជំនឿដែលយើងគួរមាននៅក្នុងទុក្ខវេទនា (ទំនុកដំកើង 11:1-7)

ការអធិប្បាយ 85 ការធ្វើការសម្រេចចិត្តនៃជីវិតទាស់នឹងជីវិតអស់កល្បជានិច្ច និងស្ថាននរក (ម៉ាកុស 9:43-50)

ការអធិប្បាយ 86 អំពីការអត់ទោស (ម៉ាថាយ 18:21-35)

ការអធិប្បាយ 87 អំពីមនុស្សដែលបដិសេធព្រះយេស៊ូវដោយការមិនអើពើពីទ្រង់ (លូកា 9:51-56)

ការអធិប្បាយ 88 ការសម្រេចចិត្តនៃអ្នកជឿ (លូកា 9:57-62)

ការអធិប្បាយ 89 ប្រភេទនៃអំណរបីយ៉ាង (លូកា 10 17-24)

ការអធិប្បាយ 90 សាសន៍សាម៉ារីចិត្តល្អ (លូកា 10:30-37)

ការអធិប្បាយ 91 តំណែងល្អដែលសិស្សាព្រះបន្ទូលរបស់ព្រះ ដែលជាការបើកសម្តែងពិសេស (លូកា 10:38-42)

ការអធិប្បាយ 92 ចូរកុំធ្លាក់ចូលទៅក្នុងការល្បួង (លូកា 11:4)
ការអធិប្បាយ 93 ការអធិស្ឋានដ៏ស្វះស្វែង (លូកា 11:5-8)

ការអធិប្បាយ 94 ការឆ្លើយតបនឹងការអធិស្ឋាន (លូកា 11:5-13)

ការអធិប្បាយ 95 ការអធិស្ឋាននឹងត្រូវបានឆ្លើយតបពិត (លូកា 11:9-13)
ការអធិប្បាយ 96 អំពីចម្លើយនៃការអធិស្ឋាន (លូកា 11:33-36)

ការអធិប្បាយ 97 ដំណឹងល្អ និងភ្នែកខាងព្រលឹង (លូកា 11:33-36)

ការអធិប្បាយ 98 ចូរបង្ហាញនូវចក្ខុវិស័យខាងព្រលឹង (លូកា 11:33-36)

ការអធិប្បាយ 99 ចូរត្រួតពិនិត្យពន្លឺដែលងងឹតនៅក្នុងអ្នក (លូកា 11:33-36)

ការអធិប្បាយ 100 អំពើបាបរបស់ផារីស៊ី (លូកា 11:37-54)

ការអធិប្បាយ 101 ចំណុចដែលត្រូវយកចិត្តទុកដាក់នៅចំពោះហ្វូងមនុស្ស (លូកា 12:1-2) ការអធិប្បាយ 102 ចូរកុះក្លាយមនុស្ស (លូកា 12:4-5) ការអធិប្បាយ 103 មនុស្សល្ងីល្ងើ (លូកា 12:13-21)

ការអធិប្បាយ 104 ចូរបោះចិត្តដែលលោភលន់ចេញ (លូកា 12:15)

ការអធិប្បាយ 105 តើយើងនឹងត្រូវរស់នៅដូចម្តេច? (លូកា 12:13-34)

ការអធិប្បាយ 106 ចូរភ្ញាក់ឡើង! (លូកា 12:35-40)

ការអធិប្បាយ 107 គោលការណ៍សកម្មភាពនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ (លូកា 12:41-48)

ការអធិប្បាយ 108 ចូរធ្វើការជាអ្នកបម្រើរបស់ព្រះជាម្ចាស់ (លូកា 12:41-48)

ការអធិប្បាយ 109 អំពីការលន់តួបាប (លូកា 13:1-9)

ការអធិប្បាយ 110 អំពីការប្រោសមនុស្សអារក្សចូលនៅថ្ងៃសប្ប័ថ (លូកា 13:10-17)

ការអធិប្បាយ 111 បញ្ហាអំពីចំនួនអ្នកដែលត្រូវបានសង្គ្រោះ (លូកា 13:23-30)
ការអធិប្បាយ 112 បេសកកម្មដែលព្រះយេស៊ូវមាន (លូកា 13:31-35)

ការអធិប្បាយ 113 អំពើបាបដែលបះបោរ (លូកា13:34-35)

ការអធិប្បាយ 114 អំពីការបន្ទាបខ្លួន (លូកា 14:7-11)

ការអធិប្បាយ 115 ការបម្រើដែលនាំមកនូវរង្វាន់នៅពេលអនាគតជាមួយនឹងតម្លៃពិតប្រាកដ (លូកា 14:12-14)

ការអធិប្បាយ 116 អំពីការអញ្ជើញមនុស្សចូលទៅក្នុងស្ថានសួគ៌ (លូកា 14:12-14)

ការអធិប្បាយ 117 ការដើរតាមព្រះជាម្ចាស់ដោយការសម្រេចចិត្ត (លូកា 14:25-35)

ការអធិប្បាយ 118 អាថ៌កំបាំងដើម្បីក្លាយជាសិស្សរបស់ព្រះយេស៊ូវ (លូកា 14: 25-35)

ការអធិប្បាយ 119 ដួងចិត្តរបស់អ្នកគង្វាល (លូកា 15:3-7)

ការអធិប្បាយ 120 សេចក្តីលោភចង់បានសម្ភារៈគឺគ្រោះថ្នាក់ណាស់ (លូកា 16:13)

ការអធិប្បាយ 121 ទុក្ខលំបាករបស់ឡាសា (លូកា 16:19-31)
ការអធិប្បាយ 122 អំពីលោកិយដែលនឹងមកដល់ (លូកា 16:19-31)

ការអធិប្បាយ 123 សេចក្តីជំនឿពីរ (លូកា 17:11-19)

ការអធិប្បាយ 124 សេចក្តីជំនឿនៃមនុស្សឃ្លង់ទាំងដប់ (លូកា 17:11-19)

ការអធិប្បាយ 125 អំពីការអរគុណ (លូកា 17:11-19)

ការអធិប្បាយ 126 ចូរអធិស្ឋាន (លូកា 18:1-8)

ការអធិប្បាយ 127 ការអធិស្ឋានដោយគ្មានការបាក់ខកចិត្ត (លូកា 18:1-8)

ការអធិប្បាយ 128 ចំណុចខុសគ្នារវាងទស្សនៈរបស់ព្រះយេស៊ូវ និងទស្សនៈរបស់សិស្សទ្រង់អំពីកូនក្មេង (ម៉ាថាយ 19:13-15 ម៉ាកុស 10:13-16 លូកា 18:15-17)

ការអធិប្បាយ 129 មនុស្សទាំងអស់សុទ្ធតែជាមនុស្សមានបាប (ម៉ាថាយ 19:17)

ការអធិប្បាយ 130 អ្នកដែលបោះបង់គ្រួសារដោយសារនគរ (ម៉ាថាយ 19:29-30)
ការអធិប្បាយ 131 ការប្រៀបធៀបនៃកសិករដែលធ្វើការនៅចម្ការទំពាំងបាយជូរ (ម៉ាថាយ 20: 1-16)

ការអធិប្បាយ 132 អ្នកដែលត្រូវលើកឡើង (ម៉ាកុស 10: 35-45)

ការអធិប្បាយ 133 សេចក្តីជំនឿរបស់សាការី (លូកា 19:1-9)

ការអធិប្បាយ 134 ចូរឱ្យបានស្មោះត្រង់តាមតំណែងរបស់យើង (ម៉ាថាយ 25:14-30)

ការអធិប្បាយ 135 ការបម្រើដែលមានក្លិនក្រអូបដ៏មានពរ (ម៉ាកុស 14:3-9)

ការអធិប្បាយ 136 ស្ដេចដ៏មានជ័យដែលយាងចូលទីក្រុង (ម៉ាថាយ 21:1-11)

ការអធិប្បាយ 137 ការតាំងអំណាចឡើងដោយបបូរមាត់របស់កូនក្មេង និងទារក (ទំនុកដំកើង 8:1-2)

ការអធិប្បាយ 138 តួនាទីជាតិនៃអ្នកជឿ (ម៉ាថាយ 22:15-22)

ការអធិប្បាយ 139 សេចក្ដីស្រឡាញ់ (ម៉ាថាយ 22:34-40)

ការអធិប្បាយ 140 អំពីការដែលត្រូវគេសម្លាប់ (ម៉ាថាយ 23:29-36)
ការអធិប្បាយ 141 ការអត់ធ្មត់ (ម៉ាថាយ 24:13)

ការអធិប្បាយ 142 អ្នកដែលត្រូវបានព្រះអម្ចាស់សរសើរ (ម៉ាថាយ 25:14-30)

ការអធិប្បាយ 143 សេចក្ដីជំនឿនៃអ្នកទោសដែលត្រូវបានឆ្កាងនៅលើឈើឆ្កាងជាមួយនឹងព្រះយេស៊ូវ (លូកា 23:39-43)

ការអធិប្បាយ 144 ការប្រែចិត្តរបស់អ្នកទោស (លូកា 23:39-43)

ការអធិប្បាយ 145 សេចក្ដីជំនឿរបស់អ្នកទោស ដែលប្រែចិត្តនៅលើឈើឆ្កាង និងស្ថានសួគ៌ (លូកា 23:39-43)

ការអធិប្បាយ 146 ការរងទុក្ខយ៉ាងខ្លាំងរបស់ព្រះគ្រីស្ទ (លូកា )

ការអធិប្បាយ 147 ហេតុផលដែលមិនជឿលើការរស់ឡើងវិញរបស់ព្រះយេស៊ូវ (លូកា 24:1-12)

ការអធិប្បាយ 148 បទគម្ពីរ និងសេចក្ដីជំនឿ (លូកា 24:25-33)

ការអធិប្បាយនៃដំណឹងល្អទាំងបី

ការអធិប្បាយ 1 ពង្សាវតាររបស់ព្រះយេស៊ូវ (ម៉ាថាយ 1:1-6)

1. បុគ្គលនីមួយៗដែលលេចមកនៅចន្លោះអ័ប្រាហាំ និងដាវីឌ (1-6)

1) បុរសនៃសេចក្ដីជំនឿគឺជាអ័ប្រាហាំ។ នៅក្នុងចិត្តរបស់គាត់ គាត់ជឿថាការបង្គាប់របស់ព្រះវាពិបាកយល់។ រហូតដល់ចំណុចដែលព្រះបានបង្គាប់ដល់គាត់ឱ្យថ្វាយយញ្ញបូជាដោយចេញពីចិត្តនូវកូនប្រុសជាទីស្រឡាញ់ទៅកាន់ព្រះ នោះគាត់បានស្ដាប់បង្គាប់ (លោកុប្បត្តិ 22:1-19) ផលផ្លែនៃជំនឿជាការស្ដាប់បង្គាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះ។ វាពិបាក ដែលជំនឿពិតមិនទាមទារនូវការស្ដាប់បង្គាប់នោះ។

2) អ៊ីសាក់ជាមនុស្សម្នាក់ដែលទុកចិត្តឡើព្រះតែមួយអង្គគត់ ហើយមិនទុកចិត្តលើអ្វីទាំងអស់។ គាត់ស្វះស្វែងនឹងរក្សានូវជីវិតនៃទីរោងឧបោសថ ហើយគេចចេញពីការឈ្លោះប្រកែក។ យ៉ាកុបជាមនុស្សម្នាក់ដែលមានសេចក្ដីលោភលន់ខ្លាំង។ គាត់បានដកយកមរដកនៃបងប្រុសរបស់គាត់អេសាយដោយការបញ្ឆោត។ ការដែលគាត់ត្រូវដាក់ទោសដោយសារការបោកបញ្ឆោតដូចនោះត្រូវបានលេចមកនៅពេលក្រោយមកដែលកូនគាត់បានបោកបញ្ឆោតគាត់ជាច្រើន។

ឧទារហណ៍ ពួកគេបានលក់យ៉ូសែប និងបញ្ជូនគាត់ទៅប្រទេសអេស៊ីប ហើយក៏បែរមករកឪពុករបស់ពួកគេ ហើយរាយការណ៍ថាគាត់ត្រូវបានសត្វសាហាវហែកស៊ី (លោកុប្បត្តិ 37:25-36)។ អំពើបាបត្រូវតែទទួលការដាក់ទោស។ ប៉ុន្តែដោយសារបំណងប្រាថ្នារបស់គាត់ដែលចេញមកពីការទទួលព្រះ វាចេញមកពីគោលបំណងដែលល្អ។

យើងគួរតែមានទំនុកចិត្តក្នុងការដែលមានគោលបំណងល្អ ដែលនោះជាលោកិយដែលនឹងមកដល់ និងការខាងវិញ្ញាណ។

(លោកុប្បត្តិ ជំពូក 27)

3) យ៉ូដា ជាកូនប្រុសទីបួនរបស់យ៉ាកុប តែការសម្រេចនូវសេចក្តីសន្យារបស់ព្រះដែលនឹងបញ្ជូននូវព្រះមេស៊ី នឹងត្រូវសម្រេចដោយសារបុរសម្នាក់នេះ។ តើគាត់ជាអ្វី? យើងអាចដឹងវាបាន នៅពេលយើងមើលទៅការពិតដែលយ៉ាកុបនិយាយពីទំនាយទៅកាន់គាត់។ វាគឺជា "យូដាអើយ ពួកបងប្អូនឯងនឹងសរសើរឯង" (លោកុប្បត្តិ 49:8) "យូដាជាសិង្ហស្ទាវកូនអើយ ឯងបានឡើងមកពីស៊ីរំពា វាបានក្រាបចុះ បានដេកដូចជាសិង្ហយ៉ាងខ្លាំង នោះតើអ្នកណាហ៊ានដាស់វា។" (លោកុប្បត្តិ 49:9)។ ទំនាយនេះចង្អុលទៅថា ព្រះមេស៊ីជាស្តេចនឹងត្រូវបានប្រសូត្រចេញពីកូនចៅរបស់គាត់។ ភាពជាស្តេចរបស់គាត់បំពាក់ដោយហេតុការណ៍ដែលមិនព្រមសម្លាប់យ៉ូសែបដែលជាប្អូនប្រុសរបស់គាត់។ (លោកុប្បត្តិ 37:26)។ មិនតែប៉ុណ្ណោះ គាត់ជាមនុស្សម្នាក់ដែលមានតម្លៃដែលប្រែចិត្តពីកំហុសរបស់ខ្លួន។ ដែលជាការដែលគាត់បានយកនាងថាម៉ាដោយកំហុសរបស់គាត់ ក្រោយមកគាត់បានប្រែចិត្ត ហើយបាននិយាយថា "យូដាក៏ទទួលស្គាល់ រួចគាត់និយាយថា វាសុចរិតជាងអញ ដ្បិតអញមិនបានឱ្យដល់សេឡាជាកូនអញទេ នោះគាត់ក៏លែងស្គាល់នាងទៀត។" (លោកុប្បត្តិ 38:26)។

5) នាងរ៉ាហាបជាស្ត្រីសំផឹងសាសន៍ដទៃ តែនាងស្គាល់ពីជ័យជំនះរបស់ព្រះយេហូវ៉ា ហើយបានលាក់អ្នកស៊ើបអង្កេតឱ្យកងទ័ពរបស់អុ៊ីស្រាអែល ហើយពួកគេបានមានជីវិតរស់។ វាពិតជាគ្រោះថ្នាក់ណាស់ក្នុងការដែលលួចលាក់អ្នកស៊ើបអង្កេត។ ប៉ុន្តែសេចក្តីជំនឿត្រូវតែធ្វើការផ្សងព្រេងបែបនោះ (យ៉ូស្វេ ជំពូក 2) នាងរ៉ាហាបបានផ្សងព្រេងដូច្នោះ ពីព្រោះនាងប្រាកដថាព្រះទ្រង់នឹងមានជ័យជំនះ។ សេចក្តីជំនឿមិនមែន

មិនដឹងអ្វីសោះនោះទេ តែជាការស្គាល់ព្រះ ដែលជាព្រះដែលមានគ្រប់ព្រះចេស្ដាជាព្រះនៃឋានសួគ៌ និងផែនដី ហើយការដែលសម្លឹងមើលទៅកាន់នូវជ័យជំនះរបស់ទ្រង់ពិត។ “សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិតគេមើលងាយប្រាជ្ញា និងសេចក្ដីប្រៀនប្រដៅវិញ។ (សុភាសិត 1:7)

6) នាងរស់ជាស្ត្រីសាសន៍ម៉ូអាប់ ហើយនាងបានបម្រើម្ដាយក្មេករបស់នាងដោយស្មោះត្រង់។ បន្ទាប់ពីប្ដីរបស់នាងបានស្លាប់ចោល នាងមិនបានបំបោះបង់ម្ដាយក្មេករបស់នាងទេ ហើយថែមទាំងបានមកកាន់បេថ្លេហិមផង ហើយនាងប្រមូលស្រូវសាលីនិងបម្រើម្ដាយក្មេក។ នាងជាកូនស្រីដែលដឹងគុណម្នាក់ និងជាស្ត្រីដែលមានសីលធម៌។ ការពិតដែលនាងរៀបការជាមួយនឹងបូអូស ដែលជាសាច់ញាតរបស់ម្ដាយក្មេកនាងគឺ ហេតុការណ៍ធ្វើឱ្យនាងបានភ្ជាប់នឹងគ្រួសារម្ដាយក្មេករបស់នាងតាមទម្លាប់របស់សាសន៍យូដា។ ក្នុងកាលដែលយើងមើលទៅកន់ាទម្លាប់គ្រួសារនៃពិភពរបស់មនុស្សពីបុរាណ យើងមិនអាចមើលងាយវានៅក្នុងទស្សនៈនៃសីលធម៌បានឡើយ តែវាមានមនុស្សតែមួយគត់ជាចំណុចកណ្ដាលហើយមិនស្គាល់ព្រះ ហើយដែលការពិតដែលមិនមានព្រះជាចំណុចកណ្ដាលនោះពិតជាគួរឱ្យសោកស្ដាយណាស់។ ចូរយើងគិតពីការនេះដោយឧទាហរណ៍ខាងក្រោម។

(1) លូហ្គូ ជាបុរសម្នាក់របស់ ម៉ាន់ជេ កាលដែលឪពុករបស់គាត់ឈឺ នោះគាត់បានភ្លក្សលាមករបស់ឪពុក ហើយក៏ដឹងពីអាការៈនៃជំងឺ។ វាពិតជាល្អណាស់ដែលគាត់គោរពដល់ឪពុកដូច្នោះ តែយើងអាចរកឃើញពីចំណុចបែបអបិយជំនឿ និងឥតប្រយោជន៍របស់គាត់។ (2) កាង ហ្យុក ដែលជាបុរសម្នាក់នៅក្នុងកុលសម្ព័ន្ធហានបានអ៊ាវម្ដាយរបស់គាត់នៅក្រោយខ្នង បន្ទាប់ពីឪពុករបស់គាត់ស្លាប់ទៅ គាត់បានសង់តង់មួយនៅក្បែរផ្នូររបស់នាង ហើយបានទួញសោកដោយការស្លាប់របស់នាងបី

ឆ្នាំ។ នេះគឺជាការគោរពរូបព្រះក្លែងក្លាយ ហើយជាសកម្មភាពដែលធ្លាក់ចុះចូលទៅក្នុងពិភពមួយដែលយកឪពុកម្ដាយជាចំណុចកណ្ដាល។

(3) កូអុី ជាបុរសជាជាតិសាសន៍ឆូ គាត់បានរៀនសូត្រ និងពេលគាត់ត្រឡប់មកផ្ទះគាត់វិញ នោះឪពុកម្ដាយរបស់គាត់បានស្លាប់ គាត់បានព្យាយាមសម្លាប់ខ្លួនដោយសារគាត់មិនអាចទ្រាំទ្របាននូវការទួញសោក បន្ទាប់មកមនុស្សខាងខុងជឺមួយក្រុមបានជួបគាត់ ហើយបានដឹងពីហេតុផលរបស់គាត់ សិស្ស13 នាក់របស់ខុងជឺបានត្រឡប់ទៅកាន់ផ្ទះរបស់ពួកគេវិញមុនពេលម្ដាយរបស់ពួកគេចែកឋានដើម្បីនឹងបម្រើពួកគេ។ ហើយចុងក្រោយកូអុីក៏បានសម្លាប់ខ្លួន។ នេះក៏ជាចិត្តមួយដែលដឹងគុណដ៏ថ្លៃថ្នូរ តែវាមិនមែនជាការបម្រើបែបគោរពនៅក្នុងន័យដែលមានព្រះជាចំណុចកណ្ដាលនោះទេ តែជាការគោរពដែលខុសឆ្គង ដែលជ្រុលទៅក្នុងពិភពដែលយកមនុស្សជាចំណុចកណ្ដាល។

(4) ហ្គា ខាង គីម បន្ទាប់ពីម្ដាយរបស់គាត់ចែកឋានទៅ គាត់បានធ្វើរោងមួយនៅក្បែរផ្នូររបស់នាង ហើយបានយំកាន់ទុក្ខរបស់រយៈពេលបីឆ្នាំ ហើយបន្ទាប់មកគាត់ក៏ព្យាយាមយំកាន់ទុក្ខការស្លាប់របស់ឪពុកគាត់បីឆ្នាំទៀតនៅក្នុងរោងមួយផ្សេងទៀត ប៉ុន្តែកូននិងប្រពន្ធរបស់គាត់បានមកដុតរោងនោះចោល។ នេះក៏ជាទង្វើនៃសេចក្ដីមិនពិត គឺជាការមិនស្គាល់ព្រះ តែជាការអះអាងពីពិភពនៃការយកឪពុកម្ដាយជាចំណុចកណ្ដាល។

(5) វ៉ាង ហាង នៅក្នុងកុសម្ព័ន្ធហានបានជួបនឹងរឿងមួយ ដែលម្ដាយរបស់គាត់បានស្លាប់កាលគាត់នៅអាយុ 9 ឆ្នាំ ហើយគាត់បានផ្គត់ផ្គង់ឪពុករបស់គាត់ នៅរដូវក្ដៅគាត់បក់ឱ្យឪពុករបស់គាត់ ហើយនៅរដូវរងា គាត់ធ្វើឱ្យគ្រែដេកបានកក់ក្ដៅដោយខ្លួនរបស់គាត់។ ដូចដែលយើងឃើញ ការគោរពរបស់គាត់ពិតជាស្រស់ស្អាតណាស់។

ប៉ុន្តែនៅពេលយើងឃើញសកម្មភាពផ្សេងទៀតរបស់គាត់ គាត់ក៏បានចូលទៅក្នុងពិភពលោកដែលផ្តោតលើឪពុកម្តាយ ប៉ុន្តែមិនបានស្គាល់ព្រះឡើយ។ យើងគួរមានការកត្តញ្ញូដែលផ្តោតទៅលើព្រះ និងសេចក្តីពិត។ នេះគឺការកត្តញ្ញូដែលព្រះយេស៊ូមាន។ កាលដែលព្រះយេស៊ូវបានបម្រើឪពុកម្តាយរបស់ទ្រង់ នោះបានធ្វើដោយយកព្រះជាចំណុចកណ្តាល។ ពេលដែលព្រះយេស៊ូវបានយាងឡើងទៅក្រុងយេរូសាឡិមក្នុងពិធីបុណ្យរំលង ហើយឪពុកម្តាយរបស់ទ្រង់ ត្រូវបានត្រឡប់មកវិញនៅពេលដែលទ្រង់បានសម្រេច នោះទ្រង់បានស្នាក់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយបានធ្វើការដ៏មានតម្លៃថ្វាយព្រះវរបិតា។ វាមានន័យថាធ្វើឱ្យមានការថប់បារម្ភមួយចំនួនដល់ឪពុកម្តាយរបស់ទ្រង់។ (លូកា 2:48)

7) ដាវីឌជាក្មេងប្រុសម្នាក់ដែលមើលថែចៀមដូចមនុស្សទូទៅដែរ។ តែវាជាហេតុផលដែលគាត់អាចឡើងទៅកាន់បល្ល័ង្កនស្តេច។ ការពិតដែលគាត់បានសម្លាប់ កូលីយ៉ាត់ជាសាសន៍ភីលីស្ទីន គឺត្រូវបានសម្រេចដោយសារ គាត់បានហ្វឹកហាត់ទង្វើបែបនោះនៅពេលគាត់ធ្វើជាអ្នកគង្វាល។ កាលដែលស្តេចសូលសម្លឹងមើលទៅកាន់ដាវីឌ គឺមើលទៅដូចជាទង្វើដែលល្ងីល្ងើ ហើយមិនអនុញ្ញាតឱ្យគាត់ចេញទៅច្បាំងនោះទេ តែគាត់បានឆ្លើយតបថា “នោះដាវីឌដំណាលរឿងទូលសូលថា ពីដើមដែលទូលបង្គំ ជាបាវបំរើទ្រង់ ធ្លាប់ឃ្វាលចៀមរបស់ឪពុក នោះវេលាណាដែលមានសិង្ហ ឬខ្លាឃ្មុំ មកចាប់យកកូនចៀមពីហ្វូងទៅ។ ទូលបង្គំក៏ដេញតាមប្រហារវា ដោះចៀមនោះឱ្យរួចចេញពីមាត់វាមក បើកាលណាវាស្ទុះមកលើទូលបង្គំ នោះទូលបង្គំបានចាប់វាត្រង់ពុកចង្កាវាយសំឡាប់ទៅ។ ទូលបង្គំជាបាវបំរើទ្រង់ បានប្រហារទាំងសត្វសិង្ហ និងខ្លាឃ្មុំផង ដូច្នេះ សាសន៍ភីលីស្ទីនដែលឥតកាត់ស្បែកនេះ នឹងបានដូចជាសត្វ១នោះដែរ

ដ្បិតវាបានប្រកួតនឹងពលទ័ពនៃព្រះដ៏មានព្រះជន្មរស់ហើយ" (១សាំយ៉ូអែល 17:34-36)។ បន្ទាប់មក គាត់បានចូលទៅក្នុងសមរភូមិ ហើយគប់ដុំថ្មចូលទៅគាត់ ហើយពេលនោះថ្ងាសរបស់កូលីយ៉ាតក៏ត្រូវបាក់ ហើយស្លាប់ទៅ។ ចាប់តាំងពីពេលនោះមក ដាវីឌបានទទួលដំណឹងថាដាវីឌបានក្លាយជាទាហាន ហើយបន្ទាប់មកលោកបានក្លាយជាមេទ័ពអ៊ីស្រាអែល។ (១សាំយ៉ូអែល18:5) ដោយការក្រោកឡើងនោះជាចុងក្រោយគាត់បានក្លាយជាស្តេចរបស់អ៊ីស្រាអែល។

តើអ្វីជាអាថ៌កំបាំងនៃភាពជោគជ័យរបស់ដាវីឌ? [1] គាត់កោតខ្លាចព្រះតាំងពីក្មេង។ ពេលគាត់មើលថែចៀម គាត់ជឿថាការដែលគាត់សម្លាប់តោ និងខ្លាឃ្មុំនោះចេញមកពីអំណាចរបស់ព្រះ។ ដូចដែលយើងឃើញច្បាស់ណាស់ថានៅពេលដែលគាត់រត់ទៅកាន់តោនិងខ្លាឃ្មុំ នោះគាត់បានពឹងផ្អែកលើព្រះអម្ចាស់។ មនុស្សគួរប្រតិបត្តិ ទោះក្នុងកាលៈទេសៈណាក៏ដោយ គួរជឿលើព្រះ ហើយធ្វើវា។ ជីវិតដែលត្រូវពឹងលើព្រះយេហូវ៉ា ហើយដើរឆ្ពោះទៅ មិនមែនធ្វើបន្ទាប់ពីគាត់ពេញវ័យទេ ប៉ុន្តែត្រូវប្រតិបត្តិដោយការជឿលើព្រះយេហូវ៉ាសូម្បីតែនៅក្មេង។ ក្មេងនោះមានជំងឺយ៉ាងខ្លាំងដោយសារការពឹងលើខ្លួនឯង ប៉ុន្តែមិនពឹងលើព្រះយេហូវ៉ាទេ។ ពេលនេះគាត់បានទទួលការបង្ហាត់បង្រៀននៅវ័យក្មេង ក្រោយមកគាត់អាចធ្វើកិច្ចការដ៏អស្ចារ្យនៃសេចក្តីជំនឿ។ ដាវីឌបានរក្សាឥរិយាបថរបស់គាត់តាំងពីក្មេងបានយ៉ាងល្អ។ កាលដែលគាត់មើលថែរក្សាចៀម គាត់ព្យាយាមមិនឱ្យបាត់បង់សូម្បីតែកូនចៀមមួយ។ (១សាំយ៉ូអែល17:34, 35)។ សព្វថ្ងៃនេះ មនុស្សវ័យក្មេង និងកូនក្មេងគួរតែពឹងលើព្រះជាម្ចាស់តែមួយជាដំបូង ហើយគួររក្សានូវឥរិយាបថនោះ។ កាលដែលគាត់ត្រូវហ្វឹកហាត់ដូច្នោះ នោះគ្រាក្រោយមកគាត់នឹងអាចធ្វើការធំបាន។ [2] បើទោះជាគាត់បានប្រព្រឹត្តអំពើបាបនៅពេលក្រោយក៏ដោយ កាលដែលគាត់បានស្តាប់ទៅកាន់ការស្តីបន្ទោសរបស់ណាថាន

ហើយក្រោយមកបានប្រែចិត្ត (២សាំយ៉ូអែល 12:13) ដាវីឌជាមនុស្សនៃសេចក្តីជំនឿ ហើយជាមនុស្សនៃការប្រែចិត្តផង។

2. មនុស្សសម្រាប់ដាវីឌនៅពេលនៃការឃុំឃាំងរបស់បាប៊ីឡូន (7-11)

នៅទីនេះ មនុស្សដែលត្រូវបានបង្ហាញមកគឺជាស្តេចជាពិសេស ដែលត្រូវបានរាប់លើកលែងតែស្តេចដែលត្រូវបានមនុស្សសម្លាប់ និងស្តេចដែលត្រូវបានឃុំ។ ចំនួននោះគឺមានដប់បួននាក់។ ដ្បិតមានតែយ៉ូណាទេដែលត្រូវបានជាប់គុក (២របាក្សត្រ 36:9, 10) មានតែឈ្មោះរបស់គាត់ទេដែលត្រូវបានកត់ត្រា ត្រូវមិនត្រូវបានរាប់ថាជាស្តេចទេ។ (ម៉ាថាយ 1:17) នៅក្នុងចំណោមស្តេច គឺមានស្តេចល្អ និងស្តេចដែលអាក្រក់។ សូម្បីតែស្តេចដែលអាក្រក់ក៏ត្រូវបានតាំងឡើងជាបុព្វបុរសរបស់ព្រះមេស៊ីដែរ។

3. មនុស្សបន្ទាប់ពីពេលនៅក្នុងគុករហូតដល់ព្រះយេស៊ូវ (12-16) នៅក្នុងគ្រានេះ សិរីល្អនៃភាពជាស្តេចនៅក្នុងលំនាំមហាក្សត្រនៃភាពជាស្តេចរបស់ដាវីឌត្រូវបានកាត់ចេញ តែមានមនុស្សទូទៅផ្សេងទៀត។ នេះជាគ្រានៃ “គល់របស់ដាវីឌ” នៅក្នុង អេសាយ 11:1។ ព្រះយេស៊ូវជា “ត្រួយ” ដែលចេញមកពីគល់នេះ។ ទំនាយរបស់អេសាយ 11:1 បានសម្រេចដោយត្រង់”តែម្តង។

ការអធិប្បាយ 2 ការគ្មានជំនឿរបស់សាការី (លូកា 1:5-25)

នៅពេលពាក្យនេះបង្ហាញដល់យើង វាបង្ហាញពីការពិតថា សាការីបានក្លាយជាមនុស្សគ ដែលជាការដាក់ទោសនៃការគ្មានសេចក្តីជំនឿរបស់គាត់។ ហេតុអ្វីបានជាគាត់មានទំនួលខុសត្រូវធ្ងន់លើការមិនជឿរបស់គាត់រហូតដល់គាត់បានក្លាយជាមនុស្សគនោះ? យើងព្យាយាមគិតពីចំណុចទាំងនេះ។

1. ដ្បិតគាត់បែរទៅជាគ្មានជំនឿវិញ បើទោះជាគាត់បានទទួលព្រះគុណជាច្រើនក៏ដោយ នោះទំនួលខុសត្រូវរបស់គាត់ក៏ធំ។

អត្ថបទរបស់យើងនិយាយថា គាត់ជាសង្ឃម្នាក់ និងជាមនុស្សដែលសុចរិត។ (ខ 5, 6) បទគម្ពីរនិយាយថា "ឯអស់អ្នកណាដែលគេប្រគល់ទុកជាច្រើនឱ្យ នោះគេនឹងទារជាច្រើនពីអ្នកនោះវិញ គេនឹងសូមលើសទៅទៀត ពីអ្នកណាដែលគេបានផ្ញើទុកជាច្រើនផង។" (លូកា 12:48) ការពិតដែលការធ្វើជាសង្ឃ និងជាមនុស្សសុចរិត គឺជាលទ្ធផលដែលថាគាត់បានទទួលនូវព្រះគុណជាច្រើន។

2. ពីព្រោះអ្វីដែលព្រះទ្រង់បានសន្យាដែលអនុញ្ញាតឱ្យមានកូនប្រុសមួយ គឺត្រូវបានសម្រេចដោយការដែលគាត់ទន្ទឹងចង់បាន វាមិនចម្លែកទេ តែហេតុអ្វីបានជាគាត់មានការសង្ស័យ? ឥរិយាបថនេះចេញមកពីការមិនជឿជាងការបះបោរនៅចំពោះព្រះ។ វាពិតជាងាយដែលឱ្យមនុស្សមាននូវលក្ខណៈនៃការបះបោរខាងវិញ្ញាណ។ បើទោះជាគាត់ជាអ្នកជឿពិតប្រាកដក៏ដោយ កាលដែលគាត់ទទួលនូវអំណាចខាងវិញ្ញាណ ហើយមិនបានបំពាក់ដោយអាវុធដើម្បីនឹងធ្វើសង្គ្រាមជាមួយនឹងអារក្សជាបន្តទេ នោះគាត់នឹងអាចត្រូវបានវាយប្រហារដោយការមិនជឿដូច្នោះ។

3. សាការីបានស្តាប់ទៅកាន់ពាក្យរបស់ទេវតា រួចសួរទេវតាថា “តើខ្ញុំនឹងដឹងសេចក្តីនោះបាន ដោយសារអ្វី?” (ខ18)

វាជាការបង្ហាពីបំណងរបស់គាត់ ដ្បិតគាត់គិតថា បើទោះជាទេវតាជាអ្នកបើកសម្តែងក៏ដោយ គាត់គិតថាវាខ្លីពេក នោះគាត់ទាមទារនូវភស្តុតាងមួយចំនួន។ ពាក្យថា “តើខ្ញុំនឹងដឹងសេចក្តីនោះបាន ដោយសារអ្វី?” មានន័យថាជាសំណួរដែលគាត់ដឹងដោយការមើលឃើញទីសម្គាល់។ ការស្វែងរកទីសម្គាល់ដែលព្រះទ្រង់បើកសម្តែងជាការត្អូញត្អែរទៅកាន់ការដឹកនាំរបស់ព្រះ។ ការត្អូញត្អែរដូចនេះជាការមិនជឿ។ អ្នកជឿគួរតែដឹងថា ព្រះគុណដែលគេបានទទួលគឺគ្រប់គ្រាន់ និងគួរតែថ្វាយការអរគុណទៅកាន់ព្រះ នោះគាត់នឹងបានទទួលព្រះគុណថែមទៀតតាមវិធីដែលល្អប្រសើរ និងតាមលំដាប់លំដោយដែលសាកសម។ ប៉ុន្តែប្រសិនបើគាត់ត្អូញនឹងព្រះគុណដែលគាត់ទទួលបាន ហើយចង់បានទីសម្គាល់ ឬអ្វីមួយ នោះជាអាកប្បកិរិយាដែលមើលងាយដល់ព្រះគុណដែលផ្តល់មករួចហើយ។ អំពីការដែលសាការីមើលងាយដល់ព្រះគុណទេវតាបានចង្អុលមកថា ការបើកសម្តែងនោះពិតជាពិសេសខ្លាំងណាស់ ហើយបានមានបន្ទូលថា “ខ្ញុំនេះ ឈ្មោះកាព្រីយ៉ែល ដែលឈរនៅចំពោះព្រះ ទ្រង់បានចាត់ខ្ញុំឱ្យមកនិយាយនឹងលោក ហើយប្រកាសប្រាប់ដំណឹងល្អនេះ” (ខ 19)

4. ការដាក់ទោសដែលសាការីបានទទួល

គាត់បានក្លាយជាមនុស្សថ្លង់។ ដូចដែលយើងឃើញវា យើងដឹងដើម្បីលាតត្រដាងការពិតថា អំពើបាបនៃការមិនជឿគឺធំធេងណាស់។ ប៉ុន្តែ មនុស្សនោះយកអាកប្បកិរិយានៃការមិនជឿចំពោះព្រះហើយជាទូទៅ ហើយសូម្បីតែអ្នកជឿក៏មិនមានកំហុសដោយបានទទួលបទពិសោធន៍នៃការមិនជឿដែរ។ អ្នកនោះមិនអាចទទួលស្គាល់ថាការមិន

ជឿគឺជាអំពើបាបដ៏ធំនោះទេ។ ទោះបីជាវាជារឿងធម្មតា ដែលអ្នកនោះត្រូវទទួលទណ្ឌកម្មបែបនេះ នៅពេលណាដែលគាត់មានការមិនជឿនោះ ព្រះទ្រង់ស៊ូទ្រាំដោយសេចក្តីមេត្តាករុណារបស់ទ្រង់ជាយូរ ហើយរង់ចាំការប្រែចិត្តពីអ្នកនោះ។

**ការអធិប្បាយ 3 ព្រះដែលធ្វើឱ្យមនុស្សឆ្មើងឆ្មៃត្រូវអាម៉ាស់ (លូកា 1:46-55)**

នៅត្រង់ចំណុចនេះ យើងចង់មើលបទគម្ពីរជាចំបង។ “ដ្បិតទ្រង់នឹងជួយសង្គ្រោះមនុស្សដែលរងវេទនា តែឯមនុស្សឆ្មើងឆ្មៃ នោះទ្រង់នឹងបន្ទាបគេចុះវិញ” (ទំនុកដំកើង 18:27) “ដ្បិតទោះបើព្រះយេហូវ៉ាទ្រង់ខ្ពស់គង់តែទ្រង់យល់ដល់ពួកអ្នករាបសាដែរ តែឯមនុស្សឆ្មើងឆ្មៃ ទ្រង់ស្គាល់គេពីចំងាយហើយ” (ទំនុកដំកើង 138:6) “ព្រះយេហូវ៉ានឹងបំផ្លាញផ្ទះរបស់មនុស្សឆ្មើងឆ្មៃ តែទ្រង់នឹងតាំងគោលចារឹកនៃស្រីមេម៉ាយឱ្យមាំមួនវិញ។” (សុភាសិត 15:25) “អ្នកណាដែលចូលចិត្តនឹងការឈ្លោះប្រកែក នោះឈ្មោះថាជាអ្នកស្រឡាញ់អំពើបាបហើយ ចំណែកអ្នកណាដែលលើកខ្លួនឱ្យខ្ពស់ នោះជាអ្នកស្វែងរកតែសេចក្តីហិនវិនាស។” (សុភាសិត 17:19)

នៅសម័យបុរាណ ស្តេចមួយអង្គនៅស្រុកស៊ីរី ស្តេច អាន់ទីយ៉ូកុស អេពីផានី ជាមនុស្សក្រអឺតក្រទម ហើយធ្វើទុក្ខបុកម្នេញដល់ជនជាតិយូដាជាច្រើននាក់ ហើយទ្រង់បានដាក់រូបព្រះ ជូភីទ័រ អូលីមផឹស នៅព្រះវិហារនៃក្រុងយេរូសាឡឹម ហើយត្រឡប់មកវិញ។ ក្រោយមក គាត់បានស្តាប់ពាក្យចចាមអារ៉ាមដែលថាជនជាតិយូដាបោះរូបព្រះនោះចេញ ហើយខឹងយ៉ាងខ្លាំង ហើយនិយាយថា៖ “យើងនឹងធ្វើក្រុងយេរូសាឡិមជាទីបញ្ចុះសព។ពេលគាត់និយាយចប់ភ្លាម នោះគាត់កើតដុំសាច់រុំារ៉ៃក្នុងពោះ ហើយរាលដាលពេញខ្លួន ហើយសាច់របស់គាត់ក៏ធ្លាក់ចុះ និងរលួយ ហើយមនុស្សមិនអាចចូលទៅជិតគាត់បាន ដោយសារក្លិនមិនល្អ។ ដូច្នេះ គាត់សោកស្តាយដោយការបៀតបៀនសាសន៍យូដាជាខ្លាំង ហើយបន្ទាប់មកគាត់បានស្លាប់នៅលើភ្នំផាកាតាដែលនៅជិតក្រុងបាប៊ីឡូន។

ការនេះជាការសម្រេចបំពេញនូវពាក្យរបស់ ដានីយ៉ែល 8:25 ែដលបានទាយទៅកាន់មនុស្សដែលឆ្មើងឆ្មៃ ដែលនិយាយថា “ហើយដោយគំនិតវាងវៃរបស់វា នោះវានឹងធ្វើឱ្យកលឧបាយបានប្រយោជន៍នៅដៃខ្លួន រួចនឹងមានចិត្តលើកដំកើងខ្លួន ព្រមទាំងបំផ្លាញមនុស្សយ៉ាងច្រើន ដែលនៅដោយសុខស្រួល សូម្បីតែព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ គង់តែនឹងហ៊ានឈរទទឹងទាស់ដែរ តែវានឹងត្រូវបាក់បែកទៅ ឥតមានដៃអ្នកណាធ្វើឡើយ”។

ស្តេចហេរ៉ូឌ អាធីផាស ត្រូវបានមនុស្សនៅក្រុងទីរ៉ុស និងក្រុងស៊ីដូនសរសើរ ហើយគាត់មិនបានថ្វាយសិរីល្អដល់ព្រះទេ នោះទេវតារបស់ព្រះបានវាយគាត់ ហើយដង្កូវបានស៊ីគាត់ ហើយគាត់ក៏ស្លាប់ទៅ។ (កិច្ចការ 12:22-23)

ស្តេចអូសៀសបានទៅកាន់ព្រះវិហារ ហើយបានធ្វើនូវកិច្ចការដែលមានតែសង្ឃទេដែលអាចធ្វើបាន ដែលនោះជាកិច្ចការនៃការថ្វាយកំញាន។ វាជាទង្វើដែលប្រមាថ។ ដោយសារអំពើបាបនេះ កាលដែលសង្ឃអ័សារាបានផ្តល់នូវការទូន្មានដល់ទ្រង់ នោះទ្រង់បានខ្ញាល់ រួចមកទ្រង់ក៏ក្លាយជាមនុស្សឃ្លង់ (២របាក្សត្រ 26:16-23)។ ហេប៊ូក្នេសា ដែលជាស្តេចដ៏ធំដែលត្រូវបានលើកឡើងបាន៧ឆ្នាំ (ដានីយ៉ែល 4:33) បែលសាហ្សា បានឆ្មើងឆ្មៃ ហើយគាត់បានផឹកស្រាទំពាំងបាយជូរជាមួយនឹងសម្ភារៈនៃព្រះវិហារ ហើយក្រោយមកក៏មានលេចមកនៅលើជញ្ជាំងសរសេរថា “មេណេ មេនេ ថេខែល និងផាស៊ីន” (រាប់ ជួសជុល វាស់វែង និងប្រគល់ឱ្យ) ហើយត្រូវបានកាត់ទោសដោយការនោះ នៅយប់នោះ បែសសាហ្សាបានស្លាប់ទៅ។ (ដានីយ៉ែល 5:1-31)

ការអធិប្បាយ  4 អំពីគ្រីស្ទាស (ម៉ាថាយ 1:1-25)

ម៉ាថាយនិយាយ នៅក្នុងការចាប់ផ្តើមនៃការសរសេរពីពង្សាវតាររបស់ព្រះយេស៊ូវថា បញ្ជីរពង្សាវតារនៃអ័ប្រាហាំ និងដាវីឌ”។ វាមានន័យពីរច្បាស់ណាស់។ ព្រះទ្រង់បានសន្យានឹងអ័ប្រាហាំថា “គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង ពីព្រោះឯងបានស្តាប់តាមពាក្យអញ”(លោកុប្បត្តិ 22:18)។ ព្រះបន្ទូលនេះជាទំនាយដែលចង្អុលទៅកាន់ព្រះយេស៊ូវ។ ទំនាយបន្ទាប់ដែលនឹងមកគឺ “ជាវង្សាហ្លួងដាវីឌ” គឺ ២សាំយ៉ូអែល 7:8-16។ លោក បាវីង បានអះអាងថា ទំនាយនេះជាលក្ខណៈវិនិច្ឆ័យនៃទំនាយទាំងអស់ពីព្រះមេស៊ី។ (Deze belofte Gods aan David is dan de grondslang, het  middelpunt van alle volgende verwachting en profetie – Gereformeerde Dogmatiek vol. III. P 353) ហោរាបាននិយាយទំនាយថាទ្រង់នឹងប្រសូត្រមកជាវង្សាហ្លួងដាវីឌជាច្រើនដង។ (យោងតាម អេម៉ុស 9:11, ហូសេ 1:11, 3:5, មីកា 5:2 Ish 9:6,7, 11:1, 2, 10, យេរេមា 23:5, 30:9, 33:17, 20-22, 26, អេសេគាល 34:23, 24 37:22-28)

យើងអាចដឹងច្បាស់ថា កាលដែលម៉ាថាយសរសេរពីពង្សាវតាររបស់ព្រះយេស៊ូវ កំណើតរបស់ព្រះយេស៊ូវជាការសម្រេចបំពេញនៃទំនាយទាំងនេះ។ ព្រះយេស៊ូវជាស្ដេចដែលយាងមកដើម្បីនឹងប្រទានពរដល់មនុស្សទាំងអស់ដែលនៅក្រោមមេឃ។ វាជាអបអរពិតនៃគ្រីស្ទាស់ ដែលយើងសន្យាថានឹងស្ដាប់បង្គាប់ទ្រង់ទាំងស្រុង និងអនុវត្តដោយស្មោះត្រង់។ អ្នកដែលស្ដាប់បង្គាប់ស្ដេចពិតនឹងត្រូវបានទទួលព្រះពរ។ ហើយវាជាការធម្មតាដែលស្ដេចទាមទារនូវការស្ដាប់បង្គាប់ទាំងស្រុងពីរាស្ត្ររបស់ទ្រង់។ ប្រសិនបើមនុស្សស្ដាប់បង្គាប់ព្រះយេស៊ូវនៅគ្រាដើម ដែលជាប្រវត្តិសាស្ត្រនៃលោកិយនេះ ដែលត្រូវបានបង្កើតឡើងនូវមហន្តរាយបណ្ដោះអាសន្ន។ ពីព្រោះមនុស្សចាកចេញពីព្រះយេស៊ូវ តែដោយសារហូរចូលទៅកាន់ទិសដៅមួយទៀតដោយចាកចេញពីព្រះយេស៊ូវ គឺពួកគេតែងតែធ្លាក់ចុះទៅក្នុងសេចក្ដីវេទនាមួយចូលមួយ។ យើងគួរតែទទួលស្គាល់នូវការពិតដែល ព្រះយេស៊ូវជាស្ដេចលើស្ដេច ជាស្ដេចលើគ្រប់ជំនាន់ដោយផ្ទាល់ៗ។

2. ព្រះយេស៊ូវបានប្រសូត្រដោយស្រីក្រមុំព្រហ្មចារី (18-20)

កំណើតរបស់ព្រះយេស៊ូវតាមរយៈស្រីក្រមុំព្រហ្មចារីជាចម្បងត្រូវបានបង្ហាញមកដោយឯកសារដំណឹងល្អរបស់យើងច្បាស់ណាស់។ កាលដែលយើងអាន ម៉ាថាយ 1:16 យើងអាចមើលឃើញផ្នែកដែលទាញចំណាប់អារម្មណ៍របស់យើង។ នោះគឺជាពាក្យ "ហើយយ៉ាកុបជាឪពុករបស់យ៉ូសែប ជាប្ដីរបស់ម៉ារា ដែលព្រះយេស៊ូវបានប្រសូតមកដែលហៅថាព្រះគ្រីស្ទ»។ ដែលបញ្ជាក់ពីកំណើតនៃព្រហ្មចារី ហើយពាក្យខាងលើបាននិយាយថា "ហើយយ៉ាកុបជាឪពុករបស់យ៉ូសែប ជាប្ដីរបស់ម៉ារា" ប៉ុន្តែគ្មានពាក្យថាយ៉ូសែបបង្កើតព្រះយេស៊ូវទេ។ វាមានន័យថា យ៉ូសែបគឺគ្រាន់តែជាអ្នកស្លាប់ស្រប

ច្បាប់ប៉ុណ្ណោះ ប៉ុន្តែមិនមែនជាកូនរបស់អ្នកដែលមានជីវិតនោះទេ។ មិនត្រឹមតែប៉ុណ្ណោះ កាលយ៉ូសែបដឹងការពិតដែលថា ម៉ារាមានផ្ទៃពោះ គាត់បានពិបាកចិត្ត (ម៉ាថាយ 1:20) ហើយកាត់នូវបញ្ហានោះចេញបញ្ជាក់ថា កំណើតដោយក្រមុំព្រហ្មចារីនោះគឺដោយកិច្ចការដ៏អស្ចារ្យពិតប្រាកដ។ បញ្ហារបស់យ៉ូសែបគឺបែបមួយដែលគាត់មិនអាចគេចបាត់ទៅបាន។ មិនត្រឹមតែប៉ុណ្ណោះ ដូចដែលយើងឃើញការកត់ត្រានៃដំណឹងល្អលូកា (លូកា 1:5 -2:52) កំណើតរបស់ព្រះយេស៊ូវតាមរយៈស្រីក្រមុំព្រហ្មចារីនោះច្បាស់ណាស់។ នៅក្នុងចំណោមអ្នកវិទូខាងសាសនា និងសាសនវិទូនៅសម័យនោះ អ្នកខ្លះបដិសេធពីកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី ពួកគេមិនអាចបាំងនូវបន្ទាល់ត្រឹមត្រូវនៃសាសនវិទូត្រឹមត្រូវទេ។

សៀវភៅដែលជាសៀវភៅ “កំណើតដោយក្រមុំព្រហ្មចារីរបស់ព្រះគ្រីស្ទ” ត្រូវបានសរសេរដោយ លោកបណ្ឌិត ម៉ាឆេន បានលេចមកនូវទ្រឹស្ដីផ្ទុយគ្នានឹងសាសនវិទ្យាទាំងអស់ដោយគ្មានការសង្ស័យ។

លើសពីនេះទៅទៀត យើងទទួលបានព្រះគុណដ៏សំខាន់ខាងវិញ្ញាណក្នុងគោលលទ្ធិសេចក្ដីជំនឿនៃកំណើតនៃព្រហ្មចារី។ វាមានន័យថា គ្រិស្ដសាសនាត្រូវបានចាប់ផ្ដើមជាមួយនឹងជំនឿអរូបី។ សេចក្ដីសង្គ្រោះរបស់យើងមិនអាចសម្រេចបានដោយអបិយជំនឿទេ ព្រោះមនុស្សបានខូចខ្លាំងពេក។ ដោយសារសេចក្ដីសង្គ្រោះរបស់យើងស្របគ្នាដោយជំនឿអរូបី នោះយើងត្រូវបានជឿលើចលនានៃសេចក្ដីសង្គ្រោះនេះហើយដែលត្រូវបានទទួលយក។

1. ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះដែលយាងមកជាការសម្រេចបំពេញនូវទំនាយ (ខ 22)

កណ្ឌគម្ពីរសញ្ញាចាស់ជាប្រភេទចង្អុលទៅកាន់ព្រះយេស៊ូវ ឬជាទំនាយ។ ដ្បិតគ្រប់ទំនាយត្រូវបានសម្រេចដោយព្រះយេស៊ូវ អត្ថបទយើងបានដកស្រង់ អេសាយ 7:14 ជាតំណាងមួយ។ លើកលែងពីការទាំងនោះ ទំនាយជាច្រើនអំពីព្រះយេស៊ូវត្រូវបានសម្រេច។ យោងតាមពាក្យរបស់លោកបណ្ឌិត បារីង ដូច ជាសៀវភៅ LXX ចង្អុលទៅកាន់ ទំនាយពីព្រះគ្រីស្ទនៅក្នុងសញ្ញាចាស់មាន 456 ដង ទាំងនោះមាន 75 នៅក្នុងកណ្ឌគម្ពីរទាំង៥របស់ម៉ូសេ 243 នៅក្នុងកណ្ឌគម្ពីរហោរា និង 138 នៃកណ្ឌគម្ពីរផ្សេងទៀត។ គ្រប់ទាំងទំនាយទាំងនេះត្រូវបានសម្រេចបំពេញ។ ជាពិសេសនៅក្នុងចំណោមទំនាយដោយកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី អ្វីដែលយើងត្រូវផ្តោតលើនោះជាទំនាយពីបុរាណបំផុត ដែលជាការសម្រេចបំពេញនៃលោកុប្បត្តិ 3:15។ ព្រះបន្ទូលដែលចេញមកនៅទីនោះគឺ ការពិតដែល មួយអង្គដែលនឹងយកឈ្នះអារក្សត្រូវបានទាយទុកថា នឹងចេញមកពីពូជរបស់ស្ត្រី។ (កាឡាទី 4:4) នៅទីនេះ ពាក្យថា ពូជរបស់ស្ត្រី គឺចង្អុលទៅកាន់កំណើតព្រហ្មចារី។ អេសាយបានដឹងពីចំណុចនេះដោយព្រះវិញ្ញាណបរិសុទ្ធច្បាស់ណាស់ ហើយក៏បានថ្លែងទំនាយយ៉ាងច្បាស់ផង។ (អេសាយ 7:14) កាលដែលយើងស្តាប់ជំនឿមួយភាគបួននៃការសម្រេចបំពេញនូវទំនាយ។ (1) យើងជឿថាព្រះទ្រង់ផ្តល់នូវទំនាយនោះ (2) យើងជឿថា ឯកសារនៃទំនាយដែលជាព្រះគម្ពីរនោះគឺពិត (3) យើងជឿលើព្រឹត្តិការណ៍ (ឧទាហរណ៍ កំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី) ដែលត្រូវបានបង្ហាញដោយការសម្រេចបំពេញនៃទំនាយ។ (4) យើងជឿនូវការសន្យានៃព្រះពរនៅពេលបច្ចុប្បន្ន និងពេលអនាគតដែលព្រឹត្តិការណ៍នោះចង្អុលប្រាប់។ យើងគួរជឿតែព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានយាងមកសម្រេចបំពេញរាប់រយដងនៅក្នុងការពង្រឹង។ ដោយការជឿ

ដល់ព្រះអង្គសង្គ្រោះដែលយាងមក កាលដែលយើងជឿដល់ទ្រង់ពិត វាជាការអបអរដ៏មានអត្ថន័យនៃគ្រីស្ទាស់។

## ការអធិប្បាយ 5 អំពីកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី (ម៉ាថាយ 1:18-25)

កំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារីត្រូវបានកត់ទុកនៅ លូកា 1:39-2:20 ។ នេះអាចនិយាយបានថា គោលលិទ្ធិនៃគ្រីស្ទសាសនា និងវិធីជាគ្រឹះនៃកិច្ចការសេចក្ដីសង្គ្រោះ។ យើងនឹងគិតថា ដូចជាបន្ទាល់របស់ម៉ាថាយអំពីកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី។

1. អត្ថន័យនៃកំណើតដោយក្រមុំព្រហ្មចារី

នឹងត្រូវបានប្រសូត្រដោយព្រះវិញ្ញាណបរិសុទ្ធ ដូចដែលអត្ថបទបាននិយាយ គឺវាមានន័យថា ស្រីក្រមុំព្រហ្មចារីនឹងមានគភ៌ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ការនេះខុសពីគំនិតរបស់អ្នកកាន់សាសនាផ្សេងដែលបង្ហាញនៅក្នុងរឿងរបស់ពួកគេ។
ឧទាហរណ៍ នៅក្នុងប្រវត្តិសាស្ត្របុរាណ ត្រូវបានប្រាប់មកថា មានស្ដេចមួយអង្គត្រូវបានចាប់កំណើតកាលដែលមាតារបស់ទ្រង់បានឃើញនូវដានជើងធំមួយ។ វាមិនបានមានន័យថា មានគភ៌ក្រៅពីទំនាក់ទំនងប្ដីប្រពន្ធនោះទេ។ បើតាមសាច់រឿងរបស់អេដែន មនុស្សពេលឪពុករបស់ផ្លាទូននាំប្រពន្ធរបស់គាត់មក មនុស្សស្រីនោះបានបង្កើតផ្លាទូនរួចហើយ។

ប៉ុន្តែរឿងបែបនេះគឺជារឿងព្រេងមួយដែលល្បីក្នុងពេលនោះ ប៉ុន្តែគ្មានលក្ខណៈប្រវត្តិសាស្ត្រនោះទេ ។ មិនត្រឹមតែប៉ុណ្ណឹងទេ វាមិនមានន័យថា ម្ដាយរបស់ផ្លាតុនបង្កើតគាត់មកដោយក្រមុំព្រហ្មចារីសុទ្ធនោះទេ។ រឿងព្រេងស្រដៀងគ្នាមួយចំនួនដូចជាវាត្រូវ

បានបន្ថែមទៅវីរបុរសផ្សេងទៀតនៅសម័យបុរាណ ប៉ុន្តែវាមិនមែនមានន័យថាព្រហ្មចារីបរិសុទ្ធមានគភ៌ទាំងស្រុងនោះទេ ដោយទស្សនៈខុសនៃព្រះនៃមនុស្សបុរាណទេ វាគ្រាន់តែជាទេវកថាដែលចេញពីគំនិតទទេ។ ព្រះបានយកប្រពន្ធនៃជាមនុស្ស ហើយបង្កើតបានកូន។

កំណើតរបស់ព្រះយេស៊ូវតាមរយៈព្រហ្មចារីគឺខុសពីទេវកថាបុរាណដែលបាននិយាយខាងលើវាមានន័យថាដោយអំណាចនៃព្រះតែមួយប៉ុណ្ណោះដែលក្រមុំព្រហ្មចារីបានមានគភ៌។ ការនេះខុសពីគំនិតដែលថាព្រះ (ព្រះវិញ្ញាណបរិសុទ្ធ) យកប្រពន្ធនៅក្នុងលោកិយនេះ។ ដូចដែលព្រះទ្រង់បង្កើតគ្រប់ភាវៈទាំងអស់ទាំងនៅស្ថានសួគ៌ និងផែនដីដោយព្រះចេស្តា នោះទ្រង់ធ្វើឱ្យព្រះយេស៊ូវចាប់កំណើតដោយក្រមុំព្រហ្មចារីដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះយេស៊ូវដែលបានក្លាយជាព្រះអង្គសង្គ្រោះជាពូជពង្សរបស់អ័ដាម ទ្រង់មិនបានទទួលនូវធម្មជាតិដែលពុករលួយរបស់អ័ដាមនោះទេ ដោយកំណើតរបស់ទ្រង់ នោះមានកិច្ចការចូលរួមដ៏អស្ចារ្យរបស់ព្រះ។ មិនតែប៉ុណ្ណោះ សាសនាគ្រីស្ទជាសាសនាខាងវិញ្ញាណតាំងពីដើមរហូតដល់ចប់ វាធម្មតាទេដែលត្រូវចាប់ផ្តើមជាមួយនឹងសាសនាខាងវិញ្ញាណបែបនេះ។

## 2. ភាពបរិសុទ្ធនៃទំនៀមទម្លាប់អំពីកំណើតដោយក្រមុំព្រហ្មចារី

ដូចជាយើងឃើញនៅក្នុងខ 19 យ៉ូសែបមានគំនិតជាច្រើនបន្ទាប់ពីដឹងការពិតថា ម៉ារាមានគភ៌។ គាត់បានគិតពីដំណោះស្រាយចំពោះបញ្ហា ដោយគាត់គិតថាវាជាបញ្ហាមួយ។ តែគាត់បានដោះស្រាយបញ្ហាកាលដែលការបើកសម្តែងដ៏អស្ចារ្យ នោះគាត់ក៏លែងលំបាកចិត្តដូចមុន។ ដូចជាយើងបានឃើញ ពីការផ្លាស់ប្តូរចិត្តរបស់គាត់។ វា

ធម្មតាទេនៅពេលដែលគាត់បានស្តាប់ទៅកាន់ដំណឹងនៃកំណើតរបស់ម៉ារា នោះបញ្ហារបស់គាត់គឺនឹងបានជាបញ្ហាធំច្បាស់ណាស់។ ប៉ុន្តែបន្ទាប់ពីបញ្ហាត្រូវបានដោះស្រាយហើយមានសុវត្ថិភាពពេញមួយជីវិតរបស់ យើងមិនអាចជួយបានទេ ក្រៅពីគិតថាវាជាការជ្រៀតជ្រែកពិសេសរបស់ព្រះ។ ពិតជាទេវតាបានបង្ហាញខ្លួនដល់គាត់មែន។ វាបាននាំមកនូវដំណោះស្រាយនៃបញ្ហាដល់គាត់។ ពេលនោះបញ្ហាបានកើតឡើង ជាការអស្ចារ្យដ៏បរិសុទ្ធ ដោយមិនមានអ្វីខុស (ហៅថាអ្នកសុចរិត) វានឹងត្រូវដោះស្រាយចំពោះគាត់។ បន្ទាប់មក វាប្រាកដណាស់ថាកំណើតនៃព្រហ្មចារីគឺជាគោលជំនឿរបស់យ៉ូសែប។ មិនត្រឹមតែវាជាការដែលយើងឃើ្ញប្រវត្តិនៃគោលលិទ្ធិរបស់គ្រីស្ទាន នូវកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារីជាគោលជំនឿនៅស.វទី២។ ម្យ៉ាងទៀត វាគឺជាគោលលទ្ធិរបស់ពួកជំនុំគឺដែលបានកើតឡើងចំពោះព្រះយេស៊ូវ ហើយសាវ័កបាននាំយកមក។ គោលលទ្ធិនេះត្រូវបានផ្ទេររហូតមកដល់សព្វថ្ងៃនេះតាមប្រវត្តិសាស្ត្រ (Dr. J. G. Machen, The Virgin Birth of Christ, ទំព័រ ២-៤៣) មិនត្រឹមតែប៉ុណ្ណោះ ដោយសារតែការប្រសូតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារីត្រូវបានកត់ត្រានៅ ម៉ាថាយ 1:18 និងនៅលូកា ជំពូកទី 1, 2 វាគឺជាមេរៀននៅក្នុងលក្ខណៈវិនិច្ឆ័យនៃជំពូក និងខគម្ពីរយ៉ាងទូលំទូលាយ ដែលមិនអាចបកស្រាយខុសគ្នានៅក្នុងបញ្ហានៃបំណែកគម្ពីរ និងបញ្ហាការបកស្រាយ។ ដូច្នេះ យើងជឿលើគោលលទ្ធិច្បាស់ណាស់ ដោយសារយើងជឿលើសិទ្ធិអំណាចនៃបទគម្ពីរ។ យើងចង់គិតថា សំខាន់ជាងនេះទៅទៀត ជាចំណុចសំខាន់ដែលការប្រសូតរបស់ព្រះយេស៊ូតាមរយៈក្រមុំព្រហ្មចារី គឺជាគោលលទ្ធិប្រាកដរបស់ព្រះយេស៊ូវ។

តើជាវិធីសាស្ត្រនៃការបើកសម្តែងអ្វីដែលត្រូវបានបើកសម្តែងដល់យ៉ូសែប?

អំពីបញ្ហានៃការប្រសូតរបស់ព្រះយេស៊ូវតាមរយៈស្ត្រីព្រហ្មចារី ព្រះបានជូនដំណឹងអំពីការទាំងអស់តាមរយៈការបង្ហាញពួកគេដល់យ៉ូសែប ព្រះបានបើកសម្តែងវាដល់យ៉ូសែបតាមរយៈសុបិន។ នេះជាចំណុចពិសេសចំពោះវិធីសាស្ត្រនៃការបើកសម្តែងដល់យ៉ូសែប ។ នៅពេលយើងឃើញវិធីសាស្ត្រនៃវិវរណៈដល់យ៉ូសែប យើងអាចចង្អុលទៅមិនមែនមធ្យោបាយតែមួយគត់នោះទេ។ វាដូចជាខុសគ្នាខ្លះក្នុងការទទួលព្រះគុណពីព្រះនៅក្នុងសម័យក្រុមជំនុំ។ យ៉ូសែបបានទទួលការដឹកនាំពីព្រះតាមរយៈសុបិន។(ម៉ាថាយ 1:20, 2:13, 19) នៅថ្ងៃនៃការបើកសម្តែង សុបិនតែងតែមិនបង្រៀនការពិត។ សព្វថ្ងៃនេះមានសុបិនបីប្រភេទ ដែលមួយណាជាសុបិនឥតប្រយោជន៍ គឺការមើលឃើញអ្វីដែលមនុស្សគិតជាឈុតឆាកខ្លះ ឬក្នុងការគេងរបស់គាត់ ហើយឈុតឆាកខ្លះត្រូវបានបង្កើតឡើងក្នុងស្មារតីរបស់គាត់ ដោយទទួលបានឥទ្ធិពលនៅក្នុងស្មារតីរបស់គាត់។ ឧទាហរណ៍ បើកាលណាជើងរបស់មនុស្សដែលកំពុងដេកលក់ធ្លាក់ចុះពីកន្លែងខ្ពស់ វាប្រៀបដូចជាថា គាត់ផ្ទាល់ត្រូវបានធ្លាក់ចុះក្រោមទៅដល់បាតពីច្រាំងថ្មមក ហើយបានស្តាប់ទៅកាន់សម្លេងដង្ហើមរបស់គាត់យ៉ាងខ្លាំង គាត់គិតថាកាលដែលគាត់ស្តាប់ទៅកាន់សម្លេងនៃទំនុកដំកើង ឬគាត់ផ្ទាល់ដែលសរសើរនូវទំនុកដំកើង។ ហើយមួយទៀត ជាសុបិនដែលអាក្រក់ ដែលអាចត្រូវបានចាប់អារម្មណ៍យ៉ាងខ្លាំង និងទិដ្ឋភាពគួរឱ្យភ្ញាក់ផ្អើលមួយចំនួន។ ប៉ុន្តែដោយសារគាត់ពឹងផ្អែកលើសុបិនបែបនេះ គាត់អាចនឹងត្រូវបរាជ័យយ៉ាងខ្លាំង។ បន្ទាប់មក មួយទៀតបានចេញមកពីការប្រទានមករបស់ព្រះ សុបិនបែបនេះអាចផ្តល់ផលប្រយោជន៍ខ្លះដល់គាត់ចំពោះការទាមទារផ្ទាល់ខ្លួន ប៉ុន្តែពេលដែលគាត់ប្រាប់វាជាសាធារណៈ ឬពេលគាត់ជឿទុកចិត្តលើវាខ្លាំងពេក មានរឿងបរាជ័យ។

យើងទទួលស្គាល់ថា យ៉ូសែបបានជឿលើកំណើតរបស់ព្រះយេស៊ូវតាមរយៈក្រមុំព្រហ្មចារី និងរបៀបដែលព្រះយេស៊ូវបានធ្វើកិច្ចបម្រើដ៏អស្ចារ្យ ។ ជាពិសេស យើងចង់សង្កត់ធ្ងន់ទៅលើការពិតដែលថា យ៉ូសែបបានជឿលើការប្រសូតរបស់ព្រះយេស៊ូវតាមរយៈព្រហ្មចារី។ ដោយសារយើងអាចដឹងវាដូចជាយើងឃើញការពិតដែលថាគាត់បានហៅឈ្មោះរបស់កូនថាយេស៊ូដូចដែលគាត់បានទទួលនៅក្នុងសុបិនរបស់គាត់។ ព្រះនាមព្រះយេស៊ូវ ដែលត្រូវបានបង្រៀនដល់យ៉ូសែបនៅក្នុងសុបិនរបស់គាត់។ តាមពិតកំណើតរបស់ព្រះយេស៊ូវគឺជាគោលជំនឿរបស់យ៉ូសែប។

## ការអធិប្បាយ 6 សេចក្ដីសន្យារបស់ព្រះ (លូកា 1:72-73)

លោកគ្រូ មូឌី បាននិយាយថា “ការដែលអ្នកលើកសមុទ្រ នោះវាងាយជាងការប្តូរព្រះបន្ទូលរបស់ព្រះ”។ សាការីបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ គាត់បានឃើញពីរបៀបដែលព្រះបន្ទូលនៃការសន្យារបស់ព្រះត្រូវបានសម្រេចយ៉ាងច្បាស់ និងយ៉ាងស្មោះត្រង់។ ព្រះទ្រង់បានប្រទាននូវព្រះបន្ទូលសន្យាដល់យើង និងសង្គ្រោះយើង។ កណ្ឌគម្ពីរសញ្ញាចាស់និងសញ្ញាថ្មីជាព្រះបន្ទូលនៃការសន្យា។ កណ្ឌគម្ពីរសញ្ញាចាស់ត្រូវបានសម្រេចដោយកណ្ឌគម្ពីរសញ្ញាថ្មី។ កណ្ឌគម្ពីរសញ្ញាថ្មីត្រូវបានសម្រេចដោយការយាងមកជាលើកទីពីររបស់ទ្រង់។ ព្រះទ្រង់សង្គ្រោះដោយប្រព័ន្ធនៃការសន្យាដូច្នេះ។ ហើយដោយការរក្សានូវសេចក្ដីសន្យារបស់ទ្រង់ នោះទ្រង់មានចំណុចមួយធំគឺភាពស្មោះត្រង់រហូតដល់ទ្រង់បានសម្លាប់បុត្រាតែមួយរបស់ទ្រង់ផង។ គឺនៅក្នុងការសម្រេចបំពេញនូវការសន្យារបស់ទ្រង់ ព្រះទ្រង់មានវិធីសាស្ត្រយ៉ាងធំអស្ចារ្យ ដែលចិត្តដ៏តូច និងងងឹតរបស់យើងមិនអាចជឿបានបណ្ដោះអាសន្ន។

1. ទ្រង់បានជ្រើសផ្លូវដ៏ឆ្ងាយដោយត្រឡប់មកវិញរហូតដល់ទ្រង់សម្រេចតាមនូវការសន្យា។

សេចក្ដីសន្យារបស់ទ្រង់គឺទៅខាងកើត ហើយវិធីសាស្ត្រនៃការសម្រេចបំពេញរបស់ទ្រង់មិនតម្រង់ទៅទិសខាងកើតទេ។ ដំបូងបំផុត ភាគច្រើន ទ្រង់ចេញតាមទិសដៅ

ដែលបញ្ច្រាស។ បើទោះជាព្រះទ្រង់បានសន្យានឹងអ័ប្រាហាំហើយវាត្រូវបានសម្រេចបំពេញដោយការទៅយកទឹកដីកាណាន តែដំបូង ពូជពង្សរបស់គាត់បានបម្រើជាទាសករនៅប្រទេសអេស៊ីបអស់រយៈពេល ៤៥០ឆ្នាំ។ ការសម្រេចបំពេញនៃខ្លឹមសារនៃការសន្យានឹងបានកើតឡើងនៅទឹកដីកាណាន ត្រូវសម្រេចតាមដំណើរការនៃខ្លឹមសារនៃការសន្យានោះ។

2. ការសម្រេចតាមសន្យាត្រូវបានសម្រេចដោយចំណាយពេលយូរ

ព្រះទ្រង់បានអនុវត្តតាមការសន្យារបស់ទ្រង់ដល់យើង ដែលពេលប្រាកដជាក់ស្តែងមិនទាន់មកដល់នៅឡើយ នោះទ្រង់នៅស្ងៀមស្ងាត់។ ដូច្នេះ មានការស៊ូទ្រាំជាយូរដូចនោះ ដែលជាហេតុផលត្រូវរង់ចាំ គឺដោយសារវាមានតម្លៃសម្រាប់យើង ដោយទ្រង់សម្រេចវាតាមពេលច្បាស់លាស់របស់ទ្រង់។ អេសាយ 30:18 មានបន្ទូលថា “ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាទ្រង់រង់ចាំឱកាស នឹងផ្តល់ព្រះគុណដល់ឯងរាល់គ្នាដែរ ហើយទោះបើយ៉ាងនោះក៏ដោយ គង់តែទ្រង់នឹងចាំឯងលើកដំកើងទ្រង់ឡើង ដើម្បីឱ្យទ្រង់មានសេចក្តីអាណិតមេត្តាដល់ឯង”។ ដ្បិតព្រះទ្រង់មានបន្ទូលថា កាលណាជាតិសាសន៍អី ុស្រាអែលប្រព្រឹត្តអំពើបាប នោះទ្រង់នឹងពង្រាយគេទៅគ្រប់ជាតិសាសន៍ទាំងអស់ ហើយពួកគេនឹងត្រូវទៅទីនោះ ដែលចេញមកពីកណ្ឌគម្ពីរចោទិយកថា។ នោះគឺថា “បើឯងមិនព្រមប្រយ័ត្ន និងធ្វើតាមអស់ទាំងពាក្យក្នុងក្រឹត្យវិន័យដែលបានកត់ទុកក្នុងគម្ពីរនេះ ដើម្បីឱ្យបានកោតខ្លាចដល់ព្រះនាមដ៏មានសិរីល្អ ហើយគួរស្ញែងខ្លាចនេះ គឺ ព្រះយេហូវ៉ា ជាព្រះនៃឯង។ នោះព្រះយេហូវ៉ានឹងធ្វើឱ្យសេចក្តីវេទនារបស់ឯង បានចំឡែកអស្ចារ្យព្រមទាំងសេចក្តីវេទនានៃពូជឯងផង គឺជាសេចក្តី

វេទនាយ៉ាងធំ ហើយជាប់ជាយូរ និងជំងឺគ្រាំគ្រាដែលនៅជាប់ជាយូរដែរ។ ទ្រង់នឹងធ្វើឱ្យឯងកើតអស់ទាំងជំងឺរបស់ស្រុកអេស៊ីព្ទ ដែលឯងបានខ្លាចនោះទាំងប៉ុន្មាន ជំងឺទាំងនោះនឹងនៅជាប់នឹងឯង។ ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យឯងកើតគ្រប់ទាំងជំងឺ ហើយនឹងសេចក្ដីវេទនាទាំងអស់ ដែលមិនបានកត់ទុកក្នុងគម្ពីរក្រឹត្យវិន័យនេះទៀត ដរាបដល់ឯងបានវិនាសបាត់អស់រលីងទៅ។ ហើយទោះពីដើមឯងរាល់គ្នាមានគ្នាច្រើនដូចជាផ្កាយនៅលើមេឃក៏ដោយ គង់តែនឹងនៅសល់តែបន្តិចទេ ពីព្រោះឯងមិនបានស្ដាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯង។ នៅគ្រានោះព្រះយេហូវ៉ាទ្រង់នឹងសព្វព្រះហឫទ័យ ធ្វើឱ្យឯងរាល់គ្នាវិនាស ហើយនឹងបំផ្លាញឯងរាល់គ្នាចេញ ដូចជាកាលពីដើមទ្រង់សព្វព្រះហឫទ័យ នឹងប្រោសសេចក្ដីល្អដល់ឯង ហើយចំរើនឯងរាល់គ្នាឡើងនោះដែរ ឯងរាល់គ្នានឹងត្រូវដកចេញពីស្រុក ដែលឯងនឹងចូលទៅចាប់យកនោះ។ ព្រះយេហូវ៉ាទ្រង់នឹងកំចាត់កំចាយឯង ឱ្យទៅនៅក្នុងគ្រប់ទាំងសាសន៍ ពីចុងផែនដីម្ខាង រហូតដល់ចុងផែនដីម្ខាង នៅទីនោះឯងនឹងគោរពប្រតិបត្តិដល់ព្រះដ៏ទៃធ្វើពីឈើ ហើយនឹងថ្ម ដែលឯង និងពួកឰយុកោឯងមិនដែលស្គាល់សោះ។ នៅក្នុងសាសន៍ទាំងនោះ ឯងនឹងរកសេចក្ដីស្រណុកមិនបាន ហើយបាតជើងឯងមិនចេះបានសំរាកឡើយ គឺនៅទីនោះព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យចិត្តឯងញ័ររន្ធត់ ឱ្យភ្នែកឯងស្រវាំងទៅ ហើយឱ្យមានគំនិតព្រួយលំបាកដែរ។ ទោះទាំងជីវិតឯង ក៏នឹងគ្មានទីកំណត់ដល់ឯងផង ឯងនឹងចេះតែភ័យខ្លាចទាំងយប់ទាំងថ្ងៃ ឥតមានសង្ឃឹមនឹងរស់នៅឡើយ” (ចោទិយកថា 28:58-66) ព្រះបន្ទូលនេះត្រូវបានសម្រេចបន្ទាប់ពីប៉ុន្មានរយឆ្នាំក្រោយមក។ គឺវាត្រូវបានសម្រេចកាលដែលអ៊ីស្រាអែលត្រូវបាននិរទេស និងជាប់គុកដោយកងទ័ពរបស់អាស៊ីរីប្រហែលនៅឆ្នាំ 745 មុនគ្រឹស្តសករាជ។ 700 ក្រោយបន្ទាប់ពីវាបានសម្រេច។ ព្រឹត្តិការណ៍នៃព្រះគ្រីស្ទត្រូវបានមកកាន់លោកិយ ជាដំបូងព្រះបាន

សន្យានឹងអ័ប្រាហាំប្រហែល 2000 ឆ្នាំមុនគ្រីស្តសករាជនៅគ្រាមុននោះ។ លោកុប្បត្តិ 12:3 មានបន្ទូលថា “អញនឹងឱ្យពរដល់អស់អ្នកណាដែលឱ្យពរដល់ឯង ហើយនឹងដាក់បណ្តាសាដល់អស់អ្នកណាដែលផ្តាសាឯង គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង”។ សេចក្តីសន្យានេះត្រូវបានសម្រេច 2000 ឆ្នាំក្រោយមក។ បើទោះជាវាត្រូវបានសម្រេចបន្ទាប់ពីច្រើនឆ្នាំក្រោយមក តែវាជាការពិតដែលព្រះបន្ទូលរបស់ព្រះត្រូវបានសម្រេច។ ដ្បិតព្រះទ្រង់ស្មោះត្រង់ណាស់ ដូច្នេះយើងសង្ឃឹមលើទ្រង់ សម្លឹងទៅកាន់ទ្រង់ និងអធិស្ឋានទៅរកទ្រង់។ ដូច្នេះទំនុកដំកើងបាននិយាយដដែលថា “ចូរអំពាវនាវដល់អញនៅថ្ងៃមានសេចក្តីទុក្ខលំបាក

នោះអញនឹងជួយឱ្យរួច ឯងនឹងលើកដំកើងដល់អញ។” (ទំនុកដំកើង 50:15)

**ការអធិប្បាយ 7 ស៊ីម៉ូន និងអាណា (លូកា 2:21-39)**

ឪពុកម្តាយរបស់ព្រះយេស៊ូវបានឡើងទៅកាន់ព្រះវិហារដើម្បីនឹងថ្វាយទ្រង់ដល់ព្រះ។ បន្ទាប់មកលោក ស៊ីមាន និងអាណាបានស្គាល់ទ្រង់។

1. សីុមាន

ត្រូវបាននិយាយថាគាត់ជា "មានមនុស្សម្នាក់ឈ្មោះស៊ីម្មាន ជាអ្នកសុចរិត ដែលកោតខ្លាចដល់ព្រះ គាត់រង់ចាំសេចក្តីដោះទុក្ខ របស់សាសន៍អ៊ីស្រាអែល។" សេចក្តីសុចរិត និងសេចក្តីកោតខ្លាចដល់ព្រះគួរតែដើរទន្ទឹមគ្នា។ ដោយសារការគោរពកោតខ្លាចដល់ព្រះខាងវិញ្ញាណមិនមានជីវិតសុចរិត គឺមានន័យថាបម្រើព្រះតែសំបកខាងក្រៅ ហើយព្រះទ្រង់មិនសព្វព្រះទ័យនោះទេ។ ស៊ីមានមិនបន្ទូរបន្ថយជាមួយនឹងជំនឿដែលអាក្រក់ និងគ្រាដែលពុករលួយនោះទេ តែគាត់មានភាពសុចរិត និងការកោតខ្លាចដល់ព្រះដែលព្រះទ្រង់សព្វព្រះទ័យ។ នេះគឺជាការកាន់ជាប់នូវខ្សែនៃផ្លូវតែមួយក្នុងការរស់នៅក្នុងជីវិតនៃសង្ឃឹមនៅក្នុងគ្រាដែលអាក្រក់។ មិនតែប៉ុណ្ណោះ សីុមានមិនមែនដើរតាមរឿងព្រេងនោះទេ តែគាត់មានសេចក្តីជំនឿដែលចាក់ឫសនៅក្នុងការបើកសម្តែងរបស់បទគម្ពីរ ហើយកំពុងរង់ចាំនូវការកំសាន្តសម្រាប់អីុស្រាអែល។ "សេចក្តីកំសាន្តដល់អីុស្រាអែល" ចង្អុលទៅកាន់សេចក្តីកំសាន្តដែលមកពីព្រះមេសីុដែលនឹងសង្គ្រោះដោយការពឹងផ្អែកលើពាក្យទំនាយរបស់ហោរា (អេសាយ 40:1, 2, 49:13, 51:3 61:2, 3)

ចម្រៀងរបស់លោកសីុមាន និងទំនាយរបស់គាត់ចង្អុលទៅកាន់ផ្នែកដ៏មានអត្ថន័យនៃកិច្ចការរបស់ព្រះគ្រីស្ទយ៉ាងច្បាស់។

(1) បានទាយពីសេចក្តីសង្គ្រោះដែលមានឥទ្ធិពលលើគ្រប់ជាតិសាសន៍ (ខ 31)

(2) វាចង្អុលទៅកាន់ព្រះគ្រីស្ទថាជាសេចក្តីពិតតែមួយ (ខ 34) ដូចជាអត្ថបទនិយាយថា "ព្រះគ្រីស្ទ" ជាមួយអង្គដែលមនុស្សដែលត្រូវបានវិនាសហើយ តែនឹងត្រូវរស់ឡើងវិញ ការនេះមានន័យថាអ្នកណាដែលទទួលព្រះគ្រីស្ទនឹងត្រូវប្រោសឱ្យរស់

ឡើងវិញ តែអ្នកដែលទាស់នឹងទ្រង់នឹងត្រូវវិនាសទាំងស្រុង ពីព្រោះព្រះគ្រីស្ទជាសេចក្ដីពិតតែមួយគត់។

(3) វាចង្អុលមកថា ព្រះគ្រីស្ទនឹងត្រូវរងទុក្ខដោយការបៀតបៀន និងសេចក្ដីវេទនានៅក្នុងលោកិយ។ (34, 35)

អត្ថបទនេះនិយាយថា “មើល បុត្រនេះបានតាំងឡើង សំរាប់ធ្វើឱ្យពួកសាសន៍អ៊ីស្រាអែលជាច្រើនដួល ហើយងើបឡើងវិញ ក៏សំរាប់ជាទីសំគាល់ ដែលគេនឹងស្រដីទទឹងផង។” ជាទំនាយពីការរងទុក្ខរបស់ព្រះគ្រីស្ទ។

2. អាន់ណា

អាន់ណាជាមនុស្សម្នាក់ដែលមិនចាកចេញពីព្រះវិហារឡើយ ហើយតែងតែតម និងអធិស្ឋាន។ ក្នុងនាមជាហោរាស្រី បើទោះជានាងចាស់ក៏ដោយ ការពិតដែលថានាងមានភាពស្មោះត្រង់យ៉ាងអស្ចារ្យ ជាជីវិតដ៏មានតម្លៃរបស់នាងនៃជំនឿដូចជាយ៉ាកុបដែលពឹងផ្អែកលើឈើច្រត់ និងថ្វាយបង្គំដល់ព្រះ។ នាងជាអ្នកជឿដោយការមើលទៅកាន់សេចក្ដីប្រោសលោះដោយផ្អែកលើព្រះបន្ទូលនៃបទគម្ពីរ។ ព្រះទ្រង់បានផ្ដល់នូវការបើកសម្ដែងពិសេសដោយព្រះវិញ្ញាណបរិសុទ្ធដល់អ្នកជឿដូចនាង ហើយធ្វើឱ្យនាងបានស្គាល់ព្រះគ្រីស្ទ។

## ការអធិប្បាយ 8 កំណើតរបស់ព្រះគ្រីស្ទ និងការឆ្លើយតបរបស់មនុស្ស (ម៉ាថាយ 2:1-12)

1. អត្ថន័យនៃសកម្មភាពរបស់អ្នកប្រាជ្ញដែលបានស្វែងរក។ ការពិតដែលពួកគេបានឃើញផ្កាយនៅទិសខាងកើត ហើយបានមកដើម្បីនឹងថ្វាយបង្គំនោះជាសេចក្តីជំ

នឿ។ ពីព្រោះវាច្បាស់ថា ពួកគេបានឃើញផ្កាយនៃស្តេចរបស់សាសន៍យូដា ហើយបានរង់ចាំទ្រង់។ សេចក្តីជំនឿត្រូវបានប្រើឱ្យទន្ទឹងរងចាំមើលការសម្រេចបំពេញនៃព្រះបន្ទូល។ ការមើលឃើញការដែលចេញមកពីព្រះបន្ទូលរបស់ព្រះនោះជាជំនឿ។

(2) ពីព្រោះវាជាការផ្សងព្រេងនៃជំនឿរបស់ពួកគេ ដែលពួកគេបានខំស្វែងរករហូតមកដល់យូដា។ វាជាការដែលអាក្រក់មួយ ដែលពួកគេបានចូលទៅកាន់រាជធានីរបស់យូដា ហើយបាននិយាយពីកំណើតរបស់ស្តេចថ្មីទៅកាន់ស្តេចហេរ៉ូឌក៏កំណាច។ តែដោយការធានាអះអាងបានធ្វើឱ្យពួកគេលែងភ័យខ្លាចនូវភាពឃោឃៅ។ សេចក្តីជំនឿមិនមែនជាការមួយដែលដើរដោយមិនមានការធានាអះអាងនៃព្រះបន្ទូលរបស់ព្រះនោះទេ តែវាមិនបន្ធូរបន្ថយនឹងមនុស្សខាងលោកិយដោយគ្មានការធានាអះអាងនោះឡើយ។ មនុស្សនៃសេចក្តីជំនឿដឹងថាព្រះយេស៊ូវជាស្តេច ហើយទ្រង់រក្សានូវព្រះបន្ទូលរបស់ទ្រង់។ សេចក្តីជំនឿរក្សានូវបំណងព្រះហឫទ័យរបស់ព្រះជានិច្ច បើទោះជាមនុស្សមិនពេញចិត្តក៏ដោយ។ នៅក្នុងការរក្សានូវថ្ងៃរបស់ព្រះអម្ចាស់ក្នុងនាមជាគ្រីស្ទាន គេមិនគួរធ្វើការខាងលោកិយនៅថ្ងៃនោះឡើយ។

(4) ដ្បិតពួកគេបានថ្វាយបង្គំទារកយេស៊ូវ នោះជាទង្វើមួយដែលបង្ហាញពីសង្ឃឹមនៃអនាគតតាមពីស្ថានភាពបច្ចុប្បន្ននេះ។ ទារកមិនទាន់បានឡើងដល់ភាពជាស្តេចនៅឡើយ តែពួកគេបានថ្វាយបង្គំព្រះឱរសយេស៊ូវ ហើយបានថ្វាយទ្រង់នូវអំណោយដ៏មានតម្លៃរបស់ស្តេចផង។ វាមានន័យថាជាការស្តាបបង្គាប់ដែលគ្មានលក្ខខណ្ឌទៅកាន់ព្រះយេស៊ូវ។ យើងគួរតែស្តាប់បង្គាប់ព្រះយេស៊ូវដោយគ្មានលក្ខខណ្ឌ។ ពីព្រោះព្រះទ្រង់ជាទីជ្រកកោនដល់យើងនៅក្នុងអង្គទ្រង់ ឬនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ការពឹងផ្អែកលើទ្រង់នោះជាសេចក្តីសុខសាន្ត ហើយការស្តាប់បង្គាប់ដល់ព្រះបន្ទូលទ្រង់

ដោយស្មោះត្រង់ជាព្រះពររបស់យើង។ កាលដែលយើងមិនចាត់ទុកព្រះជាម្ចាស់ជាស្ដេចរបស់យើងនោះជាការមិនជឿហើយ។

2. ស្ដេចហេរ៉ូឌ និងមនុស្សនៅយេរូសាឡិមទាំងមូលបានស្ដាប់ទៅកាន់ដំណឹងនៃកំណើតរបស់ព្រះគ្រីស្ទ

ហេតុអ្វីបានជាពួកគេមិនពេញចិត្ត តែច្រទ្បំទៅវិញ កាលដែលពួកគេស្ដាប់ពីអំណឹងដ៏ពេញដោយអំណរនោះ? វាត្រូវបានបកស្រាយដូចតទៅនេះ៖

1) ពីព្រោះពួកគេនិយាយថា ពួកគេល្អជាងអ្នកផ្សេង តែតាមពិតទៅពួកគេអាក្រក់ជាអ្នកផ្សេងទៀតផង។ ម្យ៉ាងទៀត ពួកគេស្ថិតនៅក្នុងស្ថានភាពដែលដេកលក់ដែលបានគិតថាពួកគេធំជាងអ្នកដទៃ។ ប៉ុលបាននិយាយថា “កុំឱ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្ដីអំនួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឱ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ” (ភីលីព 2:3)។ យើងគួរចាត់ទុកអ្នកដទៃប្រសើរជាងខ្លួន ដ្បិតខ្ញុំបានស្លាប់ដោយសារកំហុសនិងអំពើបាប (អេភេសូ 2:1) អ្នកដទៃ ហើយនឹងខ្ញុំគឺដូចគ្នា។

កាលណាអ្នកផ្សេងទៀតមានកំហុស ប្រសិនបើខ្ញុំមើលងាយគេដោយចិត្តឆ្មើងឆ្មៃរបស់ខ្ញុំ វាមានន័យថាខ្ញុំបានធ្វើបាបខ្លាំងជាងគេហើយ។ មិនតែប៉ុណ្ណោះ កាលណាយើងធ្វើការល្អ នោះវាងាយស្រួលដែលយើងធ្វើវាដោយប្រើវិធីដែលខុច។ នោះវាអាក្រក់ជាជាងការដែលយើងមិនធ្វើការល្អសោះផង។

ស្ដេចហេរ៉ូឌ និងពួកយូដាបានអះអាងថាគេបម្រើព្រះ តែពួកគេជាមនុស្សមានពុតហើយបានមើលងាយដល់អ្នកដទៃ។ នេះជាទង្វើដែលបានធ្លាក់ចុះនៅក្នុងស្ថានភាពដ៏អាក្រក់ជាអ្នកមិនជឿផង។ ដូច្នេះ ពួកគេបានស្ដាប់ទៅកាន់ការប្រកាសរបស់អ្នកមិន

ជឿ ថាស្តេចរបស់ពួកយូដាបានប្រសូត្រ នោះពួកគេច្របូកច្របល់។ អំណឹងល្អ និងសំបុត្របង្ហាញថាពួកសាសន៍ដទៃបានស្វាគមន៍ដល់ដំណឹងល្អជាជាងសាសន៍យូដា។ នេះជាសេចក្តីពិត ដែលអ្នកមកក្រោយបានក្លាយជាអ្នកទីមួយវិញ។ សេចក្តីពិតនេះជាក្រិត្យវិន័យរបស់ព្រះដែលធ្វើឱ្យរបស់ដែលគ្មានសោះបានធ្វើឱ្យអ្វីមួយទៅជាអាម៉ាស់ ដែលធ្វើឱ្យយើងបានស្គាល់ព្រះដ៏មានព្រះជន្មរស់។ យើងគួរតែចង់ចាំថា អ្នកដែលមានអ្វីមួយត្រូវរស់នៅដូចជាគ្មានវិញ។ ការទំនាក់ទំនងខាងវិញ្ញាណដែលអួតពីសាសនាដែលព្រះផ្តល់មក តែមើលងាយដល់អ្នកមិនជឿនោះបានចាកចេញពីព្រះហើយ។ ដោយផ្ទុយពីនោះ អ្នកមិនជឿដែលមានព្រះបន្ទូលរបស់ព្រះដោយកម្រជាងការដែលទទួលបានសេចក្តីស្រឡាញ់របស់ព្រះ។ អ្នកប្រាជ្ញនេះអាចជាចង់ចាំពីព្រះបន្ទូលនៅ ជនគណនា 24:14 ដ៏មានអត្ថន័យ។ ពីព្រោះព្រះបន្ទូលដែលបានទាយនៅទីនោះថា “មើល ទូលបង្គំត្រឡប់ទៅឯសាសន៍ទូលបង្គំឥឡូវនេះឯង សូមយាងមកនេះ ទូលបង្គំនឹងប្រកាសទូលទ្រង់ពីរដែលសាសន៍នេះ នឹងធ្វើដល់សាសន៍ទ្រង់នៅគ្រាជាន់ក្រោយ។” ម៉ូអាប់ដែលត្រូវបានបំផ្លាញ។ អ្នកដែលទទួលសូម្បីតែព្រះបន្ទូលមួយរបស់ព្រះហើយស្តាប់ព្រះបន្ទូលនោះ ហើយធ្វើតាម នោះគេនឹងទទួលបានព្រះពរ តែអ្នកដែលស្តាប់ច្រើន តែមិនធ្វើតាម នោះគេបានធ្វើបាបដោយការមើលងាយព្រះវិញ។

(2) ដ្បិតពួកគេស្រឡាញ់លោកិយជាងនគររបស់ព្រះ នោះគេក៏ច្របូកច្របល់។ កាលណាអ្នកណាស្រឡាញ់ព្រះ ហើយបានជួបព្រះ នោះពួកគេមានសេចក្តីក្លាហាន។

(3) ពួកគេមិនមានការរៀបចំដើម្បីនឹងទទួលព្រះគ្រីស្ទ។ តែពួកគេរីករាយនឹងអំពើបាបដែលព្រះគ្រីស្ទមិនសព្វព្រះហឫទ័យវិញ នោះគេក៏ច្របូកច្របល់។

(5) ដ្បិតពួកគេត្រូវបានព្រះចាប់បាន នោះពួកគេក៏ច្របូកច្របល់។

(6) គ្រូគង្វាលម្នាក់បានជិះរថភ្លើងដោយអង្គុយជាមួយបុរសក្មេងម្នាក់ដែលមានជំនឿខ្សោយ។ ដ្បិតបុរសក្មេងគ្មានសេចក្ដីសុខសាន្តនៅក្នុងចិត្តទេ នោះគ្រូគង្វាលបាននិយាយទៅកាន់គាត់ថា "តើអ្នកមើលឃើញដាវតូចនេះទេ?" ចូរមើលមកដាវដែលដាក់នៅលើសៀវភៅនេះមើល" គាត់ដាក់ដាវតូចនោះនៅលើសៀវភៅដោយដៃរបស់គាត់។ រួចបុរសវ័យក្មេងនោះនិយាយថា "ដោយសារលោកគ្រូគង្វាលកាន់វា នោះទើបវាបាននៅជាប់លើនោះ"។ គ្រូគង្វាលក៏ឆ្លើយថា "គឺដូច្នេះដែរ ដែលព្រះទ្រង់កាន់ចិត្តរបស់អ្នក នោះអ្នកមិនត្រូវរង្គើឡើយ"។

5) ពីព្រោះពួកគេមិនភ្លក្សនូវសេចក្ដីស្រឡាញ់របស់ព្រះ នោះពួកគេមិនពេញចិត្តនឹងការយាងមករបស់ព្រះគ្រីស្ទទេ តែពួកគេច្របូកច្របល់វិញ។ គ្រូគង្វាលជនជាតិស្កុតម្នាក់ឈ្មោះ ម៉ាក់នេល បានធ្វើការនៅចម្ងាយឆ្ងាយពីផ្ទះរបស់គាត់ ហើយបានត្រឡប់មកវិញ។ ម្ដងនោះ ពេលគាត់បានត្រឡប់មកផ្ទះរបស់គាត់វិញ នោះគាត់បានភ្ញាក់ផ្អើល តែពេលគាត់ដឹងថាសម្លេងនោះជាឪពុករបស់គាត់ នោះគាត់ក៏សប្បាយចិត្ត។

6) ពីព្រោះពួកគេមិនមែនជាផ្នែកល្អមួយនៃក្រុមជំនុំរបស់ព្រះគ្រីស្ទ រូបកាយរបស់ទ្រង់ នោះពួកគេច្របូកច្របល់។ ប្រសិនបើពួកគេធ្វើជាតួអង្គនៃរូបកាយរបស់ព្រះគ្រីស្ទយ៉ាងត្រឹមត្រូវ នោះកាលណាដែលក្បាលនៃរូបកាយមកទីនោះ នោះពួកគេនឹងមិនត្រូវច្របូកច្របល់នោះឡើយ។

## ការអធិប្បាយ 9 ការបីយ៉ាងដែលមកតាមក្រោយការបៀតបៀនរបស់ហេរ៉ូឌ (ម៉ាថាយ 2:1-23)

ដ្បិតស្ដេចហេរ៉ូឌដ៏អស្ចារ្យជាស្ដេចដែលអាក្រក់ គាត់សម្លាប់កូនក្មេងដោយងាយៗ។ ដូច្នេះ មានសុភាសិតមួយថា សុខចិត្តធ្វើជាជ្រូកជាជាងដែលធ្វើជាកូនរបស់ហេរ៉ូឌ។

កាលដែលហេរ៉ូឌបានស្តាប់ពីដំណឹងនៃកំណើតរបស់ព្រះយេស៊ូវដោយត្រចៀកផ្ទាល់ គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយបានរៀបគម្រោងសម្លាប់ទ្រង់។ ដោយសារហេតុនោះ មានការបីបានកើតឡើង។

1. ហេរ៉ូឌ និងអ្នកប្រាជ្ញ (1-12)

អ្នកប្រាជ្ញមានភាពក្លាហានតាមទំនាយដោយប្រៀបធៀបនឹងពួកគ្រូខាងច្បាប់ និងសង្ឃនៅគ្រានោះ។ រួចមក សម្តេចសង្ឃ និងពួកគ្រូច្បាប់ត្រូវបានពុករលួយ ហើយបានក្លាយជាអ្នកបម្រើរបស់ហេរ៉ូឌជាមនុស្ស ដែលកាន់សាសនាដ៏អាក្រក់ម្នាក់(4, 5)។

ពួកគេបានប្រមាថដល់មនុស្សដែលជឿសាសនាកាលដែលបោះនូវរបស់បរិសុទ្ធទៅដល់ឆ្កែ ហើយត្បូងទៅកាន់ជ្រូក ហើយពួកគេជាដៃគូរដ៏ល្អដែលចូលរួមនៅក្នុងទូកជាមួយនឹងពូជរបស់អេសាវដែលពុករលួយ ជាហេរ៉ូឌ។ ដោយសង្ខេប ពួកគេជាឧបករណ៍ហិង្សាដែលបានប្រើរួចដែលទាស់នឹងសេចក្តីពិតរបស់ព្រះ។ តែមនុស្សដែលមានប្រាជ្ញានឹងបានស្តាប់ទៅកាន់ព្រះបន្ទូលទំនាយរបស់បាឡាម ដូចជាពាក្យរបស់បាឡាម ជាហោរាពីទិសខាងកើត ដែលពួកគេបានរំពឹងថាផ្កាយមួយនឹងកើតឡើងនៅក្នុងទឹកដីយូដា។ ពួកគេបានគិតពីសេចក្តីពិតយ៉ាងម៉ឺងម៉ាត់។ កាលដែលពួកគេទន្ទឹងរង់ចាំនូវសេចក្តីពិត ពួកគេក៏បានឃើញផ្កាយ ហើយបានសម្រេចចិត្តភ្លាមទៅកាន់ជាតិសាសន៍ដែលនៅឆ្ងាយនោះ ជាស្រុកយូដា ហើយពួកគេបានមកដល់បេថ្លេហិមដោយមានការលះបង់ជាច្រើន។ នេះជាគំនិតមួយដែលក្លាហានរបស់ហោរា។ ពួកគេបានមកបេថ្លេហិម ហើយបានថ្វាយបង្គំទៅកាន់ព្រះឱរសយេស៊ូវ ហើយកាលដែលពួកគេត្រឡប់ទៅកាន់ជាតិសាសន៍របស់ពួកគេវិញ នោះជំនួសដោយពួកគេបានចង់ចាំពីការ

សន្យារបស់ពួកគេជាមួយនឹងស្តេចហេរ៉ូឌ ក៏ពួកគេមិនបានត្រឡប់ទៅជួបហេរ៉ូឌទេ ហើយពួកគេបានត្រឡប់ទៅកាន់ជាតិសាសន៍របស់ពួកគេតាមផ្លូវមួយផ្សេងទៀត។ ពីព្រោះពួកគេបានដឹងដោយសារការចង្អុលបង្ហាញនៃសុបិនរបស់ពួកគេ ហើយមិនបានត្រឡប់មកហេរ៉ូឌវិញទេ។ នេះជាភាពក្លាហានរបស់ហោរាដែលស្តាប់បង្គាប់ព្រះជាងការស្តាប់ព្រះបន្ទូលរបស់ស្តេចនៃជាតិសាសន៍មួយ។ តាមដែលយើងសង្កេតនូវការកត់ត្រានេះ យើងបានឆ្លងកាត់នូវការទាំងនេះដោយមិនយកចិត្តទុកដាក់។ តែជាការធម្មតាទេ ដែលមនុស្សស្តាប់តែទៅកាន់ពាក្យអាចាមអារ៉ាមរបស់ស្តេចនៅក្នុងជាតិសាសន៍មួយ យើងភ័យខ្លាច ពួកគេគិតថាវាជារឿងធម្មតាដែលត្រូវស្តាប់បង្គាប់ព្រះដោយការសម្រេចចិត្តនៃសេចក្តីស្លាប់ តែការបដិសេធនូវពាក្យរបស់ស្តេចដ៏អស្ចារ្យហេរ៉ូឌ។ នេះជាគម្រូដ៏ស្រស់ស្អាតដែលពួកបរិសុទ្ធនៃសាសន៍ដទៃបានបង្ហាញមក។

2. អំពីការភៀសខ្លួនដែលយ៉ូសែបបាននាំទារកមក (13-15)

ព្រះទ្រង់បានដឹកនាំឱ្យបានគេចខ្លួនទៅប្រទេសអេស៊ីបជាមួយនឹងទារក និងមាតារបស់ទ្រង់ប្រាប់ដល់យ៉ូសែបនៅក្នុងយល់សប្តិ។ យ៉ូសែបបានសម្រេចចិត្តស្តាប់បង្គាប់តាមការចង្អុលបង្ហាញរបស់ព្រះទាំងស្រុង ហើយបានធ្វើការភៀសខ្លួនទៅប្រទេសអេស៊ីប។ ការសម្រេចចិត្តដូច្នេះជាការងាយស្រួល។ កាលដែលយើងមើលទៅកាន់ទង្វើរបស់យ៉ូសែប យើងអាចដឹងបានថាគាត់បានស្តាប់បង្គាប់របស់ព្រះប៉ុណ្ណា។ នៅសម័យបុរាណឪពុកម្តាយរបស់ម៉ូសេបានដឹងថាម៉ូសេជាទារកម្នាក់ដែលពិសេសដែលត្រូវបានបញ្ជូនមកពីព្រះ។ ហើយគាត់ត្រូវបានបោះចោលទៅក្នុងវាលកក់។ តែយ៉ូសែបវិញបានទទួលយកព្រះឱរសយេស៊ូវ ហើយបានភៀសខ្លួនទៅប្រទេសអេស៊ីបដែលនៅឆ្ងាយ។ ហើយនៅត្រង់ចំណុចនេះ កាលដែលយើងគិតពិព្រឹត្តិការណ៍នេះ ព្រះយេស៊ូវត្រូវរកទុក្ខត្រូវ

បានបង្ហាញជាមួយបែបទៀត។ គឺវាជាជីវិតដែលតែងតែភៀសខ្លួននៅក្នុងគ្រាដែលទ្រង់នៅក្មេងនៅឡើយ។ ជីវិតដែលភៀសខ្លួនគឺមិនមែនជាការរស់នៅក្នុងស្រុកកំណើតរបស់ខ្លួននោះទេ តែត្រូវបាននិរទេសវិញ ដែលវាជាជីវិតនៃការជាប់គុក ជាជីវិតដ៏វេទនា គឺដើម្បីនឹងរក្សានូវជីវិត។

3. ពីព្រឹត្តិការណ៍ដែលទារកនៅភូមិបេថ្លេហិមដែលមានអាយុក្រោមពីរឆ្នាំត្រូវគេសម្លាប់ (16-18)

យើងគួរតែគិតពីក្មេងៗដែលបានស្លាប់ដោយលម្អិត។ ហេតុអ្វីបានជាពួកគេត្រូវបានសម្លាប់? ពួកគេត្រូវបានសម្លាប់យ៉ាងឃោឃៅគឺដោយសារតែហេតុការរបស់ព្រះយេស៊ូវ។ យើងនឹងពិចារណានូវការមួយចំនួនពីការនេះ។

1) ការដែលគ្មានបាប (អំពើបាបដើម) ដែលត្រូវបានសម្លាប់ នោះពួកគេត្រូវបានគេសម្លាប់។
2) ពួកគេត្រូវបានសម្លាប់ដោយឃោរឃៅដោយសារហេរ៉ូឌ និងភាពឆោទល្ងង់របស់ទ្រង់។ បើទោះជាយើងអាចគិតថា ការដែលត្រូវស្លាប់នៅវាដូចតែគ្នាទេ គឺវាគ្រាន់តែជារឿងមួយដែលគួរឱ្យទួញសោកជាងដែលត្រូវគេសម្លាប់យ៉ាងឃោឃៅនោះ។

អំពីការស្លាប់ដែលទារកទាំងនេះត្រូវបានគេសម្លាប់ យើងដែលជាអ្នកជឿគួរតែគិតអំពីរឿងមួយចំនួន។ គឺថាប្រសិនបើទារកទាំងនោះបានជួបនូវការសម្លាប់មួយយ៉ាងវេទនានោះមនុស្សពេញវ័យបានជួបសេចក្ដីស្លាប់សម្រាប់ព្រះជាម្ចាស់ ហេតុអ្វីបានជាវាបាន

ជាការមួយដែលគួរឱ្យទួញសោកនោះ? ប្រសិនបើទារកត្រូវស្លាប់ តើមានអ្វីដែលយើងមិនអាចធ្វើបាន?

យើងគួរតែគិតអំពីពាក្យនេះជានិច្ចទុកជាសុភាសិតរបស់យើង។ គឺថា "ប្រសិនបើទារកបានស្លាប់ មានអ្វីទៀតដែលយើងមិនអាចស្លាប់នោះ?"

ការអធិប្បាយ 10 **ព្រះយេស៊ូវបានយាងទៅកាន់ក្រុងយេរូសាឡិមកាលទ្រង់មានព្រះជន្ម ១២ វស្សា** (លូកា 2:41-51)

យើងពិបាកនឹងដឹងពីសកម្មភាពដែលព្រះយេស៊ូវទ្រង់បានធ្វើមុនទ្រង់មានព្រះជន្ម 12 វស្សាណាស់ ដ្បិតព្រះគម្ពីរមិនបាននិយាយទេ។ កាលទ្រង់បានព្រះជន្ម 12 វស្សា កូនចៅរបស់សាសន៍យូដាបានក្លាយជាមនុស្សដែលមានទំនួលខុសត្រូវនៅចំពោះក្រិត្យវិន័យ គឺត្រូវចូលរួមនៅក្នុងការរក្សានូវពិធីបុណ្យទាំងអស់។ ដូច្នេះ បន្ទាប់ពីព្រះយេស៊ូវត្រូវបានថ្វាយនៅព្រះវិហារបន្ទាប់ពីទ្រង់ប្រសូត្រមកនោះ វាជាព្រឹត្តិការណ៍ទីមួយដែលទ្រង់ឡើងទៅកាន់ព្រះវិហារម្តងទៀត។ អ្នកនិពន្ធដែលសរសេរបទគម្ពីរមិនមានគោលបំណងក្នុងការសរសេរគ្រប់ការទាំងអស់នៃជីវិតផ្ទាល់ខ្លួនរបស់ទ្រង់នោះទេ តែផ្តោតតែលើជីវិតសារធារណៈរបស់ទ្រង់ប៉ុណ្ណោះ។ ដូច្នេះ ភាពស្ងៀមស្ងាត់របស់បទគម្ពីរអំពីការមុនដែលទ្រង់បានព្រះជន្ម 12 វស្សាគឺមានហេតុផលនេះ។ យើងគិតពីសកម្មភាពរបស់ព្រះយេស៊ូវដែលទ្រង់បានយាងទៅកាន់ក្រុងយេរូសាឡិមនៅពេលទ្រង់មានព្រះជន្ម 12 វស្សា។

2. ពីការពិតដែលឪពុកម្តាយរបស់ព្រះយេស៊ូវបានបាត់ទ្រង់ (43-45)

ហេតុផលដែលពួកគេបានបាត់ព្រះយេស៊ូវគឺ ដោយសារពួកគេធ្វេសប្រហែសនឹងទ្រង់។ កាលណាដែលយើងធ្វេសប្រហែល នោះយើងនឹងបរាជ័យដដែលៗ។ លោក ជេអែម អូលសុន បាននិយាយពីមនុស្សធ្វេសប្រហែសដូចតទៅនេះ។

"ដឹងថាអ្នកឈ្មោះអ្វីទេ? ខ្ញុំអាចនឹងត្រូវដាក់ទោសដោយសារទង្វើខុសឆ្គងរបស់ខ្ញុំ។ ប៉ុន្តែដោយសារខ្ញុំ នោះជីវិតរបស់មនុស្សជាច្រើនត្រូវបានបំផ្លាញ រថភ្លើងត្រូវបានក្រឡាប់ កប៉ាល់ក៏ត្រូវលិចទៅ ទីក្រុងក៏ត្រូវឆេះអស់ ហើយការធ្វើសឹកក៏ត្រូវបរាជ័យ រដ្ឋាភិបាលក៏ត្រូវបំផ្លាញ។ បើទោះជាខ្ញុំមិនបានវាយខ្លាំង និងនិយាយពាក្យអាក្រក់ក៏ដោយ នោះគ្រួសារក៏ត្រូវបែកបាក់សម្រាប់ខ្ញុំ។ មិត្តរបស់ខ្ញុំក៏លែងអើពើ សម្លេងក្មេងសើចក៏ត្រូវបានបញ្ចប់ទៅ ហើយភរិយានៃគ្រួសារក៏បានបង្ហូរទឹកភ្នែកធ្លាក់ចុះមកដោយឈឺចាប់។ បងប្អូនប្រុសស្រីក៏ត្រូវបានភ្លេច ហើយក៏រស់នៅឆ្ងាយទៀត រហូតដល់ឪពុកម្តាយចូលមឈ្យូស ទើបចិត្តរបស់ពួកគេត្រូវលំបាក។ ខ្ញុំមិនបានមានគម្រោងធ្វើអាក្រក់ទេ។ ប៉ុន្តែសម្រាប់ខ្ញុំ ការដែលមានជំនាញល្អគឺគ្មានន័យអ្វីទាំងអស់ ទង្វើសុភាពរាបសារ និងភាពសប្បុរសត្រូវបានរលាយបាត់ទៅ ការសន្យានៃជ័យជំនះបានត្រឡប់ទៅជាការទួញសោក និងការបរាជ័យវិញ។ ខ្ញុំគ្មានពន្លឺទេលើកលែងតែងងឹត ហើយគ្មានសម្លេងអ្វីទាំងអស់លើកលែងតែភាពស្ងាត់ជ្រងំ។ អ្នកអាចនឹងមិនហៅឈ្មោះខ្ញុំត្រង់ៗទេ។ តែអ្នកស្និតស្នាលនឹងខ្ញុំដោយផ្ទាល់ផង។ ឈ្មោះរបស់ខ្ញុំគឺអ្នកដែលធ្វេសប្រហែស។" ប្រសិនបើឪពុកម្តាយរបស់ព្រះយេស៊ូវស្វែងរកទ្រង់ដោយបន្ទាបខ្លួន នោះពួកគេនឹងមិនបានបាត់ទ្រង់នោះទេ។ យើងចាត់ទុកព្រះយេស៊ូវដោយធ្វេសប្រហែស។ បើទោះជាយើងអាចចាំពីរឿងផ្សេងទៀតយ៉ាងល្អ តែយើងមិនបានប្រយ័ត្ននឹងការពិត

ដូចជាព្រះយេស៊ូវទ្រង់គង់នៅជាមួយខ្ញុំនៅពេលនេះ ហើយដែលមិនខ្វល់ខ្វាយពីព្រះយេស៊ូវសោះ។ យើងគួរតែប្រឆាំងនឹងអំពើបាបរហូតដល់ស្រក់ឈាមមក ក្នុងពេលតែមួយយើងគួរតែដកចេញពីអាកប្បកិរិយាដែលធ្វេសប្រហែសចេញ។ មានមនុស្សអស្ចារ្យម្នាក់បាននិយាយថា “មានមនុស្សជាច្រើនយកឡាននៃសេចក្តីសង្គ្រោះ តែពួកគេបានយកនូវឡានអាក្រក់វិញ។” ពិតណាស់ ក្រុមជំនុំបច្ចុប្បន្នជឿលើព្រះគ្រីស្ទ ហើយបានយកឡាននៃសេចក្តីសង្គ្រោះ តែពួកគេបានព្រងើយនឹងព្រះគ្រីស្ទ ហើយមនុស្សជាច្រើនបានងោកងុយ និងដេកលក់។

1. តើពួកគេបានរកឃើញព្រះយេស៊ូវដែលបាត់នោះនៅទីណា??

ឪពុកម្តាយរបស់ព្រះយេស៊ូវបានទៅព្រះវិហាររកទ្រង់ ពួកគេក៏បានឃើញទ្រង់នៅក្នុងព្រះវិហារ។ ព្រះវិហារជាកន្លែងប្រកាសព្រះបន្ទូលរបស់ព្រះ។ និងជាកន្លែងថ្វាយនូវការអធិស្ឋានទៅកាន់ព្រះ។ ការស្តាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះគឺដើម្បីនឹងបានស្គាល់ព្រះថែមទៀត ការអធិស្ឋានទៅកាន់ព្រះត្រូវបានស្គាល់ថាជាវិធីដើម្បីជួបនឹងព្រះ។ ព្រះវិហារនេះជាក្រុមជំនុំនៅគ្រាសញ្ញាថ្មី។ ក្រុមជំនុំពិតប្រាកដរក្សានូវព្រះបន្ទូលរបស់ព្រះពិតប្រាកដ និងកាន់ជាប់រហូតដល់ទីបញ្ចប់ ហើយក៏ស្វែងរកព្រះផងដែរ។ ក្រុមជំនុំតែងតែមាននូវអំណាចនៃជីវិតដែលពិសេសបែបនេះ។ លោក អាញស្តាញ បានសារភាពដូចតទៅថា “កាលដែលមានសង្គ្រាមនៅប្រទេសអាឡឺម៉ង់ នោះខ្ញុំត្រូវស្រឡាញ់សេរីភាព។ ខ្ញុំបានសម្លឹងមើលទៅសកលវិទ្យាល័យដើម្បីនឹងរក្សាវា។ ប៉ុន្តែសកលវិទ្យាល័យទាំងអស់ត្រូវបានទុកចោលស្ងាត់នៅក្រោមការគៀបសង្កត់នៃភាវរកម្ម។ ខ្ញុំបានមើលទៅកាន់អ្នកនិពន្ធដ៏អស្ចារ្យដើម្បីឱ្យសរសេរចុះសម្រាប់សេរីភាពរបស់អាឡឺម៉ង់។ ប៉ុន្តែពួកគេក៏ល្ងីល្ងើ។ ប៉ុន្តែខ្ញុំមើលឃើញតែព្រះវិហារប៉ុណ្ណោះដែលនៅឈរ

ដដែលនៅក្រោមការគៀបសង្កត់របស់អ៊ីត្លែ ឈរសម្រាប់សេចក្តីពិត។ ខ្ញុំជាមនុស្ស ដែលមិនចាប់អារម្មណ៍នឹងក្រុមជំនុំទេពីមុនមក តែពេលនេះខ្ញុំមិនអារម្មណ៍ថា ស្រឡាញ់និងកោតសរសើរដល់ក្រុមជំនុំវិញ។" ក្នុងគ្រាដែលក្រុមជំនុំត្រូវបានពុករលួយ នោះយើងមិនគិតទេថាមានមនុស្សអាចថ្វាយបង្គំនៅក្រុមជំនុំណាមួយនោះទេ។

នៅលើផែនដីនេះ គ្មានភាពបរិសុទ្ធទាំងស្រុងណានោះទេ ស្តង់ដារដែលយើងអាចគិតថា នៅក្នុងចិត្តដែលត្រឹមត្រូវ វាជាសេចក្តីពិតដែលមាននៅ។ ស្តង់ដានេះជាព្រះបន្ទូលរបស់ព្រះដែលព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីបង្រៀន។ ប្រសិនបើក្រុមជំនុំណាបង្រៀនព្រះបន្ទូលនេះ និងកាន់តាមយ៉ាងខ្លាំង និងប្រែចិត្តដោយស្មោះត្រង់ នោះនឹងធ្វើឱ្យពួកគេបានស្គាល់ព្រះយេស៊ូវពិតប្រាកដ និងស្វែងរកទ្រង់ផង។

មនុស្សដ៏អស្ចារ្យដែលនឹងទទួលព្រះពរពីព្រះនោះជាក្រុមជំនុំដែលតែងតែចូលមកក្នុងព្រះវិហារជានិច្ច។ លោក វ៉ាស៊ីនតោន មិនបានប្តេជ្ញានឹងរក្សាថ្ងៃព្រះអម្ចាស់ទេ។ អតិថិជនដែលមករកលោក វីលៀម ដែលជាមនុស្សដ៏អស្ចារ្យម្នាក់បានជួបគាត់នៅផ្ទះរបស់គាត់ ឬនៅព្រះវិហារ។

## ការអធិប្បាយ 11 ធ្វើនៅក្នុងសេចក្តីសុចរិត (លូកា 3:11-14)

1. ថ្មជំពប់ដើម្បីរក្សាសេចក្តីសុចរិតជាការសូកប៉ាន់

ទង្វើនៃការទទួលយកការសូកប៉ាន់ជាការដែលទុច្ចរិតដែលត្រូវលក់របស់សាធារណៈ ដើម្បីនឹងបំពេញនូវផលប្រយោជន៍ផ្ទាល់ខ្លួន វាធ្វើឱ្យប៉ះពាល់ដល់ទាំងសាធារណៈ និង ឯកជន។ ពីព្រោះសង្គមនឹងត្រូវបំផ្លាញ។ នៅសម័យបុរាណ ប្រទេសណាដែលត្រូវ បំផ្លាញគឺដោយមន្ត្រីពុករលួយ។ ដែលវានឹងត្រូវបំពេញដោយការលោភលន់ផ្ទាល់ខ្លួន ហើយផលប្រយោជន៍សាធារណៈនឹងត្រូវបានលក់ចេញទៅ នោះវានឹងត្រូវបំផ្លាញ។

2. ភាពជាមនុស្សត្រូវបានបិតបាំងដើម្បីនឹងរក្សាសេចក្តីសុចរិត

ទង្វើនៃការលក់ប្រយោជន៍សាធារណៈមិនមែនត្រឹមតែទាក់ទងនឹងការសូកប៉ាន់នោះទេ តែក៏ទាក់ទងនឹងភាពជាមនុស្សផងដែរ។ គឺថាពួកគេត្រូវបានទាញទៅកាន់ភាពជា មនុស្សដែលពួកគេមិនបានបង្កើតនូវផលប្រយោជន៍សាធារណៈ។ ប៉ុន្តែយើងមិនគួរ ត្រូវបានទាញដោយការដែលលក់ផលប្រយោជន៍សាធារណៈឡើយ។

ភាពជាមនុស្សជាធាតុដែលត្រូវការនៅក្នុងជីវិតនៃសេចក្តីស្រឡាញ់ តែនេះអាចជា រារាំងនៅក្នុងជីវិតនៃសេចក្តីសុចរិត។ កាលដែលយើងមានទំនោរទៅរកមនុស្សនិយម នោះយើងនឹងទៅជាខ្សោយ តែបើយើងមានទំនោរទៅរកសេចក្តីសុចរិត នោះយើងនឹង មានទំនោរទៅរកហិង្សា។ យើងមិនគួរមានទំនោរទៅរកភាពមនុស្សនិយមនៅក្នុងការ បម្រើដល់ក្រុមជំនុំនោះទេ។ ជីវិតដែលមានការប្រកបនឹងមនុស្សដែលខ្លួនស្រឡាញ់ មិនមែនជាជីវិតសាធារណៈរួចទៅហើយ។

3. លទ្ធផលនៃការបោះចោលនូវភាពយុត្តិធម៌

នៅក្នុងសម័យបុរាណ ជាតិសាសន៍ដែលបោះចោលនូវយុត្តិធម៌គឺត្រូវបានបំផ្លាញ។ ជាតិសាសន៍ដែលត្រូវបានបំផ្លាញដោយការគ្រប់គ្រងដោយសង្កត់សង្កឹនរបស់ស្តេច។ ទ្រង់បានសោយរាជ្យយ៉ាងទុច្ចរិតនៅលើរាស្រ្ត ដោយសងនូវអ្វីដែលទ្រង់បានធ្វើទៅលើទ្រង់វិញ។ លោក ឈុន ជូជុន បាននិយាយថា "វូតាំងបានធ្វើបាប លោក ហ្គើលជូ បានធ្វើបាបដោយសារភាពមនុស្សនិយម" (ស្តេចរបស់វូ និងស្តេចរបស់ថាងបានទម្លាក់កំហុសរបស់ខ្លួនមកលើខ្លួនវិញ តែស្តេចរបស់ហ្គើល និងស្តេចជូបានទម្លាក់កំហុសទាំងអស់ដល់អ្នកដទៃ) មិនត្រឹមតែ សាង ត្រូវបានបំផ្លាញដោយការទុច្ចរិតរបស់ជូនោះទេ។ ជូមិនបានសម្លឹងទៅមើលសេចក្តីសុចរិតរបស់មនុស្សសុចរិតនោះទេ ហើយមិនបានស្តាប់ទៅកាន់ការជំរុញរបស់ ប៊ីហ្គាន ហើយមានការដែលគាត់អះអាងដែលស្របនឹងមនុស្សដែលគ្មានកំហុសដែលមានរន្ធប្រាំពីរ ហើយបានសម្លាប់គាត់នឹងកាត់ចេញទៅ។

នៅក្នុងការគ្រប់គ្រងរបស់ភារកម្ម ចំណុចអាក្រក់នោះគឺជានយោបាយមិនល្អ ប្រព័ន្ធរបស់អ្នកជោគជ័យផ្ទាល់គឺទុច្ចរិតទៅហើយ។ បើទោះជាកូនចៅរបស់ស្តេចជាកូនដែលមិនមានតម្លៃក៏ដោយ ការដែលបង្កើតស្តេចនោះជាការទុច្ចរិត។

4. ការមិនត្រឹមត្រូវនៅក្នុងពិភពសាសនា

ការដែលមិនយុត្តិធម៌ត្រូវបានបង្ហាញជាច្រើននៅក្នុងពិភពនៃសាសនា។

1) មានមនុស្សជាច្រើនដែលខ្វល់តែពីផលប្រយោជន៍ផ្ទាល់ខ្លួន តែមិនខ្វល់ពីប្រយោជន៍សាធារណៈទេ។ បើទោះជាវាជាការល្អ បើទោះជាគាត់ផ្ទាល់បានចូលរួមមួយផ្នែក មានជាច្រើនដែលបានបែកចេញ។

2) នៅទីអធិប្បាយ គាត់មិននិយាយតែសេចក្តីពិតទេ តែជាពាក្យដែលបញ្ជោរដល់មនុស្សផងដែរ ដែលជាទង្វើពុករលួយដែលជាការកាត់ទោសនៃសេចក្តីពិត។

3) នៅទីអធិប្បាយ មានការមួយដែលវាយប្រហារដល់អត្តសញ្ញាណរបស់មនុស្ស ដែលចេញពីចិត្តដែលទុច្ចរិត ហើយវាមិនសាកសមនឹងប្រកាសសេចក្តីពិតទេ។ មានតែនៅទីអធិប្បាយប៉ុណ្ណោះដែលជាកន្លែងដែលត្រូវនិយាយពីគោលលិទ្ធិ។

4) អ្នកដឹកនាំ និងមនុស្សសាមញ្ញចូលចិត្តមនុស្សដូច្នោះ តែបដិសេធមនុស្សដែលស្តីបន្ទោសដោយសេចក្តីសប្បុរស ក្រុមជំនុំបច្ចុប្បន្នបានក្លាយជាក្រុមជំនុំដែលមិនមានឆ្អឹង។ ប្រទេសបានបដិសេធមនុស្សស្មោះត្រង់ ប្រទេសនោះនឹងត្រូវបំផ្លាញ ហើយក្រុមជំនុំស្តាប់នូវការស្តីបន្ទោសដែលល្អនោះនឹងត្រូវពុករលួយ។ តែម្តងទៀតយើងមានរឿងដែលត្រូវព្រមាន។ នោះគឺ មានមនុស្សដែលផ្តោតលើការស្តីបន្ទោស។ ដែលដើរតាមបែបសើចចំអក បែបឆ្កួត និងស្តីដោយខឹង។ តែនេះជាទង្វើរបស់អារក្សដែលធ្វើតាមផ្លូវល្អនៃការនាំឱ្យជឿ តែជំនួសដោយការនាំដោយវិធីខុសវិញ។ ការដែលនាំឱ្យជឿគឺត្រូវតែចេញពីសេចក្តីស្រឡាញ់ជាដំបូងបង្អោះ ហើយទីពីរ គឺដោយប្រាជ្ញា ទីបី គឺដោយការអធិស្ឋាន។

5) សេចក្តីទុច្ចរិតដែលគិតអាក្រក់ពីអ្នកដទៃ

6) មានការគិតអាក្រក់ពីអ្នកដទៃជាច្រើននៅក្នុងក្រុមជំនុំ។ គឺច្បាស់ណាស់ថាយើងគួរតែបញ្ឈប់នូវការគិតអាក្រក់ពីគេ។ បើទោះជាគេមានគំនិតខុសគ្នាពីខ្ញុំក៏ដោយក៏យើងមិនគួរមានគំនិតអាក្រក់ពីគេដែរ។ កាលដែលយើងនិយាយទៅកាន់អ្នកផ្សេងនោះយើងគួរតែនិយាយដោយពាក្យល្អ កាលដែលបញ្ចេញនូវពាក្យល្អៗ នោះយើងគួរតែនៅស្ងៀម។ ការដែលមានគំនិតមិនល្អពីអ្នកដទៃជាការទុច្ចរិត ហើយដែលទុកខ្លួនជាចៅក្រម។ យើងមិនគួរមានគំនិតមិនល្អពីគេ តែយើងគួរតែអធិស្ឋានសម្រាប់គេវិ

ញ។ កាលដែលយើងអធិស្ឋាន យើងមិនគួរអធិស្ឋានដោយមានគំនិតមិនល្អទៅកាន់អ្នកដទៃនោះទេ តែគួរតែប្រទានពរដល់គេវិញ។

**ការអធិប្បាយ 12 ពីការដែលព្រះយេស៊ូវទ្រង់ទទួលនូវការជ្រមុជទឹក (ម៉ាកុស 3:13-17, ម៉ាកុស 1:9-11, លូកា 3:21-22)**

កាលដែលព្រះយេស៊ូវទ្រង់ចង់ទទួលពិធីជ្រមុជទឹក និងទៅជួបយ៉ូហានបាប់ទីស្ទ នោះយ៉ូហានបាប់ទីស្ទបានបដិសេធ។ តែចុងក្រោយដោយផ្អែកលើព្រះបន្ទូលរបស់ព្រះយេស៊ូវ នោះគាត់ក៏ព្រមជ្រមុជទឹកឱ្យទ្រង់។ ពីការនេះ យើងត្រូវគិតពីការមួយចំនួន។

1. ឥរិយាបថរបស់ព្រះយេស៊ូវដែលទទួលពិធីជ្រមុចទឹកជាទង្វើរបស់អ្នកដែលផ្សះផ្សា ដែលនឹងធ្វើគ្រប់ការសុចរិតទាំងអស់ជំនួសអស់អ្នកជឿ។

ដូចដែលគ្រូព្យាយាមរៀនចេញពីសិស្ស នោះគឺហៅថាការបន្ទាបខ្លួន ដូចជាម្ចាស់ដែលបម្រើដល់អ្នកបម្រើខ្លួន នោះហៅថាជាការបន្ទាបខ្លួន។ តែព្រះអាទិករដ៏បរិសុទ្ធបំផុតចង់ទទួលនូវពិធីជ្រមុជទឹកពីមនុស្ស ដែលជាម្នាក់ក្នុងអ្នកមានបាប នោះជាការបន្ទាបខ្លួនមួយដែលមិនអាចនឹងថ្លែងប្រាប់បានវិញ។

គ្រប់ទាំងព័ន្ធកិច្ចដ៏ធំនឹងត្រូវបានអនុវត្តដោយឥរិយាបថបន្ទាបខ្លួនដូច្នេះ។ បុរសម្នាក់ឈ្មោះថា ហ្វ្រាន់សីស ចាបឺ បានអធិប្បាយព្រះបន្ទូលនៅទីក្រុងប្រទេសជប៉ុន មានបុរសម្នាក់បានមកកាន់គាត់ ហើយសុំចង់និយាយជាមួយគាត់ រួចមកក៏ស្តោះទឹកមាត់ដាក់មុខគាត់។ លោក ចាប៊ី មិនបានបង្ហាញអ្វីចេញនៅលើផ្ទៃមុខរបស់គាត់ទេ ហើយគាត់បានជូតមុខរបស់គាត់ដោយកន្សែងដៃ ហើយគាត់បន្តអធិប្បាយព្រះបន្ទូលទៀត។ ដោយសារហេតុការណ៍នោះមានមនុស្សជាច្រើនបានមានការកោតសរសើរដោយសារគាត់ ហើយមនុស្សជាច្រើនបានទទួលពិធីជ្រមុជទឹក។ លោក អេហ្វ ប៊ី មេយើរ បាននិយាយដូចតទៅថា “ខ្ញុំបានដឹងថាវត្តមាននៃព្រះគុណរបស់ព្រះត្រូវដាក់បង្ហាញនៅលើឆាកជាច្រើន។ ហើយកាលដែលខ្ញុំគិតថាកាលដែលកម្ពស់របស់យើងអាចនឹងត្រូវ

លើកបាន នោះខ្ញុំអាចយកពួកគេទៅកាន់ឆាកជាច្រើន។ តែក្រោយមកខ្ញុំក៏បានយល់ វត្តមានរបស់ព្រះគុណរបស់ព្រះគឺត្រូវបានដាក់នៅទីដែលទាបជាច្រើន។ ដូច្នេះដើម្បីទទួលបាននូវអំណោយទាំងនេះ ខ្ញុំមិនគួរត្រូវបានលើកឡើងទេ តែខ្ញុំគួរតែព្យាយាមអោនចុះ ហើយចុះទៅកាន់ទីខាងក្រោម។”

2. ការទទួលពិធីជ្រមុជទឹកដោយលោកយ៉ូហានបាប់ទីស្ទ ជាការប្រកបជាមួយនឹងមនុស្ស

ព្រះយេស៊ូវទ្រង់ជាស្តេចស្ថានសួគ៌។ តែទ្រង់បានយាងចុះមកលើលោកិយ ហើយបានធ្វើជាមិត្តដល់មនុស្សមានបាបដើម្បីនឹងសង្គ្រោះពួកគេ។ (បើទោះជាទ្រង់គ្មានបាបសោះក៏ដោយ) នេះជាវិធីប្រកាសដំណឹងល្អទៅកាន់មនុស្សមានបាប។ គ្រូបង្រៀនពិតជាអ្នកដែលចូលទៅក្នុងចិត្តរបស់សិស្សខ្លួន។ ព្រះយេស៊ូវមានបទពិសោធន៍នូវស្ថានភាពនោះ ទ្រង់បានជួយមនុស្ស និងបានដឹកនាំពួកគេ។ គ្រូគង្វាលដែលដើរតាមព្រះយេស៊ូវគួរតែធ្វើដូច្នោះផងដែរ។ គ្រូគង្វាលធំម្នាក់ លោក ចន ហ្វាវ៉េត បានបម្រើជាគ្រូគង្វាលនៅស្រុកតូចមួយឈ្មោះ យ៉កសាយ ដែលត្រូវបានហៅដោយក្រុមជំនុំមួយដែលលោកបណ្ឌិត ហ្គីល បានបម្រើ កាលដែលគាត់កំពុងចងវ៉ាលីធ្វើដំណើររបស់គាត់ ហើយព្យាយាមចាកចេញ នោះគ្រប់ក្រុមជំនុំទាំងអស់បានមកកាន់គាត់ ហើយពួកគេយំ ហើយខ្លាចគាត់ចាកចេញទៅ។ គ្រូគង្វាល ហ្វាវ៉េត និងប្រពន្ធរបស់គាត់ឃើញដូច្នោះ នោះបានប្តូរចិត្ត និងត្រឡប់មកបម្រើនៅក្រុមជំនុំតូចវិញនៅយ៉កសាយបន្តទៀត។ នេះជាលទ្ធផលដែលគ្រូគង្វាលទទួលបានអារម្មណ៍ពីស្ថានភាពរបស់ចៀមយ៉ាងជ្រាលជ្រៅ។ ប្រៀបដូចជាអ្នកគង្វាលល្អដែលមានការប្រកបយ៉ាងជិតស្និតជាមួយនឹងចៀមរបស់ខ្លួនដែលខ្លួនជាអ្នកគង្វាល។ មិនត្រឹមតែគ្រូគង្វាលទេ តែអ្នកជឿ

ទាំងអស់ដែលគួររស់នៅក្នុងជីវិតដែលមានការប្រកបគ្នាដែលត្រូវដឹងពីស្ថានភាពរបស់គ្នាយ៉ាងជ្រាលជ្រៅ។

3. ការពិតដែលព្រះយេស៊ូវទទួលការជ្រមុជទឹក ជាឥរិយាបថមួយនៃអ្នកផ្សះផ្សា ដែលបង្កើតគ្រប់ការសុចរិតទាំងជំនួសពួកជំនុំ

បើទោះជាទ្រង់មិនមានបាបក៏ដោយ ទ្រង់បានទទួលយកនូវឈ្មោះនៃមនុស្សមានបាប ហើយទ្រង់ធ្វើជាតំណាងជំនួសមនុស្សមានបាបទាំងអស់។ ទ្រង់ស្ថិតនៅជារបស់ក្រិត្យវិន័យ ហើយមានទំនួលខុសត្រូវសម្រេចគ្រប់ការទាមទារទាំងអស់របស់ក្រិត្យវិន័យ។ គ្រប់ទាំងសេចក្តីសុចរិតដែលទ្រង់ធ្វើនោះត្រូវបានប្រគល់មកដល់យើង។ ដូច្នេះ ទ្រង់ត្រូវរក្សាក្រិត្យវិន័យទាំងស្រុងសម្រាប់យើង។ បើគ្មានទ្រង់ទេ នោះយើងគ្មានសេចក្តីសុចរិតអស់កល្បជានិច្ច ហើយយើងមិនអាចមានផ្លូវទៅកាន់ជីវិតអស់កល្បជានិច្ច។ ដោយសារទ្រង់បានជំនួសយើង នោះគ្រប់ទាំងព្រះពររបស់ទ្រង់បានត្រឡប់មកកាន់យើង។ ការអាចកំកំបាំងដែលទ្រង់មានព្រះពរនោះសម្រាប់យើង គឺដោយសារទ្រង់ផ្ទាល់បានយាងមកនៅក្រោមក្រិត្យវិន័យ ទ្រង់ទទួលយកនូវភាពក្រីក្រទាំងអស់ និងការរងទុក្ខគ្រប់យ៉ាងសម្រាប់យើង ហើយទ្រង់បានសម្រេចគ្រប់ទាំងសេចក្តីសុចរិតទាំងស្រុង។ មានអ្នកបរិសុទ្ធម្នាក់និយាយដូចតទៅថា "ទ្រង់ដែលជានំប៉័ងជីវិតបានចាប់ផ្តើមកិច្ចការដោយឃ្លាន ទ្រង់ដែលជាទឹកជីវិតបានបញ្ចប់កិច្ចការរបស់ទ្រង់ដោយស្រេកទឹក។ ទ្រង់បានអត់ឃ្លានដូចជាមនុស្ស ហើយទ្រង់បានចម្អែតមនុស្សដែលស្រេកឃ្លានដូចជាព្រះទ្រង់បានធ្វើដែរ។ បើទោះជាទ្រង់អស់កម្លាំង នោះទ្រង់បានក្លាយជាទីសម្រាកដល់យើង ទ្រង់បានបង់ពន្ធ បើទោះជាទ្រង់ផ្ទាល់ជាស្តេចក៏ដោយ។ ទ្រង់ត្រូវគេស្តីបន្ទោសថាជាមនុស្សអារក្សចូលដោយនាមដែលស្មោកគ្រោក តែទ្រង់បាន

ដេញអារក្សចេញវិញ។ ទ្រង់ផ្ទាល់បានអធិស្ឋាន តែទ្រង់បានស្តាប់ទៅកាន់ការអធិស្ឋានរបស់មនុស្ស ទ្រង់បានព្រះកន្សែង តែទ្រង់នឹងជូតទឹកភ្នែករបស់យើងចេញ។ ទ្រង់ត្រូវបានលក់ក្នុងតម្លៃប្រាក់ 30 ដុំ តែទ្រង់បានលោះលោកិយនេះ។ ទ្រង់ត្រូវបានគេដឹកនាំទៅកាន់ទីមនុស្សស្លាប់ដូចជាចៀម តែទ្រង់ជាអ្នកគង្វាលដ៏ល្អ។ ទ្រង់បានសុគត តែការសុគតរបស់ទ្រង់បានសម្លាប់នូវសេចក្តីស្លាប់វិញ។"

**ការអធិប្បាយ 13 សិទ្ធិអំណាចនៃបទគម្ពីរ (ម៉ាថាយ 4:1-11)**

យើងអាចដឹងពីអាកប្បកិរិយារបស់ព្រះយេស៊ូវទៅចំពោះព្រះគម្ពីរនៅក្នុងអត្ថបទនេះ។ ព្រះយេស៊ូវទ្រង់ជ្រាបថា បទគម្ពីរជាព្រះបន្ទូលរបស់ព្រះ ហើយទ្រង់បានបណ្តេញអារក្សដោយសិទ្ធិអំណាចនៃព្រះបន្ទូល។

1. គោលលិទ្ធិនៃបទគម្ពីរអំពីព្រះគម្ពីរ

1) កាលដែលយើងឃើញព្រះគម្ពីរ ត្រូវបាននិយាយថាព្រះគម្ពីរជាសំបុត្រដែលត្រូវបានបើកសម្តែងមក។

ពាក្យថា ការបើកសម្តែងគឺ សេអូភ្នូថូស (θεόπνευστος) នៅក្នុងភាសាក្រិក នៅក្នុង ២ធីម៉ូថេ 3:16។ អត្ថន័យនៃពាក្យនេះគឺ "ផលិតផលនៃដង្ហើមដែលបង្កើតដែលចេញមកពីព្រះ"។ "ខ្យល់ដង្ហើមរបស់ព្រះ" ជានិមិត្តសញ្ញានៃអំណាចនៃព្រះដ៏មានព្រះចេស្តាទាំងអស់ (លោក ប៊ីប៊ី វ៉ហ្វីលដ៍ ថា ខ្យល់ដង្ហើមរបស់ព្រះគឺនៅក្នុងព្រះគម្ពីរ គឺ

ប្រៀបដូចជាអំណាចេស្តាដ៏អស្ចារ្យរបស់ទ្រង់។ – ការបើកសម្តែង និងសិទ្ធិអំណាចរបស់ព្រះគម្ពីរ ទំព័រ 133) ប្រៀបធៀបនៅ ទំនុកដំកើង 33:6។
ព្រះបន្ទូលខាងលើ ២ធីម៉ូថេ 3:16 មានបន្ទូលថា "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឱ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ។" (πασα γραφή θεόπνευστος) ពាក្យថា "គ្រប់ទាំងបទគម្ពីរ" មានបន្ទូលថា គោលបំណងរបស់ព្រះគម្ពីរ ឬផ្នែកនីមួយៗរបស់ព្រះគម្ពីរមានន័យដូចគ្នា។ (លោក ប៊ី ប៊ី វ៉ហ្វីលដ៍ ថា ការដែលនិយាយថាផ្នែកនីមួយៗនៃគម្ពីរបរិសុទ្ធនេះជាខ្យល់ដង្ហើមរបស់ព្រះ គឺជាចំណុចដែលសំខាន់តែមួយ។ សៀវភៅដដែលនៅទំព័រ 134)

2) ២ពេត្រុស 1:19-21 មានបន្ទូលថា "ហើយយើងខ្ញុំមានពាក្យទំនាយដ៏ពិតជាង ដែលគួរឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់តាម ដូចជាតាមចង្កៀងដែលភ្លឺក្នុងទីងងឹត ទាល់តែថ្ងៃភ្លឺឡើង ហើយផ្កាយព្រឹករះឡើងក្នុងចិត្តអ្នករាល់គ្នា។ ដោយដឹងសេចក្តីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ។ ដ្បិតសេចក្តីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ។" តើអ្វីជាកត្តាដែលជំរុញឱ្យគាត់និយាយពាក្យបែបនេះ? គឺត្រូវបានពន្យល់ដូចតទៅ។ នៅក្នុងការប្រកាសពីការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ គាត់បានណែនាំពីភស្តុតាងនៃសិរីល្អរបស់ព្រះជាម្ចាស់ថា គាត់បានឃើញនៅភ្នំនៃការផ្លាស់ប្រែ។ ដូច្នេះ គាត់ក៏និយាយថាព្រះបន្ទូលទំនាយគឺច្បាស់ជាងការដែលគាត់បានឃើញទៀតផង។ នៅទី

នេះ ពាក្យថា "ទំនាយ" គឺ ថន ផ្រូផេថេស លូហ្គូន (τόν προφήτεία γρφής) នៅក្នុងភាសាក្រិក ដែលគួរតែបកប្រែថា "ព្រះបន្ទូលនៃទំនាយ"។ ដ្បិត "ព្រះបន្ទូលនៃទំនាយ" មានតួអក្សរដែលចង្អុលទៅកាន់កណ្ឌគម្ពីរសញ្ញាចាស់ទាំងអស់ជាប្រព័ន្ធសាមញ្ញ។

ពាក្យខាងក្រោម (ខ 20) "ដោយដឹងសេចក្តីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ" (πάσα προφήτεία γρφής ) គាំទ្រការបកប្រែនេះយ៉ាងប្រាកដ។ លោកបណ្ឌិត វ៉ហ្វីលដ៍ ក៏បកប្រែខនេះដូចគ្នា។

(3) យ៉ូហាន 10:34-36 បានមានបន្ទូលថា "ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា តើគ្មានសេចក្តីចែងទុកមកក្នុងក្រឹត្យវិន័យរបស់អ្នករាល់គ្នាថា «អញបាននិយាយថា ឯងរាល់គ្នាជាព្រះ»ទេឬអី? ដូច្នេះ បើទ្រង់បានហៅអ្នកទាំងនោះជាព្រះ ដែលព្រះបន្ទូលរបស់ព្រះអង្គបានឮទៅដល់គេ ហើយបើលើកចោលបទគម្ពីរណាមិនបាន។ នោះតើអ្នករាល់គ្នានិយាយមកខ្ញុំនេះ ដែលព្រះវរបិតាញែកជាបរិសុទ្ធ ហើយចាត់មកក្នុងលោកីយ៍ ថា ខ្ញុំពោលពាក្យប្រមាថដល់ព្រះ ដោយព្រោះតែខ្ញុំនិយាយថា ខ្ញុំជាព្រះរាជបុត្រានៃព្រះដូច្នេះឬអី"។ នៅទីនេះ ឃ្លាដែលត្រូវបានដកស្រង់មកគឺមិនមែនជាសៀវភៅទាំងប្រាំកណ្ឌទេ តែជាព្រះបន្ទូលនៃ ទំនុកដំកើង 82:6 ហេតុអ្វីបានជាព្រះយេស៊ូវទ្រង់មានបន្ទូលថា "តើក្រិត្យវិន័យបានចែងមកដូចម្តេច?" ពីព្រោះព្រះយេស៊ូវនៅក្នុងទស្សនៈរបស់ពួកយូដាសម័យនោះ (យ៉ូហាន 12:34)ទ្រង់មានបន្ទូលថាសេចក្តីសរុបនៃក្រឹត្យវិន័យទាំងអស់ជាក្រឹត្យវិន័យ។ ដូច្នេះពាក្យ ទំនុកដំកើង 82:6, "អញបានពោលថា ឯងរាល់គ្នាសុទ្ធតែជាអ្នកមានអំណាច

ហើយជាកូននៃព្រះដ៏ខ្ពស់បំផុតទាំងអស់គ្នា” ចង្អុលទៅកាន់ព្រះបន្ទូលនៅក្នុងក្រឹត្យវិន័យ។ ប៉ុលក៏បានប្រើពាក្យនៅក្នុងក្រឹត្យវិន័យនៅក្នុងន័យដូចគ្នា។ គាត់បានដកស្រង់ពាក្យរបស់អេសាយ (១កូរិនថូស 14:21, រ៉ូម 3:19) ហើយបាននិយាយថា “គ្រប់យ៉ាងដែលក្រឹត្យវិន័យមានបន្ទូល”។

ព្រះយេស៊ូវទ្រង់មានបន្ទូលពីចំណងជើងនៃការនេះថា “ក្រឹត្យវិន័យ” ដូចជានៅក្នុងឧបន្ទាប់ ហេ ហ្គ្រាហ្វេ (ἡ γραφή) គឺ “គម្ពីរ”។ ពាក្យថា “គម្ពីរ” ជាចំណងជើងនៃបទគម្ពីរទាំងអស់។ ទ្រង់បានផ្អែកលើទស្សនៈពីការមិនអាចបំផ្លាញបាននៃបទគម្ពីរទាំងអស់ ដើម្បីនឹងការពារនូវសិទ្ធិអំណាចរបស់ខគម្ពីរ (ទូលបង្គំនិយាយថា ទ្រង់ជាព្រះ ជាព្រះរាជបុត្រារបស់ព្រះដ៏ខ្ពស់បំផុត)។ ដ្បិតទ្រង់មានការមិនអាចបំផ្លាញបាននៃបទគម្ពីរ នោះគ្រប់ផ្នែកនៃព្រះគម្ពីរមិនអាចត្រូវវិនាសឡើយ។ (បំផ្លាញមិនបាន) និងការដែលគ្មានកំហុស (គ្មានកំហុស)។ ឬ អ្នកខ្លះនិយាយថា ទស្សនៈរបស់ព្រះយេស៊ូវផ្ទាល់ទៅកាន់បទគម្ពីរមិនដូច្នេះទេ តែដើម្បីឱ្យស្របទៅនឹងទ្រឹស្តីនោះទ្រង់បានអនុញ្ញាតឱ្យយកទស្សនៈនៃបទគម្ពីរនៅក្នុងសាសន៍យូដា។ (Argumentum ad honinem) តែនេះជាពាក្យចចាមរាមដែលយល់ច្រឡំនូវចំណុចគោលរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវទ្រង់មានជំនឿលើ ការបើកសម្តែងទាំងស្រុង (គ្រប់តួអក្សរគឺជាការបើកសម្តែង) ដូចជាពាក្យខាងលើនៅក្នុងទស្សនៈនៃបទគម្ពីរ។ ព្រះយេស៊ូវទ្រង់បានគិតថាព្រះបន្ទូលរបស់បទគម្ពីរជាព្រះបន្ទូលដែលជាសិទ្ធិអំណាចយ៉ាងពេញលេញ ហើយនឹងត្រូវសម្រេចជាពិតប្រាកដ ដែលប្រាកដណាស់ថាទ្រង់ជឿលើការបើកសម្តែងទាំងស្រុងនៃបទគម្ពីរ។ ប្រៀបធៀបទៅ ម៉ាថាយ 4:7, 10, 11:10, 19:5, 21:13, 42,

22:29, 43, 26:31, 54, 56 ម៉ាកុស 9:12, 13, 12:10, 24, 14:27, 49 លូកា 4:17, 18, 24:25-27, 20:17, យ៉ូហាន 12:14, 15, 13:18, 17:12។

លោក វ៉ហ្វីលដ៍ បាននិយាយថា "អត្ថបទបទគម្ពីរទាំងនេះតែមួយគត់ដែលនឹងគ្រប់គ្រាន់ដែលធ្វើឱ្យយើងប្រាកដពីទីបន្ទាល់របស់ព្រះយេស៊ូវពីបទគម្ពីរ គឺនៅគ្រប់ផ្នែករបស់វា និងការប្រកាសដោយសិទ្ធិអំណាចមកពីព្រះផង។ – ការបើកសម្តែង និងសិទ្ធិអំណាចរបស់បទគម្ពីរ។ ទំព័រ 144)

(7) ពួកសាវក

[1] ពួកគេបានរៀបចំស្ថានភាពនៃដំណឹងល្អដោយលម្អិតនៅក្នុងលក្ខណៈវិនិច្ឆ័យរបស់ព្រះគម្ពីរ។ ប្រៀបធៀបនៅ កិច្ចការ 8:35, 17:2, 3, 11, 18:24, 28, 26:22 រ៉ូម 1:17, 3:4 10, 4:17, 11:26, 12:19, 14:11, ១កូរិនថូស 1:19, 2:9 3:19, 15:3, 4 កាឡាទី 3:10, 13, 4:22, 27 ១ពេត្រុស 1:16 , 2:6។

[2] ពួកគេបានពន្យល់ពីគោលការណ៍នៃជីវិតរបស់ពួកគេដោយបទគម្ពីរ។ យោងតាម រ៉ូម 8:36, 9:33, 11:8, 15:9, 21; ១ពេត្រុស 1:16, 2:6.

[3] ពួកគេបាននិយាយថា ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ។ យោងតាម ហេព្រើរ 3:7 (ទំនុកដំកើង 95:7) កិច្ចការ 8:36 9:33 11:8 15:9 21 ២កូរិនថូស 4:13

[4] កាលដែលពួកគេដកស្រង់បទគម្ពីរ ពួកគេនិយាយថា "ទ្រង់មានបន្ទូលថា" នេះជាវិធីនិយាយផ្ទាល់មាត់ដែលទទួលស្គាល់ថា ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះ។ យោងតាម ហេព្រើរ 1:5។

[5] ដូចជានៅក្នុងបទគម្ពីរត្រូវបានដកស្រង់មក វាមិនបង្ហាញពីអ្នកដែលនិយាយ ប៉ុន្តែបានដកស្រង់មកដោយនិយាយថា "បាននិយាយ" "ហើយគាត់បាននិយាយ" ដែល

ចង្អុលទៅកាន់បែបបទនៃការនិយាយដែលទទួលស្គាល់ការពិតថា អ្នកដែលមានបន្ទូលគឺជាព្រះ។ យោងតាម រ៉ូម 15:10, ១កូរិនថូស 6:16 ២កូរិនថូស 6:2 កាឡាទី 3:16, អេភេសូរ 4:8។ បែបនៃការនិយាយផ្ទាល់មាត់នេះត្រូវបានប្រើ នៅពេលអ្នកទស្សនៈវិទូបុរាណបានគិតថាព្រះរបស់ពួកគេមានសិទ្ធិអំណាច ហើយក៏ដកស្រង់វាមក។ ឧទាហរណ៍ ក្រុមរបស់ភីថាហ្គ័រ៉ាស់ បក្សពួករបស់ផ្លាតូ និងបក្សពួករបស់អារីស្តូត ជាដើមនៅក្នុងសម័យកណ្តាលដែលនៅក្នុងលំនាំដូចនេះ។

(8) ដំណោះស្រាយរបស់បញ្ហាលំបាកទៅកាន់គោលលិទ្ធិនៃការបើកសម្តែង

នៅក្នុងចំណោមការរិះគន់ដែលបំផ្លាញមួយចំនួន មនុស្សដែលមានការពិចារណាបានជឿលើការបើកសម្តែងយ៉ាងពេញលេញរបស់បទគម្ពីរនៅក្នុងគោលលិទ្ធិនៃការបើកសម្តែង។ ឧទាហរណ៍ ចាស់ទុំធំ លោក ហ្វារ៉ា លោកអូតូ ផ្លេដេ លោក ថូឡាក់ លោក ស្វាបហ្វ័រ ជាដើម ដែលស្ថិតនៅក្នុងក្រុមនេះ។ តែមានមនុស្សមួយចំនួនដែលគិតមិនល្អ និងភ្ជាប់ជាមួយនឹងទ្រឹស្តីដូចតទៅនេះ។

[1] ព្រះយេស៊ូវមិនបានជឿលើទ្រឹស្តីនៃការបើកសម្តែងទាំងស្រុង (គ្រប់តួអក្សរគឺត្រូវបានបើកសម្តែង) តែសិស្សរបស់ទ្រង់គ្រាន់តែធ្វើដូច្នេះ។ អ្នកដែលអះអាងនូវការនេះ គឺគ្រាន់តែយល់ច្រឡំពីព្រះបន្ទូលរបស់ព្រះយេស៊ូវប៉ុណ្ណោះ។ ពាក្យរបស់ពួកគេគឺដូចតទៅនេះ។ ម៉ាថាយ 5:18 មានបន្ទូលថា “បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើ១ ឬក្បៀស១នៅក្នុងក្រឹត្យវិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃ និងផែនដី បានកន្លងបាត់ទៅ គឺទាល់តែសេចក្តីទាំងអស់បានសំរេច ដោយសព្វគ្រប់” នៅទីនេះ ពាក្យថា យ៉ូថា អេន អេ មីអា ខេរ៉ាយអា (ἰώτα εν ἠ μία κεραια) មិនមែន

ជាតួអក្សរទេ តែជាក្រឹត្យវិន័យវិញ។ តែទ្រឹស្តីនេះត្រូវបានយល់ច្រឡំពីព្រះបន្ទូលរបស់ព្រះទាំងស្រុងវិញ។

ការពិតដែលព្រះយេស៊ូវដាក់នូវក្រឹត្យវិន័យអក្សរនៅក្នុងចិត្តរបស់ពួកគេយ៉ាងច្បាស់ពីព្រោះទ្រង់សម្គាល់នៅទីនេះ ដោយតួអក្សរថា " "។ ពាក្យ " " អង្គុលទៅកាន់តួអក្សរ យ៉ូដ ( ) ដែលជាតួអក្សរដ៏តូចបំផុតនៅក្នុងភាសាហេព្រើរ ហើយនីមួយៗគឺពិបាកនឹងបែងចែកពីគ្នាណាស់។ តួអក្សរនីមួយៗចង្អុលទៅកាន់ការកោងដូចជា រេស ( ) និង ដាលេថ ( ), ដ្បិតតួអក្សរទាំងពីរនេះខុសគ្នា តែស្រដៀងគ្នា ហើយអាចច្រឡំគ្នាផង។

ម៉ាថាយ 22:43,44 មានបន្ទូលថា "ទ្រង់មានព្រះបន្ទូលសួរទៀតថា ដូច្នេះ ធ្វើដូចម្តេចឱ្យហ្លួងដាវីឌមានព្រះបន្ទូល ដោយនូវព្រះវិញ្ញាណ ហៅទ្រង់ជាព្រះអម្ចាស់បាន ៤៤ ដោយថា «ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅព្រះអម្ចាស់នៃខ្ញុំថា ចូរឯងអង្គុយខាងស្តាំអញ ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯងនៅក្រោមជើងឯង" ហើយការិះគន់បាននិយាយថា កាលដែលយើងមើលទៅកាន់ពាក្យនេះ ព្រះយេស៊ូវបានដាក់សិទ្ធិអំណាចរបស់ដាវីដនៅក្នុងចិត្តរបស់ទ្រង់ពិត មិនមែនចង់អះអាងពីទំនុកដំកើងទេ (ទំនុកដំកើង 111 :) ដែលដាវីតសរសេរនោះគ្មានចំណុចខុសនោះទេ។.

ទ្រឹស្តីខាងលើគឺខុស។ ព្រះយេស៊ូវនៅទីនេះបានមានបន្ទូលពី សិទ្ធិអំណាចរបស់ដាវីតដែលដាក់នៅក្នុងចិត្តរបស់គាត់យ៉ាងច្បាស់។ គោលលិទ្ធិរបស់ព្រះយេស៊ូវ និងសិស្សរបស់ទ្រង់តែងតែហូតទៅរកប្រភពមួយនេះ។ យោងតាម យ៉ូហាន 16:12-15.

[2] ទ្រឹស្តីខុសដែល ទស្សនៈរបស់ពួកសាវកពីបទគម្ពីរមិនមែនជាគំនិតរបស់ពួកគេទេ តែជាអ្វីដែលទទួលបានមកនៅក្នុងទស្សនៈរបស់ពួកយូដាពីបទគម្ពីរ។ ទ្រឹស្តីនេះចាត់

ទុកពួកសាវកជាមនុស្សដែលមានអត្តចរិតដែលបន្ទូរបន្ថយ តែវាខុសសម្រាប់ពួកសាវកនូវអ្វីដែលព្រះគម្ពីរមានបន្ទូល។ មិនត្រឹមតែប៉ុណ្ណោះ ពួកសាវកបានបង្រៀនដោយវិជ្ជមាននូវគោលលិទ្ធិនៃការបើកសម្តែងទាំងស្រុងរបស់បទគម្ពីរ ដែលនោះគឺគោលលិទ្ធិនៃគ្រប់ទាំងតួអក្សរត្រូវបានបើកសម្តែង ហេតុអ្វីបានជានេះជាឥរិយាបថដែលទទួលបានមកនោះ? មានពេលមួយប៉ុលបានស្តីបន្ទោសពេត្រុសដោយគាត់បានបន្ទូរបន្ថយជាមួយនឹងសេចក្តីមិនពិត។ (កាឡាទី 2:11) ប៉ុលបាននិិយាយថា "ខ្ញុំបានត្រឡប់ដូចជាខ្សោយដល់ពួកអ្នកកំសោយ ដើម្បីឱ្យបានពួកកំសោយ គឺបានត្រឡប់ជាគ្រប់សណ្ឋានទាំងអស់ ដល់មនុស្សទាំងអស់ ប្រយោជន៍ឱ្យបានសង្គ្រោះដល់អ្នកខ្លះ ដោយសារសណ្ឋានទាំងនោះឯង ២៣ ខ្ញុំធ្វើការទាំងនោះ ដោយយល់ដល់តែដំណឹងល្អ ដើម្បីឱ្យខ្ញុំបានចំណែកជាមួយគ្នាក្នុងដំណឹងល្អ។"(១កូរិនថូស 9:22-23) ដើម្បីទទួលបានមនុស្សជាច្រើន បើសិនជាអាចទៅរួច។ វាមានន័យថានៅក្នុងចំណោមនោះ (ក្រុម) នៃសេចក្តីពិត នោះគាត់នឹងទទួលបានទម្លាប់របស់គាត់ផ្ទាល់ និងអ្នកផ្សេងទៀត។

[3] ទ្រឹស្តីដែលពួកសាវកយល់ឃើញពីបទគម្ពីរនេះគឺគ្រាន់តែជាទស្សនៈផ្ទាល់ខ្លួនប៉ុណ្ណោះដែលពួកគេបានយកមក ប៉ុន្តែវាមិនបានធ្វើជាគោលលិទ្ធិនៃសេចក្តីជំនឿឡើយ ។ នេះជាទ្រឹស្តីខុស។ អ្វីដែលជាលក្ខណៈវិនិច្ឆ័យពីទស្សនៈរបស់សាវកអំពីព្រះគម្ពីរគឺគ្រាន់តែជាការផ្លាស់ប្តូរលក្ខណៈដែលអាចបត់បែនប៉ុណ្ណោះ។ ដោយសារតែពួកសាវកបាននិយាយពី ភាពគ្មានកំហុសសោះនៃបទគម្ពីរយ៉ាងទូលំទូលាយ និងត្រង់ៗប្រសិនបើវាមិនមានលក្ខណៈគោលលទ្ធិនៃសេចក្តីពិតស្តង់ដារ តើវានឹងធ្វើអ្វីបាន?

[4] ទ្រឹស្តីដែលស្ថានភាពរបស់បទគម្ពីរដែលមិនគាំទ្រការបើកសម្តែងទាំងស្រុង (គ្រប់តួអក្សរត្រូវបានបើកសម្តែង)

នេះក៏ជាទ្រឹស្តីខុសដែរ។ នេះជាកំហុសមួយដែលវានិយាយថា គោលលទ្ធិនៃបទគម្ពីរគឺដោយសារមនុស្សដោយវិធីសាស្រ្តប្រឌិត។ មនុស្សមិនមែនជាស្តង់ដារនៃសេចក្តីពិតដោយសារអំណាចអ្វី ហើយប្រាជ្ញាអ្វីដែលអាចវាស់ស្ទង់បទគម្ពីរដ៏ជ្រៅនោះបានទេ? អ្វីដែលហាក់ដូចជាមានកំហុសខ្លះនៅក្នុងបទគម្ពីរគឺត្រូវដោះស្រាយតាមពិត ហើយនឹងត្រូវដោះស្រាយយ៉ាងប្រាកដ។ លោកបណ្ឌិត វ៉ហ្វីលដ៍ បាននិយាយដូចខាងក្រោម។ នោះគឺ "នៅពេលដែលយើងមិនអាចដោះស្រាយពាក្យសម្តីបានទេ នោះមិនត្រូវជួសវាទៅវិញទៅមកដោយសិប្បកម្មរបស់យើងទេ វាជាការល្អដែលយើងទុកវាឱ្យដូចនោះ។ ប៉ុន្តែយើងមិនគួរនិយាយថាវាមិនអាចទៅរួចទេក្នុងការចុះសម្រុងគ្នា។ អំណាចនៃការបកស្រាយរបស់យើង អំណាចនៃចំណេះដឹងរបស់យើង និងអំណាចនៃការយល់ដឹងរបស់យើង មិនមែនជាលក្ខណៈវិនិច្ឆ័យនៃការពិតនោះទេ»។

2. តើអ្វីជាទស្សនៈរបស់ក្រុមជំនុំពីបុរាណ?

វាគឺជាគ្រឹះដែលបង្កើតគោលលទ្ធិនៃបទគម្ពីររបស់ក្រុមជំនុំ។ ព្រះគ្រីស្ទ និងពួកសាវកមានគោលលទ្ធិនៃការបើកសម្តែងដោយពាក្យសំដីនៅក្នុងបទគម្ពីរ។ ការពិតនេះមិនត្រូវបានបដិសេធឡើយ សូម្បីតែអ្នកប្រាជ្ញគឺមិនឱ្យទទួលគោលលទ្ធិរបស់ក្រុមជំនុំទៅកាន់បទគម្ពីរឡើយ។ ធូលេក ហ្វារ៉ា សាន់ដេ រីម ឡូអីក ផូផ្លេដេ ជាដើម ហើយក៏មិនបដិសេធមួយនេះផងដែរ ជាពិសេសអ្នកវិទូដែលល្បី ដូចជា ហឺម៉ែន ស្កាល់ ក៏មិនបដិសេធវាដែរ ថែមទាំងចង្អុលទៅកាន់វាផង។

គំនិតជាក់លាក់មួយថា នៅពេលយើងបកស្រាយបទគម្ពីរខ្លះ ដើម្បីបង្រៀនពីការបើកសម្ដែងដោយពាក្យសំដីនៃបទគម្ពីរ នោះអាចធ្វើឱ្យយើងអះអាងពីការបើកសម្ដែងដោយពាក្យសំដីបាន។ ប៉ុន្តែខ្ញុំគិតខុស។ នៅពេលដែលពួកគេដកស្រង់បទគម្ពីរ ពួកគេបាននិយាយថា “ព្រះជាម្ចាស់មានបន្ទូល” ហើយអត្ថបទដែលបានដកស្រង់ទាំងអស់គឺជាព្រះបន្ទូលរបស់ព្រះ។ មិនត្រឹមតែប៉ុណ្ណោះ ពាក្យដែលបានដកស្រង់ពាក្យថា “វាត្រូវបានគេសរសេរ” ត្រូវបានគេគិតថាជាសិទ្ធិអំណាចបញ្ចប់ក្នុងការដោះស្រាយបញ្ហាលំបាកទាំងអស់និងការពិភាក្សា។ ដូច្នេះ ការពិតដែលការដកស្រង់គឺជាព្រះបន្ទូលរបស់ព្រះផ្ទាល់ត្រូវបានលាតត្រដាង។ ដូច្នេះ គោលលទ្ធិនៃលទ្ធិការគ្មានកំហុសសោះ គឺជាគោលលទ្ធិគ្រិស្ទានអូស្សូដក់។ លោកបណ្ឌិត វ៉ហ្វីលដ៍ បាននិយាយថា គោលលទ្ធិនៃការបើកសម្ដែងដោយពាក្យសំដីនៃបទគម្ពីរគឺជាគោលលទ្ធិរបស់ក្រុមជំនុំពីបទគម្ពីរ។ លោកបានសន្និដ្ឋានដូចតទៅគឺ “ក្រុមជំនុំបានជឿថា ព្រះគម្ពីរគឺជាសៀវភៅរបស់ព្រះ ដែលព្រះបានសរសេរ ហើយព្រះបន្ទូលនៅក្នុងនោះ ទោះជាវាជាពាក្យប្រភេទណាក៏ដោយ វាគឺជាសេចក្ដីពិត ដោយមិនមានការបរាជ័យ ហើយក្លាយជាពាក្យដែលមានអំណាច ដោយគ្មានការបរាជ័យ និង វាត្រូវបានគេជឿថាជាការពិតដែលថាព្រះបានសរសេរ។”

## 3. ទស្សនៈនៃបទគម្ពីរនៅគ្រារបស់បិតាក្រុមជំនុំ និងទស្សនៈរបស់អូហ្គាស្ទីន

គ្រិស្តបរិស័ទនៅសម័យបុព្វបុរសនៃក្រុមជំនុំ បានជឿថាគ្រប់ផ្នែកនៃបទគម្ពីរគឺជាព្រះបន្ទូលដែលជាការបើកសម្ដែងរបស់ព្រះ។ លោក ប៉ូលីខាប បានចាត់ទុកថាជាសម្លេងរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត ហើយអ្នកណាដែលគិតខុសចំពោះបទគម្ពីរ ត្រូវបានគេថ្កោលទោសថាជាកូនរបស់សាតាំង។ លោក អ៊ីរ៉ានៀស ដែលជាសិស្សរបស់ ប៉ូលី

ខាប បាននិយាយថា ព្រះគម្ពីរគឺមានសុវត្ថិភាពដោយសារវាត្រូវបានបើកសម្ដែងមក ដោយព្រះវិញ្ញាណបរិសុទ្ធ និងព្រះបន្ទូល។ លោក អូរីជេន ដែលជាសិស្សរបស់ ធីធូ លៀន (ធីធូលៀន គឺជាបុរសក្នុងវ័យដំណាលគ្នានឹងលោកអ៊ីរ៉ានៀស) បាននិយាយថា "ដោយសារតែអ្នកសរសេរដំណឹងល្អធ្វើការតាមរយៈព្រះវិញ្ញាណបរិសុទ្ធ វាមិនអាចទៅ រួចទេដែលឯកសាររបស់ពួកគេមានកំហុសណាមួយ" ។

លោក អូហ្គាស្ទុស បានកើតនៅគ.ស 354 ថ្ងៃទី13 ខែវិច្ឆិកា និងជាបិតាក្រុមជំនុំមួយ យ៉ាងអស្ចារ្យម្នាក់ គាត់ជាគ្រូបង្រៀនដែលបន្ទាបខ្លួនម្នាក់ដែលត្រូវបណ្ដាជនបង្ខំឱ្យធ្វើ ជាប៊ីស្ហប។ គាត់បានិយាយពីបទគម្ពីរដូចតទៅ: "បទគម្ពីរគឺល្អឥតខ្ចោះដែលមានសិទ្ធិ អំណាចរបស់ស្ថានសួគ៌យ៉ាងពិត" (សំបុត្រទៅកាន់ យេរ៉ូម 82) ហើយក៏បាននិយាយ ថា "អ្នកដែលអានបទគម្ពីរគួរតែអានដោយមានជំនឿ និងមានអារម្មណ៍ជឿជាក់" (សំបុត្រទៅកាន់ យេរ៉ូម 82)ហើយគ្រប់ពាក្យនៃបទគម្ពីរគួរតែទទួលបានសេចក្ដីពិត" ( សំបុត្រទៅកាន់ យេរ៉ូម) "ពិតណាស់សូម្បីតែម្នាក់នៅក្នុងចំណោមអ្នកនិពន្ធ នៅក្នុង ការសរសេរ នោះពួកគេមិនបានបង្កើតកំហុសសោះ"។ (សំបុត្រទៅកាន់ យេរ៉ូម), "អ្នក ដែលសង្ស័យថាការសរសេររបស់ពួកសាវក និងពួកហោរាមានកំហុស នោះជាបក្ស ពួករបស់មនុស្សទុច្ចរិត" (Warfield, Studies to Tertullian and Augustine, ទំព័រ 109)។ គាត់ចាត់ទុកគ្រប់ផ្នែកទាំងអស់នៃបទគម្ពីរមានសិទ្ធិអំណាចទាំងស្រុង។ អ្នក ដែលមិនទទួលពាក្យណាមួយនៅក្នុងបទគម្ពីរថាមានទាក់ទងគ្នាទៅនឹងព្រះគម្ពីរ ទាំងមូលនោះជាមនុស្សដែលមានគ្រោះថ្នាក់ (សំបុត្រ 40 ទៅកាន់យេរ៉ូម III 3)។

4. ទស្សនៈរបស់ពួកកំណែទម្រង់ និងក្រុមជំនុំផ្សាយដំណឹងល្អទៅកាន់បទគម្ពីរ

1) ការសារភាពសេចក្ដីជំនឿរបស់បារាំង គ.ស 1549 – លោក កាល់វីនភ្ជាប់នឹងការសរសេរនេះ។

ការសារភាពនេះនិយាយថា "ពាក្យដែលរាប់បញ្ចូលនៅក្នុងកណ្ឌគម្ពីរ (បទគម្ពីរនៅក្នុងសញ្ញាចាស់ និងសញ្ញាថ្មី) ចេញមកពីព្រះ។ យើងបានទទួលមកពីព្រះ តែមិនបានទទួលមកពីមនុស្សទេ។ វាមិនសាកសមដែលមនុស្សណា ឬទេវតាគួរបន្ថែម ឬដកចេញពាក្យណាមួយពីព្រះគម្ពីរនោះទេ (អត្ថបទទី ៥ បកប្រែដោយការពន្យល់របស់ខ្ញុំ) ។

2) ការសារភាពសេចក្ដីជំនឿនៅបែលជិក គ.ស 1561 – ការសារភាពរបស់អ្នកកាន់ទស្សនៈរបស់កាល់វីននៃក្រុមជំនុំជនជាតិដាច់។

អ្នកសរសេរសំខាន់ដែលបង្កើតការសារភាពនេះជាលោក ហ្គីដូ ឌេ ប្រ៊ី (គាត់ត្រូវបានគេសម្លាប់)។ ការសារភាពនិយាយដូច្នេះថា "យើងជឿលើគ្រប់កណ្ឌគម្ពីរទាំងនេះ (បទគម្ពីរ) ហើយទទួលយកជាបណ្ដុំកណ្ឌគម្ពីរតែមួយគត់ដែលត្រូវបានសរសេរចុះ។ ពាក្យនេះបានបញ្ជាក់នូវច្បាប់នៃសេចក្ដីជំនឿ និងគ្រឹះរបស់វា។ ហេតុផលដែលយើងទទួលកណ្ឌគម្ពីរទាំងនេះមិនមែនដោយសារការយល់ព្រមរបស់ក្រុមជំនុំទេ ប៉ុន្តែដោយព្រះវិញ្ញាណបរិសុទ្ធជាអង្គដែលប្រកាសវានៅក្នុងចិត្តរបស់យើង។ កណ្ឌគម្ពីរមានភស្តុតាងដែលថាពួកគេបានកើតមកពីព្រះ ហើយវាក៏មានភស្តុតាងថាជាព្រះបន្ទូលរបស់ព្រះផង។ យើងមិនអាចបន្ថែមពាក្យ ឬដកពាក្យចេញពីកណ្ឌគម្ពីរនោះឡើយ។"

3) ការសារភាពសេចក្ដីជំនឿរបស់ក្រុមជំនុំផ្សាយដំណឹងល្អសេរីរបស់អាល្លឺម៉ង់ គ.ស 1948

ការសារភាពនេះបានបង្ហាញពីទស្សនៈរបស់កាល់វីននៃស.វទី 19។ អត្ថបទទីមួយ និយាយថា "ដោយផ្នែក និងផ្នែកទាំងមូល បទគម្ពីរត្រូវបានបើកសម្តែងដោយព្រះវិញ្ញាណបរិសុទ្ធ។ ហើយបទគម្ពីរទាំងនេះជាស្តង់ដានៃជំនឿ និងជាព្រះបន្ទូលដែលគ្មានកំហុសទាល់តែសោះ។"

4) អត្ថបទក្រុមជំនុំកំណែទម្រង់នៃសាសនា គ.ស 1875

អត្ថបទទី 5 និយាយនៅក្នុងការសារភាពថា "គ្រប់ទាំងបទគម្ពីរត្រូវបានផ្តល់មកដោយការបើកសម្តែងរបស់ព្រះ អង្គបុគ្គលដ៏បរិសុទ្ធនៃព្រះ ទ្រង់មានបន្ទូលតាមការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះបទគម្ពីរជាព្រះបន្ទូលរបស់ព្រះ។ វាបានបង្ហាញនូវព្រះបន្ទូលរបស់ព្រះ ក៏ដូចជាថាវាជាព្រះបន្ទូលរបស់ព្រះនោះឯង។"

5) ការសារភាពសេចក្តីជំនឿរបស់ហេរីថិកទី២ គ.ស 1566 – ការសារភាពរបស់ក្រុមជំនុំស្វីងលី។ អត្ថបទទីមួយ នៅក្នុងការសារភាពនេះនិយាយថា "យើងជឿ និងសារភាពថា បទគម្ពីរត្រូវបានសរសេរដោយហោរា និងសាវក កណ្ឌគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីសុទ្ធតែជាព្រះបន្ទូលរបស់ព្រះ។ ព្រះផ្ទាល់មានបន្ទូលទៅកាន់ពួកបុព្វបុរសរបស់យើង ពួកហោរា និងពួកសាវក។ ពេលនេះ ទ្រង់ក៏ប្រាប់យើងតាមរយៈបទគម្ពីរ។"

4. គោលលិទ្ធិខុសឆ្គងអំពីបទគម្ពីរ

1) ទស្សនៈនៃទស្សនៈដែលប្រើហេតុផល

ទស្សនៈនេះព្យាយាមបែងចែកផ្នែកដែលត្រូវបានបើកសម្តែងរបស់បទគម្ពីរ ពីផ្នែកដែលមិនត្រូវបានបើកសម្តែង។ ទស្សនៈបែបនេះត្រូវបានណែនាំមកដោយ ពួកសូស៊ី

នៀន និងពួកជេស៊ីត។ គោលលិទ្ធិដែលខុសបែបនេះត្រូវបានអះអាងដោយទម្រង់បី។ ទីមួយ ផ្នែកដែលអាថ៌កំបាំងតែមួយគត់ (ផ្នែកដែលមិនអាចបកប្រែដោយប្រាជ្ញាមនុស្ស) ដែលត្រូវបានបើកសម្ដែង។ ទីពីរ ជាការអះអាងដែលថាបទគម្ពីត្រូវបានបើកសម្ដែងតែនៅក្នុងការបង្រៀនដែលជារបស់សេចក្ដីជំនឿ និងការប្រព្រឹត្ត (ការជឿជាការប្រព្រឹត្ត)។ ទីបី បទគម្ពីរត្រូវបានបើកសម្ដែងដោយតែគំនិត និងទស្សនៈប៉ុណ្ណោះ។ ការអះអាងដែលខុសឆ្គងទាំងនេះត្រូវបានចែកចាយនៅស.វទី 19 យ៉ាងខ្លាំងក្លា តែពួកគេមិនត្រូវបានសរសេរនៅក្នុងគោលជំនឿរបស់និកាយផ្សាយដំណឹងល្អទេ។

2) គោលលិទ្ធិខុសឆ្គងដែលទស្សនៈអាថ៌កំបាំងនិយាយពីបទគម្ពីរ

ពួកនេះអះអាងថាចិត្តរបស់អ្នកជឿអាចទទួលយកអ្វីដែលគេចង់ទទួលចេញពីបទគម្ពីរ ហើយអាចបោះចោលនូវអ្វីដែលគេចង់បោះចោល។ បន្ទាប់ពីលោក ស្លាយម៉ាឃើ គំនិតនេះបានចេញមកដូចជាទឹករលក។ តែគំនិតនេះមិនបានមកដល់គោលលិទ្ធិត្រឹមត្រូវពីបទគម្ពីរនៅក្នុងក្រុមជំនុំទេ។

**ការអធិប្បាយ 14 បទគម្ពីរជាព្រះបន្ទូលដែលគ្មានកំហុសសោះរបស់ព្រះ (ម៉ាថាយ 4:1-11)**

គោលសេចក្ដីជំនឿអត្ថបទទី 1 នៅក្នុងក្រុមជំនុំប្រេសប៊ីធារៀននៃប្រទេសកូរ៉េ និយាយថា "បទគម្ពីរនៅក្នុងសញ្ញាចាស់ និងសញ្ញាថ្មីជាព្រះបន្ទូលរបស់ព្រះ ហើយជាច្បាប់តែមួយគត់ដែលច្បាស់និងគ្មានកំហុសសម្រាប់ជំនឿ និងការប្រព្រឹត្ត។" ការសារភាពនេះបានផ្អែកលើគោលជំនឿដើមនៃការសារភាពសេចក្ដីជំនឿរបស់ប្រេសប៊ីធារៀនវ៉េសមីនស្ទើ។ ការសារភាពសេចក្ដីជំនឿវ៉េសមីនស្ទើត្រូវបានបង្កើតឡើងដោយសមាជិក 152 ដែលបានប្រមូលផ្ដុំគ្នាដំបូងនៅថ្ងៃទី12 ខែកក្កដា ឆ្នាំ 1649។ ទីកន្លែងប្រជុំនេះគឺនៅក្រុមជំនុំឆាបផលវ៉េសមីនស្ទើ ដែលមានសាសនវិទូ 121 នាក់ និងអ្នកជឿធម្មតា 30 នាក់។ នៅក្នុងចំណោមអ្នកជឿធម្មតា អ្នកវិទូក៏នៅទីនោះ។ អត្ថបទទីមួយនៃគោលជំនឿប្រេសប៊ីធារៀនរបស់យើងនៃជំពូកទី 1 អត្ថបទទី 1 នៅក្នុងគោលសេចក្ដីជំនឿវេសមីនស្ទើ យើងគួរតែរំលឹងពីគំនិតនៃអ្នកសាសនវិទូ ដែលបានចូលរួមនៅក្នុងការសរសេរគោលលិទ្ធិសេចក្ដីជំនឿដោយលម្អិតនោះ។

1) នៅក្នុងចំណោមសាសនវិទូដែលសរសេរគោលជំនឿនោះ លោក ចន បុលថ៍ ជាបុគ្គលដ៏អស្ចារ្យម្នាក់បាននិយាយថា ពីបទគម្ពីរ "ដែលត្រូវបានបើកសម្ដែងដោយផ្ទាល់" ដូចតទៅថា៖ "ត្រូបានបើកសម្ដែងដោយផ្ទាល់" ត្រូវបានបកប្រែថាជាព្រះបន្ទូលដែលមកពីព្រះដែលជាព្រះវរបិតាដោយផ្ទាល់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

បទគម្ពីរត្រូវបានបើកសម្តែងនៅក្នុងខ្លឹមសារ និងពាក្យពេចន៍ផង។” (Warfield, Westminster Assembly and Its Work 1931, p179)។

2) លោក វីលៀម ប្រីជ និយាយថា “ព្រះបន្ទូលរបស់ព្រះគឺច្បាស់លាស់ជាសម្លេងដែលពួកសាវ័កបានស្តាប់នៅលើភ្នំផង” (២ពេត្រុស 1:18)។ ការយល់ពីបទគម្ពីរជាដំបូង យើងមិនគួរកែតម្រូវតួអក្សររបស់បទគម្ពីរ។ ពាក្យ និងអត្ថន័យរបស់វាមិនគួរបែងចែកពីគ្នាទេ។ បើបំបែករូបកាយ នោះអ្នកដែលមានរូបកាយនឹងត្រូវបែកបាក់ដែរ។ ប្រសិនបើព្រះបន្ទូលរបស់ព្រះគម្ពីរត្រូវបានបំបែក នោះព្រះគម្ពីរនឹងត្រូវបំបែកដែរ។

3) លោក ចន វាយ បាននិយាយដូចតទៅថា “បទគម្ពីរជាព្រះបន្ទូលរបស់ព្រះ ហើយទ្រង់ប្រាប់យើងតាមរយៈព្រះបន្ទូលនេះ។ ដូច្នេះ យើងមិនអាចធ្វើអ្វីបានក្រៅពីត្រូវតែស្តាប់តាមព្រះបន្ទូលរបស់ព្រះ។ ប្រសិនបើយើងមានគម្ពីរនៅដៃរបស់យើង នោះយើងត្រូវឈរនៅចំពោះព្រះ។ កាលដែលយើងនិយាយពីអ្នកសរសេរគម្ពីរ ពួកគេជាពួកបរិសុទ្ធ ហើយបានទទួលការបើកសម្តែងដោយចេញពីចិត្តដោយព្រះវិញ្ញាណបរិសុទ្ធដោយគ្មានកំហុសសោះ ហើយត្រូវបានសរសេរចុះដោយគាត់ផង។ ព្រះវិញ្ញាណបរិសុទ្ធបានផ្តល់ដល់គេនូវសេចក្តីពិតនៃការបង្រៀន ក៏ដូចជាផ្តល់នូវពាក្យដែលត្រូវសរសេរ និងវិធីសាស្ត្ររបស់វា និងគ្រប់ប្រព័ន្ធនៃការសរសេរទាំងអស់។ ព្រះវិញ្ញាណបរិសុទ្ធធ្វើឱ្យអ្នកសរសេរយល់ព្រះបន្ទូលរបស់ព្រះ រួចក៏ទទួល និងសរសេរចុះផង” គាត់ក៏និយាយថា “អ្នកសរសេរបទគម្ពីរខុសពីម្នាក់ដែលប្តេជ្ញាដើរតាមអារក្សនោះទេ។ អ្នកដែលត្រូវបានដឹកនាំដោយអារក្សបានពឹងផ្អែកលើវិធីសាស្ត្រដូចជាព្រលឹងដែលចាកចេញពីខ្លួន ហើយប្រាប់ពីអ្វីដែលគេបានទទួលពីអារក្សមកដល់

មនុស្សដោយមិនបានទទួលវា។ តែអ្នកសរសេរព្រះបន្ទូលរបស់ព្រះយល់ព្រះបន្ទូលរបស់ព្រះ រួចទទួលនិងសរសេរវាចុះ។"

ហើយគាត់ក៏និយាយថា "អ្នកសរសេរព្រះគម្ពីរមិនខុសគ្នាពីអ្នកដែលបម្រើដល់អារក្សទេ។ អ្នកដែលបម្រើអារក្សតែងតែពឹងលើវិធិសាស្រ្តដូចជាព្រលឹងចាកចេញពីរូបកាយ ហើយទទួលបានអ្វីដែលប្រាប់មកដោយអារក្ស ហើយប្រាប់ទៅកាន់មនុស្សដែលមិនបានទទួលវា។ តែអ្នកសរសេរព្រះបន្ទូលរបស់ព្រះបានទទួលព្រះបន្ទូលដែលបើកសម្តែងមកនៅក្នុងពេលដឹងខ្លួន ហើយប្រកាសវាទៅមនុស្សដែលមានចិត្តស្តាប់បង្គាប់។ ព្រះវិញ្ញាណបរិសុទ្ធមិនត្រឹមតែថ្វាយនូវភាពពិតនៃការបង្រៀនដល់អ្នកដែលសរសេរនោះទេ តែទ្រង់ក៏ផ្តល់នូវពាក្យជាឯកសារសរសេររួចផងដែរ វិធីសាស្រ្តនោះ និងលំដាប់លំដោយនៃការរៀបចំរបស់វាផង។ វាមិនត្រូវបានប្រគល់ដល់អ្នកធ្វើការសាមញ្ញនោះទេ។

4) លោក ប៊ីហ្គេស និយាយដូចតទៅនេះថា៖ "គ្រប់ទាំងបទគម្ពីរត្រូវបានផ្តល់មកដោយការបើកសម្តែង ហើយគោលបំណងរបស់គាត់នោះគឺដើម្បីនឹងដឹកនាំយើងឱ្យផ្តោតលើព្រះគម្ពីរ ដូច្នេះយើងអាចនឹងមានអារម្មណ៍ទាក់ទងនឹងបទគម្ពីរ។ ប្រៀបដូចជាពេលកូនក្មេងនៅក្នុងផ្ទៃដែលត្រូវបានចិញ្ចឹមផ្តល់ជីវជាតិតាមរយៈទងផ្ចិត នោះក្រុមជំនុំរស់នៅក្នុងព្រះគ្រីស្ទតាមរយៈព្រះគម្ពីរ។" (Warfield, Westminster Assembly and his Work, 1931, p.289- draft version).

5) លោក អេដវើត ក្លាមី និយាយដូចតទៅនេះថា "ប្រាកដណាស់ថា បទគម្ពីរត្រូវបានបើកសម្តែងដោយព្រះវិញ្ញាណបរិសុទ្ធ។ បទគម្ពីរជាការសរសេរដែលដឹក

ជញ្ជូនចិត្តរបស់ព្រះ។ អ្នកបរិសុទ្ធពិតប្រាកដនឹងមានអារម្មណ៍ពីព្រះនាមរបស់ព្រះ សិទ្ធិអំណាចរបស់ទ្រង់ និងប្រាជ្ញារបស់ទ្រង់ សេចក្តីសប្បុរសទ្រង់ និងស្រឡាញ់ទ្រង់ ហើយក៏មានសេចក្តីអំណរផង។ ពីសំបុត្រនៃបទគម្ពីរ។ បទគម្ពីរជាសំបុត្រដែលផ្ញើដោយព្រះដែលគង់នៅស្ថានសួគ៌។ ដ្បិតអ្នកនិពន្ធនៃព្រះបន្ទូលរបស់ព្រះ នោះមានប្រាជ្ញាដែលគ្មានកំណត់ និងភាពរលូនដែលគ្មានដែនកំណត់។ សូម្បីតែពាក្យមួយម៉ាត់នៅក្នុងគម្ពីរក៏បើកសម្តែងពីព្រះដែរ។

6) គោលលិទ្ធិនៃការបើកសម្តែងនៅក្នុងគម្ពីរដោយលោក ឡៃហ្វុត

ឡៃហ្វុត បាននិយាយថា កណ្តាំនៃបទគម្ពីរផ្ទុកនូវការបើកសម្តែងរបស់ព្រះនៅក្នុងក្រុម និងខ្លឹមសារដែលលម្អិត។ គាត់និយាយដូចតទៅថា “ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះបើកសម្តែងដល់មនុស្សនៅសញ្ញាចាស់ និងបន្ទាប់មកគេសរសេរបំណងដែលទ្រង់បើកសម្តែងយ៉ាងពេញលេញ ហើយរួចមកទ្រង់ក៏បិទនូវការបើកសម្តែងដែលពិសេសដូចនោះមួយរយៈ។ បន្ទាប់ពីនោះមក នៅគ្រាសញ្ញាថ្មី ទ្រង់ធ្វើឱ្យគេសរសេរគម្ពីរសញ្ញាថ្មីតាមរយៈការបើកសម្តែង។ រួចមកទ្រង់ក៏បានហាមកិច្ចការនោះទាំងស្រុង។” (ការបកប្រែទីមួយ) យើងអាចរកឃើញចំណុចសំខាន់ៗដូចតទៅនៅក្នុងសៀវភៅរបស់លោក ឡៃហ្វុត។ [1] ព្រះគម្ពីរជាកំណត់ត្រានៃសេចក្តីពិតទាំងអស់ [2] គាត់សង្កត់ថា គ្រីស្ទានទាំងអស់មិនគួររំពឹងចង់បានការបើកសម្តែងណាទៀតក្រៅពីព្រះគម្ពីរនោះឡើយ។ [3] អ្នកសរសេរគម្ពីរជាភ្នាក់ងាររបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយកិច្ចការរបស់អ្នកសរសេរជាអង្គុលីរបស់ព្រះ [4]

**[សេចក្ដីបន្ថែម] ការការពារសេចក្ដីជំនឿរបស់លោកបណ្ឌិត ប៊ី ប៊ី វ័រហ្វីលដ៏ អំពីអ្នកដែលយល់ច្រឡំនូវគោលលិទ្ធិនៃការបើកសម្ដែង ដោយការសរសេរនៃក្រុមរបស់ការសារភាពរបស់វ៉េសមីនស្ទើរ។**

អ្នកដែលយល់ច្រឡំពីទស្សនៈរបស់ព្រះគម្ពីរ ដែលសមាជិកអង្គប្រជុំបានសរសេរនូវការសារភាពរបស់វ៉េសមីនស្ទើរបាននិយាយថា "ពួកគេមិនបានជឿលើគោលលិទ្ធិនៃទ្រឹស្ដីពីការបើកសម្ដែងផ្ទាល់មាត់ទេ។" ត្រង់ចំណុចនេះ គាត់បានយល់ច្រឡំឃ្លាខាងលើ ដែលអ្នកវិទូសមាជិកក្រុមវ៉េសមីនស្ទើរបាននិយាយហើយ។ ត្រង់ចំណុចនេះ អ្នកការពារសេចក្ដីជំនឿដ៏អស្ចារ្យចង្អុលទៅកាន់ការយល់ច្រឡំនេះ។

1. សំណេររបស់លោក ចន ប៉ល (សមាជិកដែលសរសេរការសារភាពរបស់វ៉េសមីនស្ទើរ)

"ទីបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធមិនផ្ដោតលើការចង្អុលទៅកាន់ឃ្លាមួយចំនួន និងពាក្យមួយចំនួននៅក្នុងព្រះគម្ពីរទេ។ ពួកគេគ្រាន់តែជាភាជនៈដែលទទួលនូវពន្លឺស្ថានសួគ៌ប៉ុណ្ណោះ។ បើទោះជាបន្ទាល់របស់ព្រះគម្ពីរនៅក្នុងការបកប្រែខ្លះ សេចក្ដីពិតនៃសេចក្ដីសង្គ្រោះរាប់បញ្ចូលក្នុងនោះនោះវាបានបោះជាប់នៅក្នុងចិត្តរបស់យើង។"

លោក បណ្ឌិត ប្រ៊ីក្ស និយាយពីពាក្យរបស់លោក ចន បល ខាងលើថា ទស្សនៈរបស់បទគម្ពីររបស់លោក ចន បល មិនមានទស្សនៈនៃការបើកសម្ដែងដោយសម្លេងរបស់

ព្រះគម្ពីរទេ។ តែលោកបណ្ឌិត វ័រហ្វីលដ៍ ចង្អុលទៅកាន់ការយល់ច្រឡំរបស់លោកបណ្ឌិតប្រីក្សពីឯកសាររបស់លោក ចន បល។ លោកបណ្ឌិត វ័រហ្វីលដ៍ បាននិយាយថា “គោលបំណងនៃសំណេររបស់លោក ចន បល មិនបានប្រឆាំងនឹងការពិតដែលថាបទគម្ពីរត្រូវបានបើកសម្ដែងមកដោយផ្ទាល់មាត់នោះទេ តែគាត់បានប្រឆាំងនឹងគំនិតតែមួយដែលថាវា (ការបើកសម្ដែងដោយផ្ទាល់មាត់) អាចបញ្ជាក់ដោយទីបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ។ លោក ចន បល គ្រាន់តែដើម្បីបញ្ជាក់ពីការពិតដែលថាបទគម្ពីរត្រូវបានបើកសម្ដែងដោយផ្ទាល់មាត់ នោះអាចនិយាយបានថាជាទីបន្ទាល់ដោយទីបន្ទាល់មួយទៀត តែគាត់មិនបានប្រឆាំងនឹងទស្សនៈនៃការបើកសម្ដែងដោយផ្ទាល់មាត់របស់ព្រះគម្ពីរនោះទេ។ លោក ចន បល បានបង្រៀនពីទស្សនៈនៃការបើកសម្ដែងផ្ទាល់មាត់របស់ព្រះគម្ពីរយ៉ាងច្បាស់។ គាត់បានសរសេរការពិតនៅក្នុងសៀវភៅសំណួរចម្លើយថា បទគម្ពីរត្រូវបានបើកសម្ដែងនៅក្នុងអត្ថបទដើម ទាំងសម្ភារៈនិងពាក្យក៏ត្រូវបានបើកសម្ដែងដែរ។”

2. សំណេររបស់លោក វីលៀម វីហ្វដ

“គ្រប់ភាសា និងគ្រប់តួអក្សរមិនមែនជាច្បាប់នៃជំនឿទេ តែជាឧបករណ៍ដែលបង្ហាញនូវច្បាប់ និងសញ្ញាសម្គាល់របស់វា និងព័ត៌មានរបស់វា។ វាជាវិធីសាស្ត្រដែលធ្វើឱ្យយើងបានដឹងសេចក្ដីពិតរបស់ព្រះ។ ឧបករណ៍នៃអត្ថបទព្រះគម្ពីរ និងគោលលិទ្ធិរបស់វាត្រូវបានផ្ដល់មកនៅក្នុងភាសាតែមួយគត់ដែលយើងអាចស្គាល់បាន។ ដូច្នេះខ្ញុំជឿថាការបកប្រែភាសាអង់គ្លេសជាច្បាប់ និងរង្វាស់រង្វាល់របស់ខ្ញុំ។ នៅពេលដែលខ្ញុំពឹងលើវា មិនមែនមានន័យថាជាសិទ្ធិអំណាចរបស់មនុស្សទេ តែជាសិទ្ធិអំណាច

របស់ព្រះវិញ។” លោកបណ្ឌិត ប្រីក្ស ក៏បានយល់ច្រឡំពាក្យខាងលើរបស់លោកវីហ្វត ដែលគាត់និយាយថា “វីហ្វដមិនបានជឿលើគោលលិទ្ធិនៃការបើកសម្តែងដោយផ្ទាល់មាត់របស់បទគម្ពីរទេ” តែលោក វ៉រហ្វីលដ៍ ផ្តល់ទស្សនៈពីបទគម្ពីររបស់លោកវីហ្វដយ៉ាងត្រឹមត្រូវ។ “នៅទីនេះ លោក វីហ្វដ មិនបានគិតពីគោលលិទ្ធិនៃការបើកសម្តែងផ្ទាល់មាត់របស់ព្រះគម្ពីរទេ តែគាត់គិតពីតម្លៃនៃបទគម្ពីរវិញ។ គាត់ឃើញថាសេចក្តីពិតនៃការបកប្រែបទគម្ពីរ និងអត្ថបទដើមគឺដូចគ្នា។ ហើយ លោក វីហ្វដ បានគិតអំពីចំណុចខុសៗគ្នារវាងបទគម្ពីរដើម និងបទគម្ពីរដែលបកប្រែរួច។ គឺថា បទគម្ពីរដើមបានប្រើភាសាដែលពេញលេញ ដោយគ្មានកំហុស ចំណែកការបកប្រែវិញមិនមានកំហុសទេនៅក្នុងចំណុចរវាងសេចក្តីពិតនៃបទគម្ពីរបកប្រែ និងសេចក្តីពិតនៃអត្ថបទដើម។ នេះមិនមែនជាពាក្យដែលប្រឆាំងនឹងទស្សនៈនៃការបើកសម្តែងផ្ទាល់មាត់របស់បទគម្ពីរទេ។”

3. ទ្រឹស្តីរបស់លោក ប្រីក្ស ដែលយល់ច្រឡំ លោក វីឆាត បាក់ស្ទើរ

លោក បាក់ស្ទើរ បាននិយាយដូចតទៅថា “បទគម្ពីរគឺដូចជាប្រព័ន្ធនៃមនុស្សដែរបើប្រៀបធៀបទៅ ផ្នែកខ្លះមាននៅដើម្បីនឹងការពារផ្នែកផ្សេងទៀត។ អត្ថន័យរបស់បទគម្ពីរប្រៀបដូចជាព្រលឹង តួអក្សរវិញប្រៀបដូចជារូបរាងកាយ។”

លោកបណ្ឌិត ប្រីក្ស បានយល់ច្រឡំពាក្យខាងលើរបស់លោក បាក់ស្ទើរ ហើយគាត់បាននិយាយថា “លោក បាក់ស្ទើរមិនបានជឿលើទស្សនៈនៃការបើកសម្តែងដោយផ្ទាល់មាត់របស់បទគម្ពីរទេ។” តែលោកបណ្ឌិតវ៉រហ្វីលដ៍បាននិយាយថា “ពាក្យខាងលើរបស់លោកបាក់ស្ទើរមិនមែនជាពាក្យដែលទាស់នឹងការបើកសម្តែងដោយផ្ទាល់

មាត់របស់ព្រះគម្ពីរទេ តែវាមានន័យថា ផ្នែកមួយនៃបទគម្ពីរមានតម្លៃជាងផ្នែកផ្សេងទៀត។”

ហើយលោកបណ្ឌិត វ័រហ្វីលដ៍ បានប្រាប់ពីទីបន្ទាល់ដែលលោកបាកស្ទើរបានជឿនូវទស្សនៈនៃការបើកសម្ដែងផ្ទាល់មាត់របស់បទគម្ពីរដល់យើង។ ទីបន្ទាល់ដូចតទៅ គឺថា លោកបាកស្ទើរបាននិយាយថា “ការរិះគន់ដែលនិយាយថា អ្វីដែលត្រូវបានបិទត្រាដោយព្រះវិញ្ញាណបរិសុទ្ធជាគោលលិទ្ធិតែមួយគត់ ហើយមួយនេះគត់ដែលគ្មានកំហុសសោះ។ ហើយពួកគេ (ការរិះគន់) និយាយថា ឃ្លាឃ្លោងនៃបទគម្ពីរត្រូវបានប្ដូរដោយស្ថានភាព ដ្បិតឃ្លា និងវិធីសាស្ត្រមិនពេញលេញ ហើយអាចធ្វើខុសបាន ត្រង់ចំណុចនោះដែលប្រៀបដូចជាមនុស្សប្រាជ្ញ។ តែមនុស្សដែលនិយាយដូច្នោះជាអ្នកដែលនិយាយពីគម្ពីរដោយខុសយ៉ាងខ្លាំង។”

លោក បាកស្ទើរ បាននិយាយម្ដងទៀតថា “ពួកសាវកត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ហើយមិនមានការខុសណានៅក្នុងការសរសេរព្រះគម្ពីរនោះទេ។”

## ការអធិប្បាយ 15 ភស្តុតាងដែលសមហេតុផលដែលថា បទគម្ពីរជាព្រះបន្ទូលរបស់ព្រះ (ម៉ាថាយ 4:1-11)

1. ដ្បិតព្រះគម្ពីររាប់បញ្ចូលនូវហេតុផលដែលជ្រៅ អាថ៌កំបាំង គឺថា ការពិតដែលពិបាកនឹងយល់ដោយហេតុផលរបស់មនុស្ស ដូចជាការបង្កបង្កើត ការអស្ចារ្យគោលលិទ្ធិនៃព្រះត្រៃឯកជាដើម។ បើយើងមើលទៅ យើងអាចដឹងថា ព្រះគម្ពីរមិនត្រូវបានសរសេរដោយប្រាជ្ញារបស់មនុស្សទេ។

2. បទគម្ពីរត្រូវបានសរសេររយៈពេលយ៉ាងយូរប្រហែល 1600 ឆ្នាំ ហើយត្រូវបានកត់ត្រាដោយអ្នកសរសេរចំនួណ 36 នាក់ តែការកត់ត្រាមិនបានប្រឆាំងគ្នានោះទេ។

3. កាលដែលយើងមើលទៅកាន់ការពិតថា ទំនាយរបស់បទគម្ពីរត្រូវបានសម្រេច ព្រះដែលត្រូវបានទាយទុកនោះជាព្រះពិត យើងអាចដឹងការពិតថា បទគម្ពីរពិត ការពិតដែលបានសម្រេចជាការពិត ព្រះពរដែលការពិតបានសម្រេចរាប់បញ្ចូលពិតប្រាកដ។

4. វាច្បាស់ណាស់ថា អ្នកដែលអានគម្ពីរបានទទួលព្រះពរថ្មីនៃសេចក្ដីសង្គ្រោះ និងបានឃើញនូវការផ្លាស់ប្រែយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់គេ ព្រះគម្ពីរមិនមែនជាពាក្យរបស់មនុស្សទេ តែជាព្រះបន្ទូលរបស់ព្រះ។ អ្នកដែលជឿដល់ព្រះបន្ទូលនេះ ហើយទទួលវា នោះបានស្គាល់ព្រះ និងទទួលបានព្រះពរ។

5. កាលដែលយើងឃើញការពិតថា សេចក្តីពិតរបស់ព្រះគម្ពីរ នោះពាក្យមិនបានប្តូរទេ យើងអាចដឹងថា វាជាព្រះបន្ទូលរបស់ព្រះ។ លោក ឡូរ៉ែន បូតនើ បាននិយាយដូចតទៅថា "អ្នកវិទ្យាសាស្ត្ររបស់បារាំងបានបោះពុម្ព ការពិតនៃវិទ្យាសាស្ត្រចំនួន 51 ដែលជំទាស់នឹងព្រះបន្ទូលមួយចំនួននៅក្នុងបទគម្ពីរ រហូតមកដល់ពេលនេះ ការទាំងនោះត្រូវបានបង្ហាញមកដោយផ្ទាល់នូវការពិតថា ការបោះពុម្ពផ្សាយនោះខុសស្រឡះ ហើយគ្រប់យ៉ាងនៅក្នុងបទគម្ពីរសុទ្ធតែត្រឹមត្រូវ។"

6. នៅក្នុងបទគម្ពីរមានការអប់រំ សីលធម៌ដែលខ្ពស់បំផុតដែលយើងជាមនុស្សមិនអាចស្រមៃដល់។

## ការអធិប្បាយ 16 ការប្រែចិត្ត និងជំនឿ (ម៉ាកុស 1:14-15 ម៉ាថាយ 4:17)

1. ការប្រែចិត្ត

1) តើអ្វីជាការប្រែចិត្ត?

លោក បាដស៍ និយាយថា "វាមិនមែនជាការសម្រេចបំពេញនៃសេចក្តីបរិសុទ្ធដ៏ថ្លៃថ្លា នៅក្នុងមនុស្សទេ តែជាដំណាក់កាលចាប់ផ្តើមនៃសេចក្តីសុចរិតរបស់ព្រះ។" នេះជាពាក្យដែលគាត់បានឃើញថា ការលន់តួបាបជាសកម្មភាពរបស់ព្រះតែមួយគត់។ តែយើងមិននិយាយថាវាមិនមែនត្រឹមតែជាសកម្មភាពរបស់ព្រះតែមួយនោះទេ តែជាការទូញសោកសង្រេងរបស់មនុស្សដោយកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធផងដែរ។ លោកបណ្ឌិត ខាយកើ បាននិយាយថា "នៅក្នុងសញ្ញាចាស់ ពាក្យថា ការប្រែចិត្តគឺ សាប់ ដែលបង្ហាញមក 70 ដង ដែលត្រូវបានសរសេរចុះជាសកម្មភាពរបស់មនុស្ស 16 ដង ត្រូវបានសរសេរជាសកម្មភាពរបស់ព្រះ។ យើងជឿថា អង្គដែលធ្វើឱ្យយើងប្រែចិត្តនោះជាព្រះ។ ( កិច្ចការ 11:18, ២ធីម៉ូថេ 2:25)

តែអ្នកដែលមានទំនួលខុសត្រូវក្នុងការធ្វើការប្រែចិត្តនោះគឺជាមនុស្ស។ ហាជ្រេ ជាមនុស្សប្រមឹកម្នាក់ តែកាលដែលគាត់អង្គុយនៅតាមផ្លូវ គាត់បានឮសម្លេងថា "ចូរមក"។ ហើយគាត់មានអារម្មណ៍ថាជាវត្តមានរបស់ព្រះ ហើយគាត់បានប្រែចិត្តនៅពេលនោះ។

2) ស្ថានភាពនៃការប្រែចិត្ត

២កូរិនថូស 7:10, 11 មានបន្ទូលថា "ព្រោះសេចក្តីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ នោះរមែងនាំឱ្យប្រែចិត្តឡើង ប្រយោជន៍ឱ្យបានសង្គ្រោះ ជាសេចក្តីដែលមិនត្រូវស្តាយឡើយ តែសេចក្តីព្រួយរបស់លោកីយ៍ នោះបង្កើតសេចក្តីស្លាប់វិញ។ ដ្បិតមើលសេចក្តីនេះឯង គឺដែលអ្នករាល់គ្នាមានសេចក្តីព្រួយដ៏គាប់ដល់ព្រះហឫទ័យនៃព្រះ

នោះបានបង្កើតឱ្យអ្នករាល់គ្នាមានសេចក្តីសង្វាត សេចក្តីដោះសា សេចក្តីគ្នាន់ក្នាញ់ សេចក្តីភ័យខ្លាច សេចក្តីនឹករឭក សេចក្តីឧស្សាហ៍ និងសេចក្តីសងសឹកជាខ្លាំងទាំងម៉្លេះ អ្នករាល់គ្នាបានសំដែងយ៉ាងច្បាស់ថា ខ្លួនបរិសុទ្ធក្នុងដំណើរនេះគ្រប់ជំពូក។” កាលដែលយើងមើលទៅកាន់ព្រះបន្ទូលនេះ ការប្រែចិត្តជាការដឹងពីអំពើបាបនៅក្នុងគំនិត ការស្អប់អំពើបាបនៅក្នុងអារម្មណ៍ និងការរស់នៅសម្រាប់ព្រះដោយឆន្ទៈ។ វាមិនសំខាន់ទេដែលអ្នកជំងឺដឹងពីជំងឺរបស់ខ្លួននោះ តែវាជាប្រាជ្ញាដែលគេស្វែងរកវិធីសាស្ត្រដើម្បីព្យាបាលវា។ ការប្រែចិត្តពិតប្រាកដរបស់មនុស្សមានបាបមានសេចក្តីជំនឿទៅកាន់ព្រះគ្រីស្ទជាគោលបំណងរបស់វា។ នៅក្នុងការទួញសោកក្នុងការប្រែចិត្តជាការដែលមានតម្លៃ តែដោយផ្តោតលើការទួញសោកតែមួយវាមិនល្អនោះទេ។ វាជាដំណាក់កាលរៀបចំនាំឱ្យមានជំនឿ។ ការឆ្ពោះតម្រង់ទៅកាន់សេចក្តីជំនឿដែលជឿដល់ព្រះជាម្ចាស់ នោះហើយជាគោលបំណងនៃការប្រែចិត្ត។ អ្នកដែលប្រែចិត្តក្រោយមកនឹងបញ្ចប់ជាការទួញសោក និងការប្តេជ្ញាចិត្តដែលគាត់នឹងទៅកាន់ដំណាក់កាលនៃការជឿដល់ព្រះជាម្ចាស់។

3) ព្រះគុណដែលផ្តល់ដល់អ្នកប្រែចិត្ត

១សាំយ៉ូអែល 7:3 បានិយាយថា “នៅវេលានោះ សាំយូអែលប្រាប់ដល់ពួកវង្សអ៊ីស្រាអែលទាំងអស់ថា បើអ្នករាល់គ្នាវិលត្រឡប់មកឯព្រះយេហូវ៉ាវិញដោយអស់ពីចិត្ត នោះត្រូវយកអស់ទាំងព្រះដទៃ និងរូបព្រះទាំងប៉ុន្មានពីពួកអ្នករាល់គ្នាចេញ ហើយបាញ់ចិត្តដំរង់ចំពោះព្រះយេហូវ៉ា ព្រមទាំងគោរពប្រតិបត្តិដល់ទ្រង់តែ១ នោះទ្រង់នឹងជួយដោះអ្នករាល់គ្នា ឱ្យរួចចេញពីកណ្តាប់ដៃនៃពួកភីលីស្ទីន”។ ២កូរិនថូស 7:14 មានបន្ទូលថា “ពីព្រោះបើសិនជាខ្ញុំបានអួតនឹងគាត់ ពីដំណើរអ្នករាល់គ្នាយ៉ាងណាខ្លះ

នោះខ្ញុំមិនខ្មាសទេ ព្រោះសេចក្ដីដែលយើងខ្ញុំបានអួតនឹងទីតុស ពីអ្នករាល់គ្នា នោះឃើញថាពិតមែន ដូចជាសេចក្ដីទាំងប៉ុន្មាន ដែលយើងខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាក៏ពិតដែរ”។ ទំនុកដំកើង 34:18 មានបន្ទូលថា “ព្រះយេហូវ៉ាទ្រង់គង់ជិតបង្កើយនឹងអស់អ្នក ដែលមានចិត្តសង្រេង ហើយទ្រង់ជួយសង្គ្រោះដល់អស់អ្នក ដែលមានវិញ្ញាណទន់ទាប។” ទំនុកដំកើង 51:17 មានបន្ទូលថា “ឯដង្វាយដែលគួរថ្វាយដល់ព្រះ នោះគឺជាវិញ្ញាណខ្ទេចខ្ទាំ ឱព្រះអម្ចាស់អើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេចខ្ទាំហើយទន់ទាបឡើយ។” ទំនុកដំកើង 147:3 មានបន្ទូលថា “ទ្រង់ប្រោសអស់អ្នកដែលមានចិត្តសង្រេងឱ្យបានជា ក៏រុំរបួសឱ្យគេផង។”

2. សេចក្ដីជំនឿ

1) ទំនុកចិត្តនៃសេចក្ដីជំនឿរបស់គ្រីស្ទានគឺប្រាកដជាងចំណេះដឹងដែលច្បាស់លាស់នៅក្នុងលោកិយនេះទាំងអស់។ ពីព្រោះពាក្យរបស់លោក បារឹង ត្រូវបានលើកឡើងដែលថា (1) ការអះអាងនៃទំនុកចិត្តនោះវាខ្លាំងជាងការធានានៃច្បាប់វិទ្យាសាស្ត្រ ពីព្រោះច្បាប់មូលដ្ឋាននៃវិទ្យាសាស្ត្រត្រូវបានរកឃើញនៅលើគ្រឹះនៃទំនុកចិត្ត។ 2) ពីព្រោះកម្មវត្ថុនៃទំនុកចិត្តនេះជាព្រះ ពីព្រោះអ្នកដែលមានទំនុកចិត្តនឹងមានឥរិយាបថ ដែលអាចនឹងទទួលនូវការស្លាប់បានដោយសារទំនុកចិត្តនោះ។ 3) ពីព្រោះជំនឿនោះត្រូវបានផ្ដល់មកដោយព្រះវិញ្ញាណបរិសុទ្ធ។ ២ កូរិនថូស 4:13 មានបន្ទូលថា “ហើយដែលមានចិត្តជឿដូចគ្នា ត្រូវនឹងសេចក្ដីដែលចែងទុកមកថា «ខ្ញុំបានជឿ បានជាខ្ញុំនិយាយ» នោះយើងខ្ញុំក៏ជឿដែរ បានជាយើងខ្ញុំនិយាយ។” សេចក្ដីជំនឿជាអំណោយដែលពេញលេញរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពួកហោរាក៏មិនបានជឿ

ដោយសារតែប្រាជ្ញារបស់ពួកគេទេ ហើយពួកសាវកក៏មិនបានជឿដោយសារប្រាជ្ញារបស់ពួកគេដែរ។

3. លទ្ធផលនៃការប្រែចិត្ត និងជំនឿ

អេសាយ បាននិយាយថា “ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ។”(អេសាយ 1:18) ការនេះចង្អុលទៅកាន់ការអត់ទោសដែលព្រះទ្រង់ប្រទានដល់អ្នកដែលជឿពិតប្រាកដ។ ជាការពិតដែលមនុស្សត្រូវបំផ្លាញដោយសារអំពើបាប។ ការពិតនៃការអត់ទោសបាបត្រូវបានបង្រៀននៅក្នុងគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី។ ភីលីព 3:9 មានបន្ទូលថា “ហើយឱ្យគេបានឃើញខ្ញុំនៅក្នុងទ្រង់ ដោយសេចក្តីសុចរិតដែលមកពីសេចក្តីជំនឿដល់ព្រះគ្រីស្ទ មិនមែនដោយសេចក្តីសុចរិតរបស់ខ្លួនខ្ញុំដែលមកពីក្រឹត្យវិន័យនោះទេ គឺជាសេចក្តីសុចរិតដែលមកពីព្រះ ដោយសេចក្តីជំនឿវិញ។” ការនេះចង្អុលទៅកាន់សេចក្តីសុចរិតដោយការរាប់ជាសុចរិតនៃការអត់ទោសបាប។ លោក វ័រហ្វីលដ៍ បាននិយាយត្រង់នេះថា “សេចក្តីសុចរិតផ្ទាល់ខ្លួនរបស់យើងមិនមែនជារង្វាស់នៃសេចក្តីសង្រ្គោះរបស់យើងឬស្ថិតនៅក្នុងកម្រិតណាមួយនោះទេ តែមានតែសេចក្តីសុចរិតដែលព្រះទ្រង់ផ្តល់មកនៅក្នុងព្រះគ្រីស្ទតែមួយប៉ុណ្ណោះដែលជារង្វាល់នៃសេចក្តីសង្រ្គោះ។ ម្យាងទៀត ឃ្លានេះមានន័យថា យើងអាចទទួលបានសេចក្តីសង្រ្គោះមិនមែនដោយសារខ្លួនយើង ឬកិច្ចការរបស់យើងនោះទេ តែយើងបានសង្រ្គោះដោយសារសេចក្តីសុចរិតរបស់ព្រះតែមួយគត់។”

## ការអធិប្បាយ 17 សេចក្តីជំនឿ (ម៉ាកុស 1:14-15, ម៉ាថាយ 4:17)

1. រូបភាពនៃសេចក្តីជំនឿ
    1) ភាពស្មោះត្រង់

ពាក្យថា ជំនឿ គឺ ហ៊ីមីន ( ) នៅក្នុងភាសាហេព្រើ ដែលមានន័យថា "ការពង្រឹង" ឬ "ការជឿដោយសារភាពស្មោះត្រង់"។ សង្ខេបមក សេចក្តីជំនឿមានភាពស្មោះត្រង់នៅក្នុងធាតុ និងជីវិតរបស់វា។ សេចក្តីពុតត្បុត និងរបាំងមុខមិនមែនជាជំនឿទេ តែជាសត្រូវនៃជំនឿ និងជារបាំងនៃជំនឿវិញ។ នៅកន្លែងដែលសេចក្តីពុតត្បុត និងរបាំងមុខនៅ នោះគ្មានសេចក្តីជំនឿទេ ហើយក៏គ្មានការលូតលាស់នៃសេចក្តីជំនឿដែរ។ ដូច្នេះ បទគម្ពីរបង្រៀនពីជំនឿ ហើយក្នុងពេលតែមួយក៏ដាក់បណ្តាសាដល់សេចក្តីពុតត្បុតផងដែរ។

ពួកផារីស៊ី ជានិមិត្តរូបនៃសេចក្តីពុតត្បុតដែលជាសត្រូវរបស់ព្រះយេស៊ូវ។ លោក ចន បាន់យាន បាននិយាយថា "មនុស្សមានពុតជាពួកបរិសុទ្ធតែនៅខាងក្រៅ តែជាអារក្សនៅខាងក្នុងផ្ទះ (អ្នកបរិសុទ្ធនៅខាងក្រៅ និងជាអារក្សនៅផ្ទះ)។ លោក មូឌី បាននិយាយថា "ការនិយាយដំណឹងល្អតែនឹងពាក្យសម្តី មានន័យថាការលើកវាឡើងដើម្បីនឹងបង្ហាញ ការមានដំណឹងល្អមានន័យថាធ្វើឱ្យគេបានចូលទៅកាន់ស្ថានសួគ៌។" គឺត្រូវហើយ។ យើងគួរដឹងការពិតថា កាលណាយើងជឿ ដោយមិនបានកាន់

ជាប់ដែលត្រូវដើរតាមខ្យល់នៃសេចក្តីពុតត្បុត នោះមិនមែនជាសេចក្តីជំនឿពិតទេ។ ពីព្រោះក្រុមជំនុំកូរ៉ររបស់យើងបានពឹងលើអំណាចផ្សេង តែមិនបានឈរនៅលើជំនឿដែលស្មោះត្រង់នោះទេ។ ក្រុមជំនុំនឹងដួលចុះ។ អ្វីទៅជាសកម្មភាពដែលម្នាក់ត្រូវដួលគួរធ្វើ? នោះជាការក្រោកឡើង។ អ្នកណាដែលមិនមែនជាមនុស្សមានពុត ហើយមិនពឹងលើអ្នកផ្សេង តែក្រោកឈរនៅលើព្រះបន្ទូលរបស់ព្រះគម្ពីរ? ព្រះទ្រង់ចង់ឃើញមួយនេះ។

2) ដំណើរការនៃសេចក្តីជំនឿ

ព្រោះសេចក្តីជំនឿកើតចេញពីសេចក្តីពិត សេចក្តីពិតមិនចម្រើនឡើយ ។ វាជាហោរាដែលទាយដោយសេចក្តីពិត ជាអ្នកប្រយុទ្ធ។ លោក ថេននីសុន បានបង្កើតកំណាព្យដូចទៅថា "សេចក្តីជំនឿមិនកើតឡើងនៅក្នុងព្យុះនៃពាក្យសង្គ្រាមទេ នាងភ្លឺនៅពេលប៉ះទង្គិចទៅនឹង មែន និងទេ នាងមើលឃើញល្អបំផុតដែលភ្លឺតាមរយៈអ្វីដែលអាក្រក់បំផុត នាងមានអារម្មណ៍ថាព្រះអាទិត្យត្រូវបានលាក់ ប៉ុន្តែសម្រាប់មួយយប់នាងបានសង្កេតរដូវក្តៅឆ្លងផុតរហូតដល់រដូវរងា នាងភ្លក់ផ្លែឈើមុនពេលផ្ការីក នាងលឺសូរពងមាន់នៅក្នុងពងដែលគ្មានចម្រៀង។"

ពិតជាត្រូវមែន! ជំនឿអាស្រ័យលើសេចក្តីពិតនៃបទគម្ពីរដែលបានបើកបង្ហាញ មានសង្ឃឹមទៅអនាគត ហើយមានការធានាអះអាងផង។ លោក ស្ពឺជិន បាននិយាយថា "ការប្រែចិត្ត សេចក្តីជំនឿ សេចក្តីប៉ងប្រាថ្នាដ៏វិសុទ្ធ ជាកំដៅដែលចង់បានស្ថានសួគ៌ការទួញសោកដែលមិនអាចនិយាយបាន គឺជាទីសំគាល់ដែលព្រះវិញ្ញាណបរិសុទ្ធធ្វើ

ការនៅក្នុងយើង។ ជីវិតនេះព្រះវិញ្ញាណបរិសុទ្ធដែលផ្តល់ទិសដៅដល់យើង។ យើងមិនចាំបាច់ស្វែងរកសុបិន និមិត្ត សំឡេងអាថ៌កំបាំង និងអារម្មណ៍ងប់ងល់ឡើយ។”

2. គំនិតដែលបាំងសេចក្តីជំនឿ

1) ការដោះសារថាកម្មវត្ថុនៃជំនឿនោះមើលមិនឃើញសោះ

ជំនឿគឺជាសកម្មភាពនៃការជឿជាក់លើវត្ថុដែលមើលមិនឃើញ។ ប៉ុន្តែយើងមិនអាចនិយាយថាវាជាការសង្ស័យទេ។ វិទ្យាសាស្ត្រក៏មិនដឹងពីខ្លឹមសារនៃស្ថានភាពធម្មជាតិដែរ។ ប៉ុន្តែទោះបីជាវិទ្យាសាស្ត្រមិនដឹងក៏ដោយ ប៉ុន្តែវិទ្យាសាស្ត្រជឿជាក់លើវា ហើយវាធ្វើឱ្យការស្រាវជ្រាវបានដំណើរការផង។ ដូច្នេះហើយ យើងមិនគួរគិតថា សកម្មភាពនៃទំនុកចិត្តមិនគួរត្រូវបានប្រើចំពោះទ្រឹស្តីសាសនានោះទេ។ កាលយើងមានសកម្មភាពជឿជាក់លើសាសនា អ្នកណាដែលនិយាយថា ទ្រឹស្តីសាសនាមិនអាចជឿបាន។ ប្រតិបត្តិការនៃចំណេះដឹងទាំងអស់មានមូលដ្ឋានគ្រឹះនៃភាពជឿជាក់។

2) ចិត្តដែលទុច្ចរិតដែលជឿលើខ្លួន

នេះជារនាំងដល់សេចក្តីជំនឿ។ សុភាសិត 28:26 មានបន្ទូលថា “អ្នកណាដែលទីពឹងតែចិត្តខ្លួនឯង នោះជាអ្នកល្ងីល្ងើហើយ តែអ្នកណាដែលប្រព្រឹត្តដោយប្រាជ្ញាវិញ នោះនឹងបានប្រោសឱ្យរួច។” សុភាសិត 26:12 មានបន្ទូលថា “ឯងដែលឃើញមនុស្សដែលប្រកាន់ថា ខ្លួនមានប្រាជ្ញាឬទេ មានសង្ឃឹមចំពោះមនុស្សល្ងីល្ងើជាជាងអ្នកនោះទៅទៀត។” យេរេមា 17:9 មានបន្ទូលថា “ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន។”

3) ចិត្តដែលស្រឡាញ់អំពើបាប

អំពើបាបធ្វើឱ្យយើងព្រងើយកន្តើយនឹងព្រះ និងការជឿលើទ្រង់។ បើគ្មានអំពើបាបទេ ប្រាកដណាស់ថាមនុស្សទាំងអស់នៃពិភពលោកនេះនឹងជឿលើព្រះ ហើយបម្រើទ្រង់។ ដូច្នេះ យើងគួរបើកទ្វារឆ្ពោះទៅរកព្រះ ហើយសម្អាតជីវិតដែលមានបាបទាំងអស់។ យើងមិនគួរយកចន្លោះរវាងយើង និងព្រះនៅក្នុងផ្នែកណាមួយនៃជីវិតដែលគិតរបស់យើង និងជីវិតនិងរូបរាងកាយរបស់យើងនោះទេ។ យើងគួរបើកចិត្តយើងឱ្យដូចជាទ្វារចំហ ហើយទទួលយកព្រះអម្ចាស់ ហើយបន្ទាប់មកទ្រង់គួរធ្វើការគ្រប់គ្រងលើជីវិតរបស់យើង ។ ពេលនោះ យើងស្គាល់ទ្រង់ ហើយយើងអាចប្រកបជាមួយទ្រង់។“អញបន្ទោស ហើយផ្ចាញ់ផ្ចាល ដល់អស់អ្នកណាដែលអញស្រឡាញ់ ដូច្នេះ ចូរមានចិត្តឧស្សាហ៍ ហើយប្រែចិត្តចុះ។ មើល អញឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាឮសំឡេងអញ ហើយបើកទ្វារឱ្យ នោះអញនឹងចូលទៅឯអ្នកនោះ អញនឹងបរិភោគជាមួយនឹងអ្នកនោះ ហើយអ្នកនោះជាមួយនឹងអញដែរ។” (វិវរណៈ 3:19, 20) ការមិនប្រែចិត្តជាការសង់ជញ្ជាំងទៅកាន់ព្រះ និងការបាំងមាត់ទ្វារផង។ ការដែលបាំងរវាងព្រះនឹងយើងគឺជាអំពើបាបតែមួយគត់។ អេសាយ 59:1, 2 មានបន្ទូលថា “ “។

លោក ម៉ូឌី បាននិយាយថា "ប្រសិនបើការផ្គត់ផ្គង់ទឹករបស់យើងមិនគ្រប់គ្រាន់ ខ្ញុំមិនសន្និដ្ឋានថាទន្លេ ឬបឹងបានស្ងួតទេ ប៉ុន្តែបំពង់ទុយយ៉ូរបស់យើងមិនមានសណ្តាប់ធ្នាប់វិញ"។ ព្រះមិនប្រតិបត្តិមិនដាក់ទោសបាបទេ។

លោក បារីង បាននិយាយថា “ប្រសិនបើព្រះជាម្ចាស់មិនដាក់ទោសអំពើបាប នោះមានន័យថា ព្រះកំណត់អត្តសញ្ញាណល្អ និងអាក្រក់ ហើយបះបោរទាស់នឹងអង្គទ្រង់

ខ្លួនឯង។ ត្រូវតែដាក់ទោសបាប ព្រោះព្រះគឺសម្រាប់ព្រះអង្គទ្រង់ផ្ទាល់។ (Indien Hij dezonde niet straft, zou Hij aan het kwade gelijke rechten toekennen als aan het geode en zichhzelven verloochenen opdat God God blijve, is de straf der zoned noodzakelijk – Geref. III. P 170)

បន្ទាប់មក រឿងដែលត្រូវរារាំង ដូចជាជញ្ជាំងរវាងយើង និងព្រះជាម្ចាស់ គឺជាអំពើបាបតែមួយប៉ុណ្ណោះ។ បើមនុស្សគ្មានបាប អ្នកនោះនឹងជឿដល់ព្រះ។ ចុះតើអ្វីជាវិធីដើម្បីបំផ្លាញជញ្ជាំងនោះ? វាគឺជាការប្រែចិត្ត។ តើអ្វីទៅជាការប្រែចិត្ត? វាចង្អុលទៅកាន់ចិត្តដែលដែលខូចនោះគឺជាចិត្តរបស់យើងដូចជាថ្មដែលខូច។

ដូចជាពួកបរិសុទ្ធទាំងអស់ត្រូវបានទទួលបទពិសោធន៍ដូចជាពាក្យខាងលើដែរ ដូចដែលយើងឃើញបទពិសោធន៍របស់លោក ស្ពឺជិន យើងមានការយល់ដឹងយ៉ាងខ្លាំង។ ស្ពឺជិនបានឃើញពាក្យនេះ ១យ៉ូហាន 1:9, “បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង។” ហើយគាត់បានញាប់ញ័រដោយភ័យខ្លាច ហើយបានសារភាពអំពើបាបរបស់គាត់នៅចំពោះព្រះ គាត់បានទទួលសន្តិភាពដែលមិនអាចនិយាយបានដល់គាត់។

## ការអធិប្បាយ 18 ព្រះយេស៊ូវត្រូវបានគេបដិសេធនៅណាសារ៉ែត (លូកា 4:16-30)

លូកាបានសរសេរពីសេចក្ដីពិតដែលព្រះយេស៊ូវត្រូវបានគេបដិសេធនៅណាសារ៉ែតដោយលម្អិត។ គាត់បានចង្អុលយ៉ាងច្បាស់ពីដំណឹងល្អរបស់ព្រះយេស៊ូវនៅក្នុងព្រឹត្តិការណ៍នេះ។

1. កិច្ចការនៃដំណឹងល្អ

ការនេះត្រូវបានបង្ហាញនៅ 4:18, 19 ដែលជាការប្រកាសដំណឹងល្អដោយព្រះវិញ្ញាណបរិសុទ្ធ។ អត្ថបទរបស់យើងបាននិយាយថា "ព្រះវិញ្ញាណរបស់ព្រះបានសណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានតាំងខ្ញុំឱ្យប្រកាសដំណឹងល្អដល់មនុស្សក្រីក្រ។" ដំណឹងល្អមិនមែនជាប្រព័ន្ធនៃចំណេះដឹងដែលត្រូវបានផ្ទេរដោយវិធីសាស្ត្រមួយចំនួននៃការបង្រៀនទេ តែជាប្រាជ្ញាតែមួយគត់របស់ព្រះដ៏ពិតតាមរយៈអំណាចរបស់វិញ្ញាណ។ ហើយលទ្ធផលនៃកិច្ចការនេះជាព្រឹត្តិការណ៍ដែលមនុស្សខ្វាក់អាចមើលឃើញ និងមនុស្សដែលមានអារក្សចូលត្រូវបានដោះលែង។ នេះជាព្រះបន្ទូលដែលមានអត្ថន័យខាងវិញ្ញាណ។ (អេសាយ 42:6, 29:18, 58:6, 7 47:17-20, 52:1-6) ជំពូក និងខ

នៃការបង្រៀនទាំងអស់ជាពាក្យដែលបង្ហាញពីព្រះគុណដែលព្រះមេស្ុីទ្រង់សង្គ្រោះ។ ហោរាអេសាយចាត់ទុកមនុស្សដែលនៅក្នុងបាបថាជាមនុស្សដែលងងឹតដូចជាត្រូវអារក្សចូល។ អំពើបាបធ្វើឱ្យមនុស្សទៅជាងងឹត ហើយធ្វើឱ្យគេមិនស្គាល់ព្រះ ហើយទាញសេរីភាពពីព្រលឹងរបស់ពួកគេ និងធ្វើឱ្យពួកគេទៅជាទាសករ។ មនុស្សដែលក្លាយទៅជាងងឹតខាងវិញ្ញាណ និងបាត់បង់សេរីភាព នោះមិនមានសេចក្តីអំណរពិតនៅក្នុងកន្លែងអំណរនោះទេ តែមនុស្សដែលមានសេរីភាពខាងវិញ្ញាណត្រូវបានរំដោះដោយព្រះគ្រីស្ទ និងពីសត្រូវរបស់គេផង។

2. ដំណឹងល្អមានកិច្ចការនៃព្រះគុណដោយភាពជាអម្ចាស់ដ៏មានមហិទ្ធិឫទ្ធិរបស់ព្រះ

ព្រះគុណនៃដំណឹងល្អមិនអនុវត្តដោយកាយវិការខាងរូបកាយ និងរូបភាពរបស់មនុស្សទេ។ ដ្បិតវាជាព្រះគុណ ដែលវាមិនត្រូវបានបង្កើតដោយសារអ្នកណាម្នាក់ឡើយ។ មានតែអ្នកដែលទទួលវាប៉ុណ្ណោះនឹងទទួលបាន។ តាមរយៈអ្នកបម្រើរបស់ព្រះ អេលីយ៉ាដែលទទួលបានព្រះគុណដ៏ពិសេស គឺមានតែស្រ្តីមេម៉ាយដែលនៅសេរេផាសប៉ុណ្ណោះ។ យើងដឹងថាស្រ្តីមេម៉ាយបានទទួលព្រះគុណ ដែលស្បៀងអាហាររបស់នាងមិនត្រូវបានកាត់បន្ថយដោយការស្តាប់តាមព្រះបន្ទូលរបស់ហោរា។ មូលហេតុដែលនាងបានទទួលព្រះគុណគឺដោយសារនាងបានគោរពតាមពាក្យរបស់ហោរា។ ព្រះគុណតែមួយគត់ដែលជាមូលហេតុសំខាន់លើសពីអ្វីទាំងអស់ដែលហោរាបានទៅជួបស្រ្តីមេម៉ាយ។ ព្រះបានចាត់ហោរារបស់ទ្រង់ទៅឯនាង ដើម្បីប្រទានព្រះគុណដល់នាង។ មនុស្សគួរគោរពអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ ហើយគួរមើលការដាស់តឿនដ៏សប្បុរសរបស់ទ្រង់។ អ្នកដែលបានទទួលព្រះគុណដែលបានរួចពីគ្រោះឃ្លង់នោះក៏

មានឈ្មោះណាម៉ាន់ ជាអ្នកស្រុកស៊ីរី។ ដូចដែលយើងឃើញហើយ វាច្បាស់ណាស់ថា ព្រះមិនមានបំណងសង្គ្រោះមនុស្សទាំងអស់នោះទេ ប៉ុន្តែទ្រង់បានសង្គ្រោះមនុស្ស ដើម្បីតែងតាំងការសង្គ្រោះតាមព្រះហឫទ័យរបស់ទ្រង់ បើទោះបីជាចំនួននេះមាន ចំនួនច្រើន និងតិចក៏ដោយ។ ការពិតដែលថាព្រះយេស៊ូវត្រូវបានបដិសេធដោយ មនុស្សដែលនៅទីកំណើតរបស់ទ្រង់ ហើយមិនបានសង្គ្រោះមនុស្សជាច្រើន នោះមិន មែនជាការបរាជ័យរបស់ទ្រង់ទេ ប៉ុន្តែយើងមិនអាចជួយបានក្រៅពីមើលឃើញថាទី បំផុតវាបានស្របតាមព្រះហឫទ័យរបស់ទ្រង់។ វាជារឿងសោកសៅ នៅពេលដែល យើងគិតពីការពិត ដែលវាមិនមានឥទ្ធិពលដល់ភូមិកំណើត សាច់ញាតិ និងក្រុម គ្រួសារដោយព្រះគុណខាងវិញ្ញាណ។ ប៉ុន្តែកិច្ចការនៃដំណឹងល្អមិនបានបញ្ចប់នូវការ សម្រេចដោយរីករាយដោយការដឹកនាំនៃការស្រឡាញ់មនុស្សជាដាច់ខាត។ ដោយ សារដំណឹងល្អមិនមែនជារបស់សាច់ឈាម និងរូបកាយទេ ប៉ុន្តែត្រូវបំពេញប្រវត្តិតាម ព្រះហឫទ័យរបស់ព្រះ និងការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សតែងតែនិយាយ ថា "ដំណឹងល្អគឺអស្ចារ្យ ប៉ុន្តែហេតុអ្វីបានជាលទ្ធផលនៃការងារនេះ មិននាំឱ្យមនុស្ស ជាតិទាំងអស់នៃពិភពលោកទាំងមូលចូលទៅកាន់ព្រះ ប៉ុន្តែបង្ហាញអ្នកជឿនៅក្នុង ផ្នែកនេះ និងផ្នែកនោះទៅវិញ? ប៉ុន្តែ ពាក្យនេះខុស ដោយសារបានមើលងាយចំពោះ ការពិតដែលថាដំណឹងល្អត្រូវបានប្រកាសដោយគោលការណ៍នៃអធិបតេយ្យភាពនៃ ភាពជាម្ចាស់ និងព្រះគុណរបស់ទ្រង់។ ទោះបីជាមនុស្សជាច្រើនមិនត្រូវបានចូលរួម នៅក្នុងសេចក្តីសង្គ្រោះនេះក៏ដោយ វាជារឿងធម្មតាដែលខ្ញុំដែលត្រូវចូលរួមនៅទីនេះ ដែលគួរតែទទួលយកដោយសេចក្តីអំណរ និងការអរព្រះគុណដែលមិនអាចនិយាយ បាន។ បើឧបមារថាមនុស្សជាតិទាំងអស់ជឿលើព្រះយេស៊ូវ នោះអ្នកជឿនឹងមិនអាច ទទួលយកនូវសេចក្តីស្រឡាញ់ថាជាវិសេសទេ កាលដែលគេបានទទួលពីព្រះដ៏

វិសេស ហើយគេក៏មិនរីករាយ ហើយក៏មិនអរគុណចំពោះវាដែរ។ សេចក្តីអំណរបំផុត នៅក្នុងពួកយើងនឹងកើតឡើង នៅពេលដែលយើងពិចារណាពីរបៀបដែលយើងអាចជឿលើព្រះយេស៊ូវយ៉ាងជ្រាលជ្រៅ។

**ការអធិប្បាយ 19 ការត្រាស់ហៅពួកសាវ័ក (ម៉ាថាយ 4:18-22, ម៉ាកុស 1:16-20)**

ព្រឹត្តិការណ៍ដែលព្រះយេស៊ូវបានត្រាស់ហៅសិស្សបួននាក់មកទីនេះ ហើយនៅក្នុងលូកាជំពូកទី 5។ ព្រឹត្តិការណ៍នៃជំពូកនេះត្រូវបានពិពណ៌នាខុសគ្នាខ្លះ ប៉ុន្តែបានកត់ត្រាខ្លឹមសារលម្អិតជាង ប៉ុន្តែព្រឹត្តិការណ៍នេះហាក់ដូចជាដូចគ្នា។ ដូច្នេះ តើសិស្សបួននាក់បានជួបព្រះយេស៊ូមុនគេឬ? វាមិនមែនដូច្នោះទេ។ ដូចដែលយើងឃើញ យ៉ូហានជំពូកទី១ ពួកគេបានជួបព្រះយេស៊ូវរួចហើយ។ (យ៉ូហាន 1:35-42) ប៉ុន្តែពួកគេបាន

ទៅកានឆ្នេរសមុទ្រកាលីឡេ និងធ្វើការជាអ្នកនេសាទម្តងទៀត។ បន្ទាប់មក ព្រះយេស៊ូវទ្រង់បានយាងទៅកាន់មាត់សមុទ្រកាលីឡេ និងធ្វើការផ្សាយដំណឹងល្អ ពួកគេបានបោះបង់ចោកពាក្យរបស់លោកិយទាំងស្រុង និងបានថ្វាយខ្លួនពួកគេដល់ព្រះជាម្ចាស់ធ្វើជាសាវកររបស់ទ្រង់។

1. ការអញ្ជើញរបស់ព្រះយេស៊ូវ

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅកាន់ពួកគេថា "រួចទ្រង់មានព្រះបន្ទូលទៅគេថា ចូរមកតាមខ្ញុំៗ នឹងតាំងអ្នក ឱ្យជាអ្នកនេសាទមនុស្សវិញ" (ម៉ាថាយ 4:19) អត្ថន័យនៃការធ្វើឱ្យគេក្លាយជាអ្នកនេសាទមនុស្ស គឺជាការនាំមនុស្សទៅឯព្រះអម្ចាស់ ហើយភ្ជាប់គាត់ទៅនឹងព្រះយេស៊ូវ។ ដោយសារមនុស្សនេះត្រូវបានគេបោះបង់ចោលដោយផ្ទាល់ពួកគេមិនអាចជួយបានឡើយ ប៉ុន្តែត្រូវបានបំផ្លាញទាំងស្រុង។ ប៉ុន្តែបន្ទាប់ពីចាប់គាត់បាន ហើយនាំគាត់ចូលទៅកាន់ព្រះអម្ចាស់ ហើយបន្ទាប់មក ពួកគេចូលទៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ច។ អ្នកផ្សាយដំណឹងល្អគួរតែរក្សាទុកវានៅក្នុងចិត្តរបស់គាត់ឱ្យជ្រៅ ហើយគួរតែប្រកាសដំណឹងល្អ។ គាត់គួរតែមានសេចក្តីស្រឡាញ់ដែលឆេះឆួលទៅកាន់ព្រលឹងរបស់មនុស្ស។ បើគ្មានការស្រលាញ់ចំពោះព្រលឹងមនុស្សនោះទេគាត់មិនអាចទទួលបានឥទ្ធិពលពិតក្នុងកិច្ចបម្រើផ្សាយដំណឹងល្អនោះទេ។ ព្រលឹងមនុស្សមិនអាចផ្លាស់ប្តូរគ្នាបានទេ ទោះបីជាគាត់ផ្តល់ឱ្យពិភពលោកទាំងមូលក៏ដោយមានតែអ្នកដែលមានសេចក្តីស្រលាញ់ដ៏អស្ចារ្យប៉ុណ្ណោះដែលអាចហៅមនុស្សពិត និងជាអ្នកផ្សាយដំណឹងល្អពិតប្រាកដ។ នៅពេលដែលមនុស្សនោះជឿលើដំណឹងល្អនៃព្រះគ្រីស្ទ គាត់អាចទទួលបានជីវិតអស់កល្បជានិច្ច ប៉ុន្តែប្រសិនបើគាត់មិនជឿលើ

ដំណឹងល្អ គាត់បានទទួលវិនាសដ៏នៅអស់កល្បជានិច្ច វាជារឿងសំខាន់ និងជារឿងបន្ទាន់ ែដលត្រូវដឹកនាំមនុស្សឱ្យចូលទៅក្នុងដំណឹងល្អ ហើយធ្វើឱ្យពួកគេបានជឿលើវា។ អ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យបានដឹងថា ការពិតដើម្បីដឹកនាំមនុស្សចូលទៅក្នុងព្រះអម្ចាស់គឺមានសារៈសំខាន់ និងបន្ទាន់ខ្លាំងណាស់។ នៅពេលដែលលោក ហាត់សិន ថេឡឺ ដែលជាអ្នកផ្សព្វផ្សាយដំណឹងល្អដំបូងគេនៅក្នុងប្រទេសចិនបានសម្រេចចិត្តក្លាយជាបេសកកជនរបស់ប្រទេសចិន គាត់មានការចាប់អារម្មណ៍ចំពោះតួលេខដែលមនុស្សពីរបីលាននាក់បានទម្លាក់ចូលទៅក្នុងនរកក្នុងរយៈពេលមួយនាទីនៅក្នុងក្រសៃភ្នែកនៃដួងចិត្តខាងវិញ្ញាណរបស់គាត់។ គាត់មិនអាចជួយបានក្រៅពីស៊ូទ្រាំ។ នៅពេល លោក វ៉ាយហ្វីលដ៍ ដែលជាអ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ បានបំពេញបេសកកម្មនៃការផ្សាយដំណឹងល្អ ដោយទទួលបានព្រះគុណ គាត់មានអារម្មណ៍ថា អ្វីៗទាំងអស់ដែលគាត់បានឃើញ និងស្តាប់បានបង្ខំគាត់ឱ្យធ្វើការប្រកាសដំណឹងល្អ។ ពេលនោះ អ្នកនេសាទដើម្បីឈ្នះចិត្តមនុស្សនោះ គឺធ្វើកិច្ចការយ៉ាងសំខាន់។ ត្រង់ចំណុចនេះ [នៅក្នុងនោះ អ្វីដែលយើងគួរគិតនោះគឺថា អ្នកនេសាទចាប់ត្រីពេញមួយជីវិតរបស់គាត់ តែមិនដូចគ្នានឹងការនេសាទមនុស្សទេ។ គាត់ប្រតិបត្តិការងារប្រកបដោយវិជ្ជាជីវៈ មិនថាចាប់ត្រីបានឬអត់ទេ។ អ្នកផ្សាយដំណឹងល្អបែបនោះ មិនមានមុខរបរអ្វីផ្សេងទៀតទេ ហើយគួរតែលះបង់ដើម្បីប្រកាសដំណឹងល្អ ហើយគួរមានវិជ្ជាជីវៈដើម្បីធ្វើវាផង។ បើអ្នកផ្សាយដំណឹងល្អមិនបន្តការងារតែមួយប្រកបដោយវិជ្ជាជីវៈទេ តែទៅធ្វើកិច្ចការផ្សេងទៀត នោះគាត់នឹងក្លាយជាអ្នកនេសាទដែលពុលរលួយ ប្តូរពីអ្នកនេសាទមនុស្ស ទៅជាអ្នកនេសាទត្រីវិញ។ អ្នកនេសាទមនុស្សត្រូវធ្វើការដ៏រុងរឿងដែលមិនអាចនិយាយបាន ប៉ុន្តែអ្នកនេសាទត្រីវិញ

ជាការងារវេទនាមិនអាចប្រៀបផ្ទឹមបាន។ អ្នកនេសាទមនុស្សអាចនិយាយបានថាជាការងារដូចជាជីវិត ប៉ុន្តែអ្នកនេសាទត្រីវិញជាការងារដូចស្លាប់។

2. សាវកទាំងបួននេះដើរតាមព្រះជាម្ចាស់ដោយមានអំណាច

អត្ថបទរបស់យើងមានបន្ទូលថា “គេក៏ទុកសំណាញ់ចោល ទៅតាមទ្រង់ភ្លាម។” ( ខ 20) ហើយក៏មានបន្ទូលថា “គេក៏លះបង់ទូក និងឪពុក ដើរតាមទ្រង់ជាមួយរំពេចទៅ។” (ខ 22) យើងអាចគិតពីការពីរយ៉ាងនៅទីនេះ។ មួយជាពាក្យថា “រំពេចនោះ” និងមួយទៀតពាក្យថា “ចាកចេញ”។ ពាក្យថា “រំពេចនោះ” បង្ហាញពីការសម្រេចចិត្តដែលពួកគេសម្រេចនៅក្នុងការដើរតាមព្រះយេស៊ូវ។ ការសម្រេចចិត្តធ្វើការត្រឹមត្រូវនោះជាការមានតម្លៃ។ ពីព្រោះអ្នកដែលស្ទាក់ស្ទើពីនេះពីនោះដោយគ្មានការសម្រេចចិត្តនឹងត្រូវបានកាត់បន្ថយទៅកាន់អារម្មណ៍នៃការធ្វើការត្រឹមត្រូវ តែក្រោយមកគេនឹងមានឥរិយាបថដែលខ្សោយ។ មនុស្សដែលធ្វើខ្លះដោយការគំនិតត្រូវរលាយដោយភ្លើង គួរតែត្រូវវាយដោយដែកយ៉ាងឆាប់។ បន្ទាប់មក យើងអាចគិតនូវពាក្យថា ចាក់ចេញ។ អ្នកដែលមានស្ថានសួគ៌គួរតែបោះចោលលោកិយ។ អ្នកដែលបោះចោលលោកិយមិនចង្អុលទៅកាន់ការអនុញ្ញាត តែចង្អុលទៅក្នុងលោកិយតែគាត់មិនបម្រើលោកិយទេ។ វាជាការត្រូវដែលអ្នកជឿអាចដើរតាមរយៈលោកិយនេះ និងប្រកាសព្រះបន្ទូលរបស់ព្រះ ធ្វើឱ្យមានឥទ្ធិពលលើវា និងចាប់វាកុំឱ្យធ្វើបាប។

3. ពីការដើរតាមព្រះគ្រីស្ទ

នៅក្នុងអត្ថបទរបស់យើងពាក្យថា “បានដើរតាម” ចេញមកពីដង។ (20, 22) មានន័យថាការដើរតាម និងចង្អុលទៅកាន់កិច្ចការនៃព្រះគ្រីស្ទគួរធ្វើ។ បើទោះជាអ្នកជឿ

ទូទៅមិនបោះចោលមុខរបរខាងរូបសាច់ គាត់អាចទទួលគុណសម្បត្តិដោយជឿដល់ព្រះគ្រីស្ទ។ តែអ្នកធ្វើការគួរតែបោះចោលកិច្ចការខាងរូបកាយ និងក្លាយជាអ្នកបម្រើដល់ព្រះគ្រីស្ទដោយចេញពីចិត្ត។ អ្នកដែលដើរតាមព្រះគ្រីស្ទនឹងលីឈើឆ្កាងខ្លួន។ បើទោះជាគាត់ជួបនូវផ្លូវដែលលំបាក និងការដូចជាសមុទ្រដែលមានរលូតបោកបក់កើតឡើង គាត់នៅតែដើរតាមផ្លូវនោះដដែល។ ហើយរបៀបបន្ទាប់របស់យើងជាអ្វីដែលយើងត្រូវគិតគឺការមួយនេះ នោះគឺអ្នកដើរតាមមិនគួរបង្កើតផែនការផ្ទាល់ខ្លួនរបស់គាត់ និងវិធីសាស្ត្ររបស់គាត់ទេ គឺគ្រាន់តែធ្វើតាមជើងរបស់អ្នកត្រួសត្រាយប៉ុណ្ណោះ។ យើងនិយាយថាដើម្បីដើរតាមព្រះគ្រីស្ទ ប៉ុន្តែពេលខ្លះយើងបង្ហាញផែនការដ៏ល្ងង់ខ្លៅរបស់យើងជាចម្បង។ វាមិនមែនជាការងាររបស់អ្នកដើរតាមទេ។ យើងគួរតែជឿព្រះបន្ទូលរបស់ព្រះគ្រីស្ទ ហើយគ្រាន់តែធ្វើតាមប៉ុណ្ណោះ។

**ការអធិប្បាយ  20 ការបង្រៀនមួយចំនួន និងអំណាច (ម៉ាថាយ 4:23-25 8:14-17 ម៉ាកុស 1:21-39 លូកា 4:31-44)**

ក្នុងកិច្ចការរបស់ព្រះយេស៊ូមានរឿងសំខាន់ពីរគឺការបង្រៀន និងអំណាចរបស់ទ្រង់។ ដូចដែលការបង្រៀនរបស់ទ្រង់គួរតែត្រូវបានប្រកាសដោយគ្មានការផ្អាក ពិភពលោកដែលត្រូវបានបំផ្លាញអាចកើនឡើងនៅលើផ្លូវនៃជីវិត។ ហេតុនេះហើយបានជាទ្រង់

បានយាងទៅមកគ្រប់ទីកន្លែង បង្រៀនទាំងនឿយហត់ និងគ្មានពេលហូបចុក។ ហើយអំណាចរបស់ទ្រង់គឺជាសកម្មភាពរួម

ដោយភ្ជាប់សិទ្ធិអំណាចនៃការបង្រៀនរបស់ទ្រង់ និងអត្ថន័យរបស់វា។

1. ការបង្រៀនរបស់ទ្រង់

ម៉ាកុស 1:22 មានបន្ទូលថា " "។ អំណាចនៃការបង្រៀនរបស់ទ្រង់នោះជាអំណាចរបស់ព្រះ។ ដូច្នេះ វាជាអំណាចដែលបង្ហាញពីចេស្តាខាងវិញ្ញាណ ដែលធ្វើឱ្យមនុស្សស្លាប់បានរស់ឡើង។ ការបង្រៀនរបស់ទ្រង់មិនមែនជាមេរៀនសាមញ្ញ និងការបង្ហាញជាអក្សរនោះទេ។ ព្រះបន្ទូលរបស់ទ្រង់ជាវិញ្ញាណ។ (យ៉ូហាន 6:63)។ អ្នកដែលស្តាប់ទៅកាន់ព្រះបន្ទូលរបស់ទ្រង់ប្រឈមមុខនឹងសិទ្ធិអំណាចដ៏ខ្ពស់ និងចេស្តាខាងវិញ្ញាណ ដែលមិនអាចប្រៀបធៀបជាមួយនឹងពាក្យរបស់ហោរាទេ។ ដូច្នេះ អ្នកដែលមិនស្តាប់ទៅកាន់ព្រះបន្ទូលទ្រង់ នោះនឹងត្រូវវិនាស។ ពីព្រោះព្រះបន្ទូលទ្រង់មានសារៈសំខាន់ណាស់ កាលដែលដើរទៅគ្រប់កន្លែងហើយប្រកាសវា។ ពីព្រោះព្រះបន្ទូលទ្រង់អស្ចារ្យណាស់ បន្ទាប់ពីអ្នកអធិប្បាយពិតប្រាកដរបស់ក្រុមជំនុំបង្ហាញពីអំណាចដ៏អស្ចារ្យដោយបានស្មោះត្រង់ទៅនឹងព្រះបន្ទូលទ្រង់។ ដូច្នេះ អ្នកអធិប្បាយពិតគិតថា ពេលវេលានៃការអធិប្បាយរបស់គាត់ជាពេលវេលាដែលគួរគាប់ និងជាពេលពេញដោយសិរីរុងរឿងបំផុត។ លោក ស្ពើជិន ចាត់ទុកពេលវេលានៃការអធិប្បាយរបស់គាត់នៅក្នុងន័យនេះថា ជាពេលវេលាភ្លក្សរស់ជាតិស្ថានសួគ៌នៅក្នុងពេលអធិប្បាយ។ លោក វ៉ាយហ្វីលដ៍ បានគិតថាកន្លែងអធិប្បាយរបស់គាត់ជាបល្ល័ង្ករបស់ស្តេច។

ដូចជាយើងបានដឹងហើយថាព្រះបន្ទូលរបស់ព្រះយេស៊ូវសំខាន់ខ្លាំងណាស់ នោះយើងគួរក្លាយជាគ្រូបង្រៀនព្រះបន្ទូល ដែលមុនពេលយើងប្រកាសព្រះបន្ទូលទៅកាន់មនុស្សទាំងអស់ នោះយើងមិនអាចសម្រាកបានទេ។ ពីព្រោះព្រះបន្ទូលទ្រង់ដែលជាព្រះគម្ពីរនោះ គឺយើងគួរមាននូវមហិច្ឆតាយ៉ាងធំដើម្បីនឹងប្រកាសគ្រប់ទាំងបទគម្ពីរដល់លោកិយទាំងមូល។ យើងគួរស្វែងរកពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ហើយប្រកាសព្រះបន្ទូលទៅកាន់ពួកគេ តែបន្ថែមលើនោះទៀត យើងគួរប្រកាសព្រះបន្ទូលតាមរយៈការប្រជុំជាសាធារណៈ។ មិនត្រឹមតែប៉ុណ្ណោះ យើងគួរប្រកាសព្រះបន្ទូលទ្រង់តាមរយៈសារពាង្គកាយដែលបានបង្កើតមកជាប្រព័ន្ធ ជាបន្តទៀតតាមប្រព័ន្ធជាច្រើន។ នាពេលបច្ចុប្បន្ននេះ យើងគួរប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈវិទ្យុប្រព័ន្ធផ្សព្វផ្សាយដោយប្រើការថតទុក និងប្រព័ន្ធឃោសនាយ៉ាងរហ័សនិងធំទូលាយ។ ជាពិសេស អ្វីដែលយើងគួរគិតនោះគឺ យើងត្រូវការសកម្មភាពដែលប្រកាសសៀវភៅនៃការផ្សាយដំណឹងល្អជាសន្ទឹកតាមរយៈយន្តហោះ។ ប្រសិនបើយន្តហោះត្រូវបានយលទៅប្រើសម្រាប់សង្គ្រាម តើយើងនឹងប្រើរបៀបណាដើម្បីនឹងដឹកជញ្ជូនរបស់សម្រាប់ជួយមនុស្សនោះ? នៅត្រង់ចំណុចនេះ អ្វីដែលយើងគួរប្រយ័ត្ននោះ គឺជាការពិតដែលត្រូវបានប្រើដើម្បីសម្រួលដល់ប្រជាជននៅក្នុងការប្រៀបធៀបទៅនឹងទុក្ខលំបាកនៃការផ្សាយដំណឹងល្អ។ វាគួរតែត្រូវបានគ្រប់គ្រងវិធីតូចៗបន្ថែមទៀត។ និយាយមួយបែបទៀតគឺ យើងគួរធ្វើចលនានៃការផ្សាយដំណឹងល្អ នោះយើងនឹងទទួលបានការសម្រាលយ៉ាងធំដោយផ្តោតលើការផ្តល់នូវការលះបង់ដែលធំជាង។ បើគ្មានការផ្តោតលើការលះបង់ទេ ចលនានឹងផ្តោតលើការសម្រួលដល់ប្រជាជននោះនឹងប្រៀបបានដូចជាសម្លេងឃ្មោះទទេរ។ យើងរស់នៅក្នុងឥរិយាបថមួយដែលប្រើវប្បធម៌នាពេលបច្ចុប្បន្នសម្រាប់ផ្សាយដំណឹងល្អ។ ដូច្នេះ យើងគួរទទួលអំណាចយ៉ាងអស្ចារ្យ

ដោយការអធិស្ឋាន ការសិក្សាព្រះបន្ទូល និងការអនុវត្តវាដោយមានការលះបង់យ៉ាងធំផង។

2. ពីការប្រើប្រាស់អំណាចមួយចំនួន

នៅពេលដែលយើងយល់ព្រះបន្ទូលនេះបានត្រឹមត្រូវ ហើយជឿលើ នោះនឹងប្រកាសវាដោយស្មោះត្រង់ នោះអំណាចនឹងត្រូវបានបង្ហាញយ៉ាងពិតប្រាកដ។ ដូច្នេះ ដោយសារព្រះយេស៊ូវជាព្រះ ព្រះបន្ទូលរបស់ទ្រង់គឺជាព្រះបន្ទូលនៃព្រះ នៅទីកន្លែងណាដែលទ្រង់បានបង្រៀន នោះអំណាចគួរត្រូវបានបើកសម្តែងឱ្យឃើញច្បាស់។ ពេលដែលគាត់បង្រៀននៅសាលាប្រជុំ អារក្សកខ្វក់ក៏បានសារភាពថា ព្រះយេស៊ូជាព្រះដ៏បរិសុទ្ធរបស់ព្រះ។ ទ្រង់បានព្យាបាលឱ្យជាសះស្បើយពីជំងឺរ៉ាំរ៉ៃជាច្រើន។(ម៉ាថាយ 4:24) ជំងឺដែលព្រះយេស៊ូវបានប្រោសឱ្យជា ជាការដែលអំណាចនៃមនុស្សមិនអាចព្យាបាលបានទេ។ វាគឺជាច្បាប់ទូទៅដែលអំណាចនៃព្រះត្រូវបានបង្ហាញដោយការជួបនឹងរឿងដែលមនុស្សមិនអាចធ្វើបាន។ ដោយសារព្រះធ្វើអ្វីដែលមនុស្សអាចធ្វើបាន នោះមនុស្សនោះមិនដឹងថាព្រះបានធ្វើអ្វីនោះទេ។ នៅពេលយើងសរសេរសំបុត្រនៅលើក្រដាសសដោយប្រើទឹកខ្មៅ វាត្រូវបានបង្ហាញយ៉ាងល្អ។ ដូចជាអំណាចនៃព្រះធ្វើការចំពោះកម្មវត្ថុដែលមនុស្សមិនអាចធ្វើបាន។ ដូច្នេះ វាជារឿងធម្មតាដែលយើងគួរតែពឹងផ្អែកលើព្រះឱ្យបានកាន់តែច្រើន នៅពេលដែលយើងជួបនឹងរឿងលំបាកកាន់តែខ្លាំង។ ការពិតដែលថាព្រះអម្ចាស់បានប្រោសអ្នកជំងឺគឺមិនខុសពីការព្យាបាលចិត្តដែលគ្រីស្ទាននាសម័យនេះ សាសនាខាងវិទ្យាសាស្ត្រដែលបានយល់ខុសពីបទគម្ពីរខុសហើយផ្តោតលើព័ន្ធកិច្ចនៃការព្យាបាល។

វិធីសាស្ត្រនៃការព្យាបាលផ្លូវចិត្តធ្វើឱ្យអ្នកជំងឺមិនគិតអ្វីអំពីជំងឺនេះ ហើយបានជាសះស្បើយពីជំងឺ។ ហើយគេអះអាងថា មនុស្សខ្លះត្រូវព្យាបាលដោយវិធីបែបនេះ។ ប៉ុន្តែព្រឹត្តិការណ៍នៃការព្យាបាលដែលព្រះយេស៊ូវបានប្រោសគឺបានកើតឡើងដោយព្រះចេស្តានៃព្រះយេស៊ូវ ប៉ុន្តែមិនបានព្យាបាលដោយការព្យាបាលផ្លូវចិត្តរបស់អ្នកជំងឺនោះទេ។ មិនត្រឹមតែប៉ុណ្ណោះ ការដែល ព្រះយេស៊ូវព្យាបាលជម្ងឺនេះគឺមានគោលបំណងចំបង ប៉ុន្តែវាមិនមែនដើម្បីភាពងាយស្រួលរបស់មនុស្សនោះទេ។ ហើយកិច្ចការដែលព្រះយេស៊ូវបានព្យាបាលជំងឺនេះបានធ្វើឱ្យមនុស្សដែលបានប្រោសឱ្យជានេះបានស្គាល់ព្រះ ហើយលើកសរសើរតម្កើងដល់ទ្រង់។ ហើយការដែលព្រះយេស៊ូវបានប្រោសជំងឺនេះមិនមែនជាកិច្ចការសំខាន់នៃកិច្ចបម្រើផ្សាយរបស់ទ្រង់ទេ គឺគ្រាន់តែជាការងារបន្ថែមប៉ុណ្ណោះ។ ដូច្នោះហើយ វាអាចទៅរួចដែលថាវានៅក្នុងការប្រកាសដំណឹងល្អគឺជាការងារបន្ថែមប៉ុណ្ណោះ ប៉ុន្តែវាមិនត្រឹមត្រូវទេដែលវាត្រូវបានទទួលស្គាល់ថាជារឿងខាងលើស្ថិតនៅក្នុងកម្រិតដូចគ្នានៃកិច្ចការរបស់មនុស្សនោះ។ ដូច្នេះប៉ូលបាននិយាយថា“ “(១កូរិនថូស 1:22) ហើយទទួលយកចំណុចកណ្តាលនៃការអស្ចារ្យដោយជៀសមិនរួច។ នេះត្រូវបានហៅថាជាការអស្ចារ្យដ៏មានតម្លៃ។ ដោយសារតែវាជាលក្ខណៈដែលការអស្ចារ្យមិនគួរត្រូវបានបង្ហាញច្រើននោះទេ។ នៅពេលដែលការអស្ចារ្យកើតឡើងច្រើន វានឹងក្លាយជារឿងទូទៅ ហើយវាបាត់បង់ប្រតិបត្តិការនៃការអស្ចារ្យដែលកើតឡើងនូវព្រឹត្តិការណ៍ដ៏អស្ចារ្យ។ ដូច្នេះ ព្រះយេស៊ូវបានប្រោសជំងឺដោយឫទ្ធានុភាពនៃព្រះ ប៉ុន្តែទ្រង់មិនបានគិតថា កិច្ចការព្យាបាលជំងឺត្រូវបង្ហាញដល់គ្រប់មនុស្សនោះឡើយ។ ប្រសិនបើអ្នកណាដែលគិតធ្វើការអស្ចារ្យដោយធ្វេសប្រហែស អ្នកនោះមានគំនិតផ្សេងទៀតរបស់ព្រះយេស៊ូវ។ ក្នុងនាមជាអ្នកដែលមានគំនិតបែបនេះសម្រាប់ព័ន្ធកិច្ចនៃការព្យាបាល យើងពិបាកទទួលយកគាត់

ណាស់។ អ្នកណាដែលដើរតាមគំនិតបែបនេះ មុខជាធ្វើទុក្ខទោសដល់ក្រុមជំនុំយ៉ាងខ្លាំង។

ក្នុងព្រះវិហារកូរ៉េបច្ចុប្បន្ន យើងគិតអំពីអ្នកព្យាបាលជំងឺដូចខាងក្រោម។

1) ប្រសិនបើពួកគេព្យាបាលជម្ងឺរបស់មនុស្សមួយចំនួនពិតប្រាកដដោយចេស្ដារបស់ព្រះ យើងអាចនិយាយថាវាជាការដែលគួរអរព្រះគុណដល់ព្រះ។

2) តែជាការគួរសោកស្ដាយដែលយើងដឹង បន្ទាប់ពីគាត់បានព្យាបាលជម្ងឺនរណាម្នាក់ នោះមានពាក្យចចាមអារ៉ាមដែលផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយត្រូវបានបង្ហាញយ៉ាងច្បាស់នូវការពិតថា ជម្ងឺរបស់គាត់មិនត្រូវបានជាលះពេញលេញនោះទេ។ ការនោះនឹងធ្វើឱ្យភាពថ្លៃថ្នូរបស់សាសនាគ្រីស្ដធ្លាក់ចុះ មិនត្រឹមតែប៉ុណ្ណោះការនេះនឹងធ្វើឱ្យគេសំដៅទៅរកទិសដៅនៃការដេញតាមនូវការសង្ស័យជាងការស្ដាប់ស្គាល់ដោយសារសេចក្ដីពិតនៃដំណឹងល្អដែលពឹងលើព្រះបន្ទូលនៅក្នុងព្រះគម្ពីរទៅវិញ។ គឺប្រៀបដូចជាការនោះ ដែលមនុស្សចូលចិត្តតែទៅរកការអស្ចារ្យ ដែលជាចរិតមួយដែលគ្រោះថ្នាក់ដែលចង់តាមរកការដែលគួរឱ្យចង់ដឹងមួយចំនួនដោយមិនមានការពិចារណា។

នៅគ្រារបស់ក្រុមជំនុំ ការអស្ចារ្យដែលព្យាបាលជំងឺអាចកើតឡើង ប៉ុន្តែជាចម្បងគឺការអស្ចារ្យដែលផ្ដល់ឱ្យ ប៉ុន្តែមិនមែនជាការអស្ចារ្យនៃការបង្កើតដូចព្រះយេស៊ូវនោះទេ។ នេះត្រូវបានបញ្ជាក់ដោយការពិតពីប្រវត្តិសាស្ត្រ។ ប៉ុន្តែពាក្យរបស់ខ្ញុំមិនមានន័យថាជាការបដិសេធលទ្ធភាពដែលការអស្ចារ្យនៃការបង្កើតមិនអាចកើតឡើងដោយព្រះហឫទ័យរបស់ព្រះនិងអំណាចរបស់ទ្រង់នោះទេ។ ប៉ុន្តែនៅពេលយើងនិយាយអំពីផែនការរបស់ព្រះ ដោយសារគ្រានៃការបើកសម្ដែង គឺជាការបង្កើតមូលដ្ឋានគ្រឹះនៃការ

បើកសម្តែង វាត្រូវការការអស្ចារ្យថ្មៃដែលបង្កើតឡើង គ្រានៃក្រុមជំនុំ ប៉ុន្តែដោយសារគ្រានៃក្រុមជំនុំគឺជាពេលវេលាដើម្បីស្ថាបនាសំណង់អាគារដែលស្ងប់ស្ងាត់នៅលើគ្រឹះដែលត្រូវបានរៀបចំរួចហើយ វាគ្រប់គ្រាន់ដោយគ្រាន់តែទទួលយកការអស្ចារ្យដែលផ្តល់ជំនួយមកប៉ុណ្ណោះ។ ការអស្ចារ្យដោយបានកំណត់មករបស់ព្រះខុសពីការដែលកើតឡើងដោយច្បាប់ធម្មជាតិ ដូច្នេះជាអព្ភូតហេតុដែលកើតឡើងដោយចូលរួមរបស់ព្រះ វាចង្អុលទៅកាន់ស្ថានភាពដែលបានកើតឡើងដោយការអស្ចារ្យពិសេសជាមួយនឹងរឿងដែលសំខាន់និងច្បាប់របស់វា។

ឧទាហរណ៍ ការពិតដែលម្តាយក្មេករបស់ពេត្រុសបានឈឺក្រុនក្តៅ និងត្រូវបានព្យាបាលឱ្យជាដោយចេស្តារបស់ព្រះយេស៊ូវ ភ្លាមនោះគាត់បានក្រោកមកហើយបម្រើដល់ព្រះជាម្ចាស់ នោះហៅថាជាការអស្ចារ្យដែលបង្កើតឡើង នៅពេលបច្ចុប្បន្ននេះយើងអធិស្ឋានសម្រាប់អ្នកជម្ងឺណាមួយ ជម្ងឺខ្លះត្រូវបានជាសះស្បើយដោយព្រះគុណរបស់ព្រះ នោះគេនឹងបានក្រោកឡើងភ្លាម និងចាប់ផ្តើមបម្រើដូចជាម្តាយក្មេករបស់ពេត្រុសបានធ្វើដែរ តែយ៉ាងណាក៏ដោយ ការពិតដែលសុខភាពត្រូវបានសះស្បើយបន្តិចម្តងៗមួយរយៈក្រោយជាការអស្ចារ្យដែលព្រះបានកំណត់មក។

## ការអធិប្បាយ 21 ចូរយើងរៀនពីការអធិស្ឋានរបស់ព្រះអម្ចាស់ (ម៉ាកុស 1:35-39)

ការពិតដែលព្រះយេស៊ូវបានអធិស្ឋាននៅពេលព្រលឹមគឺជាការថ្វាយពេលដ៏ល្អបំផុតទៅកាន់ព្រះ ហើយអធិស្ឋាននៅកន្លែងស្ងាត់ជាការទំនាក់ទំនងទៅកាន់ព្រះតែមួយអង្គគត់។ យើងតែងតែធ្វើការខាងលោកិយជាមុន ហើយពេលដែលសេសសល់ទើបយើងអធិស្ឋាន។ មិនតែប៉ុណ្ណោះ យើងគ្មានការខ្វល់ខ្វាយដូច្នេះនៅក្នុងចិត្តដែលចង់អធិស្ឋាន ហើយវាត្រូវច្របូកច្របល់នឹងសម្លេងរញ៉េរញ៉ៃពីលោកិយមក។ វាជាសញ្ញាដែលថាយើងមិនអើពើនឹងការអធិស្ឋាន។ ចូរយើងរៀនពីការអធិស្ឋានរបស់ព្រះយេស៊ូវ។ យើងគួររក្សាការមួយចំនួននៅក្នុងគំនិតរបស់យើងថា មិនត្រូវមិនអើពើនឹងការអធិស្ឋានទេ តែត្រូវអធិស្ឋានដោយចេញពីចិត្តវិញ។

1. យើងគួររក្សានៅក្នុងគំនិតយើងថាការមិនអើពើនឹងការអធិស្ឋានជាអំពើបាបយ៉ាងធំ

កាលដែលយើងមិនអើពើនឹងការអធិស្ឋាន និងខ្ជិលច្រអូសនឹងធ្វើវា នោះការអាក្រក់នឹងកើតឡើង។ 1) ជំនឿរបស់គាត់នឹងកាត់បន្ថយបន្តិចម្តងៗ 2) វាធ្វើឱ្យយើងមានគ

ម្លាតឆ្ងាយ 3) គេនឹងមិនចាត់ទុកថាបាបនោះជារឿងធ្ងន់ធ្ងរទេ តែខំជៀសវាងតែអំពើបាបណាដែលធំដែលនឹងនាំមកនូវលទ្ធផលដ៏គួរឱ្យខ្លាចនៅក្នុងជីវិតរូបកាយដូចជាអ្នកមិនជឿ។ 4) គេនឹងក្លាយជាផារីស៊ីដែលរក្សាដោយខំប្រឹងនូវមុខមាត់ថាជាអ្នកជឿ។ អំពើបាបដែលមិនអើពើនឹងការអធិស្ឋាន នោះជាការហ្វឹកហាត់អំណាចនៃអំពើបាប។ ពេលនេះយើងដឹងពីការពិតនេះ យើងមានការសម្រេចចិត្តថា យើងត្រូវអធិស្ឋានឱ្យអស់ពីចិត្ត។

2. កាលដែលយើងដឹងពីវិធីសាស្ត្រអធិស្ឋាន និងច្បាប់របស់វា យើងនឹងមិនស្អប់វាទេ ហើយយើងអាចថ្វាយការអធិស្ឋានដោយអស់ពីចិត្តផង

ដោយយើងមិនដឹងវិធីសាស្ត្រក្នុងអ្វីទាំងអស់ យើងគ្មានចំណង់ចំណូលចិត្ត ហើយក៏មិនអនុវត្តឱ្យបានល្អ។ ខ្ញុំបានហ្វឹកហាត់កីឡាវាយកូនបាល់ ប៉ុន្តែខ្ញុំរៀនវិធីសាស្ត្រមិនបានល្អ ខ្ញុំមិនបានអនុវត្តដូចវិធីសាស្ត្រនោះទេ ដោយខ្ញុំព្យាយាមធ្វើវាតិចតួច ខ្ញុំមិនប្រកាន់ចំណង់ចំណូលចិត្ត និងមិនបានបន្តធ្វើវា។ ដូចនេះដែរ បើយើងមិនបានទទួលការបង្ហាត់បង្រៀនដោយច្បាប់នៃការអធិស្ឋានទេ យើងមិនគិតថាយើងគួរអធិស្ឋានដោយឧស្សាហ៍ព្យាយាម ហើយក៏បាត់បង់ការចាប់អារម្មណ៍របស់យើងឡើយ។ លោកហាលីស្បី បាននិយាយថា "ការអធិស្ឋានគឺជាសិល្បៈនៅក្នុងសិល្បៈទាំងអស់"។ នោះគឺថាការអធិស្ឋានគឺជាការងារដ៏ស្រស់ស្អាត ដែលមិនមែនដោយវោហាសាស្ត្រ និងសោភ័ណភាពទេ ប៉ុន្តែជាការងារដែលធ្វើឡើងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធតាមច្បាប់នៃព្រះបន្ទូលរបស់ព្រះ។ វាជាការងារដែលចេញពីមាត់របស់អ្នកនិយាយមិនច្បាស់។

នៅក្នុងវិធីសាស្ត្រនេះ អ្វីដែលយើងគិតគឺមានពីរយ៉ាងខ្លាំង។ ទីមួយ យើងអធិស្ឋានតាមរបៀបដែលព្រះបន្ទូលនៃបទគម្ពីរបានបង្រៀនអំពីការអធិស្ឋាន ទីពីរដោយអធិស្ឋានច្រើន ដូច្នេះយើងគួរត្រូវបានហ្វឹកហាត់។ ទម្លាប់នេះត្រូវបានគេហៅថាអាកប្បកិរិយាសញ្ញាតិទីពីរ។ សំខាន់ជាងនេះទៅទៀត ការអធិស្ឋានរបស់យើងគួរតែនៅជាមួយព្រះដោយសុភាព ប្រាស្រ័យទាក់ទងគ្នាយ៉ាងស្និទ្ធស្នាលជំនាញ ហើយគួរតែមានចលនាដែលទន់ភ្លន់ និងសកម្មភាពរស់នៅ។

អ្វីទៅជាវិធីសាស្ត្រនៃការអធិស្ឋានដែលព្រះគម្ពីរបង្រៀន?

វាបង្រៀនវិធីសាស្ត្រជាច្រើនដល់យើង។ សំខាន់ជាងនេះទៅទៀត សេចក្តីជំនឿគឺជារឿងសំខាន់។ អ្វីដែលយើងគួរគិតដល់ចំណុចនេះគឺចំណុចនេះជាពិសេស។ នោះគឺការអធិស្ឋានខ្លួនឯងមិនគួររៀបចំការពិតអំពីរបៀបដែលព្រះឆ្លើយតបនឹងសូមរបស់យើងទេ។ មានតែបញ្ហាបែបនេះទេដែលគួរប្តេជ្ញាចំពោះព្រះដែលគេគួរតែទូលសុំតែចំពោះព្រះប៉ុណ្ណោះ។ មិនត្រឹមតែប៉ុណ្ណឹងទេ អ្នកទូលសូមមិនគួរខ្វល់ខ្វាយ ថាតើការសម្រេចវាលំបាកឬអត់។ ការគិតបែបនោះវាមិនចាំបាច់ទេ ហើយជាការគ្មានជំនឿរិញ។ ត្រង់ចំណុចនេះ យើងគួររៀនវាដោយគិតអំពីការពិតដែលថានៅក្នុងយ៉ូហានជំពូកទី 2 របៀបដែលមាតារបស់ព្រះយេស៊ូវបានអធិស្ឋាន។ ឥឡូវនេះ សូមយើងគិតអំពីអ្វីដែលយ៉ូហាន ជំពូកទី 2 បើកបង្ហាញ បន្តិចទៀត។

នៅទីនោះ មាតារបស់ព្រះយេស៊ូគ្រាន់តែប្រាប់អំពីបញ្ហាលំបាកនៃផ្ទះអាពាហ៍ពិពាហ៍ដល់គាត់ នាងមិនបានរៀបចំផែនការពីរបៀបដែលព្រះយេស៊ូវសម្រេចនូវបញ្ហានៃការស្នើសុំរបស់គាត់នោះទេ។

**ការអធិប្បាយ  22 អំពីការផ្តល់មេត្តា (ម៉ាថាយ 5:7)**

“មានពរហើយអស់អ្នកដែលមានចិត្តមេត្តាករុណា  ដ្បិតអ្នកទាំងនោះនឹងទទួលបានសេចក្តីមេត្តាករុណាវិញ។”

1. សេចក្តីមេត្តាករុណានាំមកនូវដោយអារម្មណ៍ពីទ្រព្យសម្បត្តិរបស់គេ

1) កាលដែលអ្នកជឿត្រូវបានគេស្គាល់ថាជាម្នាក់ដែលរីករាយនឹងមរតករបស់ព្រះ  នោះគេនឹងដឹងពីភាពស្តុកស្តម្ភរបស់គេ។  ប៉ុលបានបង្រៀនដោយចង្អុលទៅខ្លួន

គាត់ថា “ដូចជាមានក្ដីព្រួយ តែចេះតែបានសប្បាយវិញ ដូចជាទាល់ក្រ តែកំពុងតែចម្រើនដល់មនុស្សជាច្រើន ដូចជាគ្មានអ្វីសោះ តែមានគ្រប់ទាំងអស់វិញ។” (២កូរិនថូស 6:10) អ្នកដែលមានព្រះគឺប្រសើរជាងអ្នកមានដែលមានផែនដីទាំងមូលផង។ គ្រប់ការទាំងអស់នៅលើផែនដីនឹងធ្វើចលនាសម្រាប់ប្រយោជន៍របស់គេ។

2) មិនត្រឹមតែប៉ុណ្ណោះ អ្នកជឿមានការខាងវិញ្ញាណនៅពេលបច្ចុប្បន្ន។ ការខាងវិញ្ញាណមានតម្លៃជាងសម្ភារៈដាច់។ តែមនុស្សដែលមិនដឹងការពិតនេះដែលនៅលើផែនដីនេះ តើគេមិនវេទនាទេឬអី? អ្នកដែលដឹងពីការខាងវិញ្ញាណពិតជាមានតម្លៃណាស់ ហើយអ្នកដែលមានវានឹងបោះចោលអ្វីទាំងអស់ដែលនៅលោកិយចាត់ទុកដូចជាដីឥដ្ឋវិញ។ យោងតាម ហេព្រើ 11:24-26។

2. សេចក្ដីមេត្តាករុណាកើតឡើងដោយការដើរតាមព្រះយេស៊ូវ

ដោយសារព្រះយេស៊ូវផ្ដល់សេចក្ដីមេត្តាករុណាដល់អ្នកក្រ នោះទ្រង់បានយាងមកនៅក្នុងលោកិយ។ បើទោះជាងាយនឹងស្អប់មនុស្សមានបាប តែវាពិបាកនឹងផ្ដល់មេត្តាដល់ពួកគេណាស់។ តែព្រះទ្រង់ចង់ឱ្យយើងផ្ដល់សេចក្ដីមេត្តាករុណាដល់មនុស្សមានបាប។ ដោយសារមនុស្សត្រូវបានរងគ្រោះដោយអំពើបាប អ្នកដែលខិតចូលទៅជិតអំពើបាបជាមនុស្សដែលវេទនាបំផុត។ ដូច្នេះ ជំនួសឱ្យយើងយំសម្រាប់ពួកគេ បែជាយើងស្អប់ពួកគេវិញ។ ហេតុអ្វីយើងគ្មានចិត្តដែលយំសង្រេងសម្រាប់មនុស្សមានបាប? គ្រូគង្វាលដ៏អស្ចារ្យម្នាក់ជនជាតិស្កុតម្នាក់ឈ្មោះ ម៉ាឆែន បានយំសង្រេងដោយសារមនុស្សមានបាប។

## ការអធិប្បាយ 23 ការបង្កើតសេចក្តីសុខសាន្ត (ម៉ាថាយ 5:9)

1. សេចក្តីសុខសាន្តធ្វើឱ្យចម្រើនឡើងក្នុងគ្រប់ការទាំងអស់

1) ពេលដែលយើងមានសេចក្តីសុខសាន្ត នោះកិច្ចការរបស់យើងនឹងបានល្អ ដោយសារវាមានចេស្តា

2) កាលដែលយើងមានសេចក្តីសុខសាន្ត កិច្ចការរបស់យើងនឹងបានល្អដ្បិតព្រះទ្រង់ប្រទានពរដល់យើង។

នៅកន្លែងដែលយើងមានការរួបរួមគ្នា ព្រះយេស៊ូវទ្រង់មានបន្ទូលថា “មួយទៀត ខ្ញុំប្រាប់ថា បើសិនជាមាន២អ្នកក្នុងពួកអ្នករាល់គ្នា ព្រមព្រៀងគ្នានៅផែនដី ពីដំណើរអ្វីដែលគេចង់សូមក៏ដោយ នោះនឹងបានសំរេចដល់គេ អំពីព្រះវរបិតាខ្ញុំ ដែលគង់នៅស្ថានសួគ៌។ ដ្បិតកន្លែងណាដែលមាន២ឬ៣អ្នក ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្តាលចំណោមអ្នកទាំងនោះដែរ។” (ម៉ាថាយ 18:19, 20)

2. ការបង្កើតសេចក្តីសុខសាន្តជាការរីករាយ និងមានអំណរ

នេះជាអ្វីដែលព្រះគម្ពីរមានបន្ទូលជាច្រើន។ ហេតុអ្វីបានជាអាណាចក្ររបស់ព្រះជាអាណាចក្រដែលល្អ? ពីព្រោះវាជានគរនៃសេចក្តីស្រឡាញ់។ (១កូរិនថូស 13:13) ពាក្យថា បង្កើតសេចក្តីសុខសាន្តត្រូវបានលេចមកនៅក្នុងព្រះគម្ពីរជាច្រើនដង នៅក្នុង

នោះមានការមួយចំនួនត្រូវបានបង្ហាញមកដូចតទៅ។ នោះគឺ “បើមានតែបាយក្រៀម ១ដុំ ដែលនឹងបរិភោគដោយសេចក្តីសុខ នោះវិសេសជាងមានផ្ទះពេញដោយការជប់លៀង តែមានសេចក្តីទាស់ទែងគ្នាវិញ។” (សុភាសិត 17:1) , “ស៊ូឱ្យមានតែបន្លែជាម្ហូបនៅកន្លែងណាដែលមានសេចក្តីស្រឡាញ់ ជាជាងមានសាច់គោដែលបំប៉នឱ្យធាត់ ហើយមានសេចក្តីសំអប់វិញ។” (សុភាសិត 15:17) “ស៊ូអាស្រ័យនៅក្នុងទីសូន្យស្ងាត់ ជាជាងនៅជាមួយនឹងស្ត្រីដែលចេះតែរករឿង ហើយអុចអាលវិញ។”(សុភាសិត 21:19) និង “ស៊ូនៅក្នុងទីកៀន១នៅលើដំបូលផ្ទះ ជាជាងនៅក្នុងផ្ទះធំទូលាយជាមួយនឹងស្ត្រីដែលចេះតែរករឿង។” (សុភាសិត 25:24) និង “ទឹកដែលស្រក់ចុះតក់ៗជានិច្ច នៅថ្ងៃភ្លៀងច្រើន ហើយស្ត្រីដែលចេះតែរករឿង នោះក៏ដូចគ្នា។ អ្នកណាដែលចង់ឃាត់នាង នោះឃាត់តែខ្យល់ទេ ហើយដៃអ្នកនោះចាប់ក្តាប់ប្រេងប៉ុណ្ណោះ។” (សុភាសិត 27:15, 16)

3. ហេតុផលនៃការបែកបាក់គ្នា

1) ការបែកបាក់គ្នាដោយការប្រច័ណ្ឌ និងការច្រណែនគ្នា។ “ឯជីវិតរបស់សាច់ឈាម នោះគឺជាចិត្តដែលស្ងប់រំងាប់ តែចិត្តច្រណែនជាសេចក្តីពុករលួយដល់ឆ្អឹងវិញ។” (សុភាសិត 14:30)

2) ការបែកបាក់គ្នាដោយការក្រអឺតក្រទម

“ផលនៃសេចក្តីឆ្មើងឆ្មៃ នោះមានតែការទាស់ទែងគ្នាប៉ុណ្ណោះ តែប្រាជ្ញាស្ថិតនៅនឹងពួកអ្នកដែលស្តាប់តាមសេចក្តីទូន្មាន។” (សុភាសិត 13:10)

3) ការបែកបាក់គ្នាដោយគ្មានការអត់ទោស

ព្រះគម្ពីរមានបន្ទូលថា អ្នកផ្តល់ឱ្យនោះមានពរជាងអ្នកដែលទទួល។ គឺថា កិច្ចការ 20:35 មានបន្ទូលថា “ខ្ញុំបានបង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរឱ្យខំធ្វើការដូច្នោះ ដើម្បីឱ្យបានជួយដល់ពួកអ្នកខ្សោយ ហើយនិងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានព្រះបន្ទូលថា ដែលឱ្យ នោះបានពរជាជាងទទួល។”

4) ការបែកបាក់គ្នាដោយគ្មានការប្រែចិត្ត

“អ្នកណាដែលត្រូវបន្ទោសជាញយៗ តែតាំងចិត្តរឹងវិញ នោះត្រូវវិនាសក្នុង១រំពេចទាល់បើជួយផង។” (សុភាសិត 29:1) “ឯការដែលស្តាប់ពាក្យបន្ទោសនៃមនុស្សមានប្រាជ្ញានោះវិសេសដល់មនុស្ស ជាជាងស្តាប់បទចំរៀងរបស់ពួកល្ងីលើ។” (សាស្តា 7:5)

5) ការបែកបាក់គ្នាដោយទទួលយកពាក្យសម្តីដែលចំអក

6) “ការដែលចាបហើរទៅបាត់ ហើយសត្វត្រចៀកកាំចេះតែហើរទៅមកយ៉ាងណា នោះសេចក្តីបណ្តាសាឥតហេតុ មិនទំជាប់ឡើយក៏យ៉ាងនោះដែរ។” (សុភាសិត 26:2) “អ្នកណាដែលមិនព្រមស្តាប់ពាក្យប្រៀនប្រដៅ នឹងត្រូវក្រលំបាក ហើយអៀនខ្មាសទៅ តែអ្នកណាដែលព្រមស្តាប់តាមសេចក្តីបន្ទោសវិញ នោះនឹងបានកិត្តិសព្ទ។” (សុភាសិត 13:18) “កុំឱ្យបន្ទោសដល់មនុស្សដែលតែងតែមើលងាយឡើយ ក្រែងគេស្អប់ឯង ត្រូវឱ្យបន្ទោសដល់មនុស្សប្រាជ្ញវិញ គេនឹងស្រឡាញ់ឯង។”(សុភាសិត 9:8) “ត្រចៀកណាដែលស្តាប់តាមសេចក្តីបន្ទោសនៃជីវិត នោះនឹងអាស្រ័យនៅជាកណ្តាលពួកអ្នកប្រាជ្ញ។” (សុភាសិត 15:31)

4. វិធីសាស្ត្រនៃសេចក្តីសុខសាន្ត

សេចក្តីសុខសាន្តត្រូវបានសម្រេចដោយការអត់ទោសកំហុសឱ្យគ្នាទៅវិញទៅមក។ ព្រះទ្រង់បានអត់ទោសអំពើបាបដល់មនុស្ស។ "សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ។" (ម៉ាថាយ 6:12)។

"ដ្បិតបើអ្នករាល់គ្នាអត់ទោសចំពោះការរំលងច្បាប់ ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងអត់ទោសឱ្យអ្នករាល់គ្នាដែរ។ តែបើអ្នករាល់គ្នាមិនអត់ទោស ចំពោះការរំលងច្បាប់ឱ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោស ចំពោះការរំលងច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ។" (ម៉ាថាយ 6:14, 15) យើងគួរចងចាំថា អ្វីដែលយើងអត់ទោសដែលចេញមកពីវិធីសាស្ត្ររបស់មនុស្ស អ្វីដែលយើងទទួលការអត់ទោសជាច្រើនពីបាបនោះជាវិធីសាស្ត្ររបស់ព្រះ។ កាលដែលយើងអត់ទោសបាបដល់អ្នកផ្សេង យើងគួរធ្វើឱ្យបានពេញលេញ។ លោក ស្ទើជិន និយាយថា "នៅពេលអ្នកកាប់ផ្តៃឆ្កួត កុំទុកឱ្យកន្ទុយរបស់វានៅលើដី"។

# ការអធិប្បាយ 24 ពីការពិតដែលគេបៀតបៀនដល់ព្រះយេស៊ូវ (ម៉ាថាយ 5:10-12)

កាលដែលការវេទនាមកលើយើង យើងនិយាយថាវាមិនសប្បាយទេ តែការស្លាប់នៅក្នុងព្រះអម្ចាស់តែមួយគត់ជាការមានពរ និងមានតម្លៃណាស់។ ទំនុកដំកើង 116:15 មានបន្ទូលថា “ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះយេហូវ៉ាជាការវិសេសដល់ព្រះនេត្រទ្រង់”

1. ហេតុផលដែលយើងគួរទទួលការបៀតបៀនដោយអំណរគឺមានដូចតទៅនេះ ៖

1) កាលដែលអ្នកជឿត្រូវគេបៀតបៀន ហេតុផលដែលត្រូវស៊ូទ្រាំរហូតដល់ស្លាប់នោះគឺដោយសារព្រះបន្ទូលរបស់ព្រះ។

(1) ពីព្រោះព្រះបន្ទូលរបស់ព្រះពិតជាពេញដោយសិរីរុងរឿងណាស់ អ្នកដែលជឿព្រះបន្ទូលនោះទទួលបានព្រះពរដែលរាល់មិនអស់។ ព្រះពរដែលព្រះបន្ទូលសន្យាមិនមែនមួយ ឬមិនមែនពីរ តែរាប់មិនអស់ បើទោះជាអ្នកដែលស្គាល់ព្រះបន្ទូលនេះនឹងត្រូវស្លាប់ ក៏គាត់មិនអាចបោះបង់ជំនឿរបស់គាត់បានដែរ។ នៅមូលដ្ឋានគ្រឹះនៃទីក្រុងដែលត្រូវវិនាស ទីក្រុងផុមផេយមានផូសីល ដែលស្ត្រីម្នាក់បានស្លាប់ដែលមានសភាពដែលនាងបានប៉ះនឹងគ្រឿងអលង្ការដោយដៃរបស់នាង។ បើយើងមើលទៅ វាបង្ហាញការពិតថា ស្ត្រីនោះមិនចង់បាត់នូវគ្រឿងអលង្ការនោះនៅកន្លែងដែលមានបន្ទុះភ្នំភ្លើងផ្ទុះ ហើយបានក្លាយទៅជាសមុទ្រនៃភ្លើង។ មនុស្សព្យាយាមលះបង់ខ្លួនដើម្បីនឹងការពារគ្រឿងអលង្ការដែលតែងតែវិនាស។

ព្រះបន្ទូលរបស់ព្រះស្មោះត្រង់។ ទំនុកដំកើង12:6 មានបន្ទូលថា “ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះសុទ្ធស្អាតទាំងអស់ គឺដូចប្រាក់ដែលគេសាកក្នុងបាវធ្វើពីដី ហើយបាន

សំរងអស់៧ដងផង។” សុភាសិត 30:5, 6 មានបន្ទូលថា “គ្រប់ទាំងព្រះបន្ទូលនៃព្រះសុទ្ធតែបរិសុទ្ធ ទ្រង់ជាខែល ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់ ៦ កុំឱ្យបន្ថែមបញ្ចូលក្នុងព្រះបន្ទូលទ្រង់ឡើយ ក្រែងទ្រង់បន្ទោសដល់ឯង ហើយឃើញថា ឯងជាមនុស្សភូតភរ។” អេសាយ 40:8 មានបន្ទូលថា “ស្មៅក៏ស្វិតក្រៀម ហើយផ្កាធោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប។” ព្រះបន្ទូលរបស់ព្រះស្មោះត្រង់ ចំណុចតូចក៏ពិត។ ព្រះបន្ទូលដែលថា ផែនដីទាំងមូលត្រូវបានព្យួរនៅលើអាកាសនៅ យ៉ូប 26:7 ជាព្រះបន្ទូលដ៏អស្ចារ្យពិត។ ការពិតដូច្នេះមិនមាននៅក្នុងសាសនាណានោះទេ។ លិទ្ធិខុងជឺបានហៅថាផ្នែកមួយនៃសួនច្បាស្ថានសួគ៌ ដែលវាគិតថាផែនដីជារបស់ដែលមិនមានចលនា។ ហើយ បេតា ដែលជាគម្ពីររបស់ឥណ្ឌានិយាយខុសថា “ដីត្រូវបានបង្កើតដោយត្រីកោណ ដែលដំរីកាន់វា”។ តែគ្រប់ផ្នែកនៃបទគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះគឺពិត។ មិនត្រឹមតែប៉ុណ្ណោះ បើយើងមើលតាមប្រព័ន្ធដែលទាក់ទងគ្នាវិញ ខ្លឹមសារនៃព្រះបន្ទូលរបស់ព្រះជាការពិត ដែលព្រះទ្រង់បានលោះបាបរបស់មនុស្សមានបាប ការនេះត្រូវបានសម្រេចមុនពេលដែលព្រះអម្ចាស់ចាប់កំណើត ប្រហែល៤000ឆ្នាំមុន ដ្បិតព្រះទ្រង់បានបញ្ជូនព្រះគ្រីស្ទមកក្នុងការតាំងសញ្ញារបស់ទ្រង់ដោយស្មោះត្រង់ និងមកសម្រេចវាផង។ យើងអាចដឹងការពិតថាព្រះបន្ទូលរបស់ព្រះស្មោះត្រង់យ៉ាងណា។ ព្រះបន្ទូលដែលបានសន្យានឹងត្រូវបានសម្រេចប្រហែលប៉ុន្មានពាន់ឆ្នាំក្រោយមក ដោយគ្មានភ្លេចសោះ។ ការបង្រៀនរបស់បទគម្ពីរបង្ហាញការពិតថា ព្រះទ្រង់ធ្វើឱ្យមនុស្សមានបាបប្រែចិត្ត ត្រូវបានអត់ទោស និងត្រូវបានប្រោសលោះផង។ វាជាការពិតប្រាកដណាស់។ អំពើបាបជាធាតុនៃការឈឺចាប់។ តើមានអ្វីដែលមិនពិត ដែលព្រះទ្រង់បានដោះបញ្ហាបាបរបស់មនុស្ស ពីព្រោះទ្រង់ជាសេចក្តីស្រឡាញ់?

2) ហេតុផលដែលត្រូវប្រកាសព្រះបន្ទូលរបស់ព្រះ។ អ្នកប្រកាសបានទទួលភស្តុតាងពិតប្រាកដ។ ពីព្រោះគំនិតរបស់គេ និងជីវិតរបស់ពួកគេមិនត្រូវបានលាយឡំនឹងលោកិយ។ ពីទំនាក់ទំនងរវាងរ៉ូមដែលបៀតបៀនដល់សាសនាគ្រីស្ទ និងអ្នកជឿ លោកបណ្ឌិត ហ្គោដិន បាននិយាយដូចតទៅថា "អ្នកដែលកាន់កាប់អាណាចក្ររ៉ូមប្រៀបដូចជាអ្នកលុកលុយដែលចេញមកពីពិភពលោកមួយទៀត។ ពួកគេមិនបានបន្ធូរបន្ថយជាមួយនឹងលោកិយសោះ។ ពួកគេមិនបានយកចិត្តទុកដាក់នឹងជីវិតរបស់ពួកគេទេ តែពួកគេបានប្រយ័ត្ននឹងសតិរបស់ពួកគេវិញ។ ពួកគេមិនប្រយ័ត្ននឹងឈាមរបស់ពួកគេទេ តែបានធានាអះអាងនូវលោហិតរបស់ព្រះយេស៊ូវដែលបានយកជ័យជំនះវិញ។" ហេតុផលដែលទ្រាំទ្រឈើឆ្កាងដល់ទីបញ្ចប់ដោយមិនព្រមបន្ធូរបន្ថយជាមួយនឹងលោកិយនោះគឺ ដោយសារពួកគេដឹងថាដោយសារការរងទុក្ខរបស់ទ្រង់ និងការសុគតរបស់ទ្រង់ដែលពួកគេអាចទៅកាន់ស្ថានសួគ៌បាន។ លោក អ៊ីកណាធៀស ដែលត្រូវបានគេបៀតបៀន និងត្រូវបាននាំទៅកាន់ក្រុងរ៉ូមដើម្បីសម្លាប់ គាត់បាននិយាយថា "ពេលនេះខ្ញុំបានផ្តើមក្លាយជាសិស្សរបស់ព្រះយេស៊ូវហើយ"។ កាលដែលអ្នកបរិសុទ្ធស្លាប់ កូនស្រីរបស់គាត់និយាយថា "ចិត្តរបស់ម្តាយយើងបានសម្រាកនៅស្ថានសួគ៌អស់រយៈពេល 40 ឆ្នាំហើយ។" អ្នកជឿពិតទទួលស្គាល់ថា ការស្លាប់របស់គេជាជ័យជំនះរបស់គេវិញ។ អ្នកជឿប្រហែលពីសែននាក់ត្រូវបានកប់នៅផ្នូរនៅក្រុងរ៉ូមដែលជាកន្លែងដែលមនុស្សជាច្រើនត្រូវបានសម្លាប់។ តែគ្មានខ្លឹមសារដែលសោកសៅណានៅលើការសរសេរនៅលើផ្នូររបស់ពួកគេទេ។

**ការអធិប្បាយ 25 រីករាយនៅក្នុងការបៀតបៀន (ម៉ាថាយ 5:10-12)**

1. ហេតុផលដែលត្រូវសប្បាយចិត្ត

1) ពីព្រោះព្រះជាព្រះដែលប្រទានពរនូវសេចក្តីអំណរ នោះយើងនឹងរីករាយនៅក្នុងការបៀតបៀន។

ទំនុកដំកើង 4:7 មានបន្ទូលថា “ទ្រង់បានប្រោសឱ្យចិត្តទូលបង្គំមានសេចក្តីអំណរលើសជាងពួកទាំងនោះ ក្នុងកាលដែលស្រូវ និងទឹកទំពាំងបាយជូររបស់គេបានសំបូរផង”។

ទំនុកដំកើង 32:11 មានបន្ទូលថា “ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ ហើយរីករាយឡើង ក្នុងព្រះយេហូវ៉ាចុះ អស់អ្នកដែលមានចិត្តទៀតត្រង់អើយ ចូរនាំគ្នាស្រែកឡើងដោយអំណរចុះ។”

ទំនុកដំកើង 36:8 មានបន្ទូលថា “គេនឹងបានឆ្អែត ដោយរបស់ដ៏បរិបូរក្នុងដំណាក់ទ្រង់ហើយទ្រង់នឹងឱ្យគេផឹកពីទន្លេនៃសេចក្តីអំណររបស់ទ្រង់។”

ទំនុកដំកើង 43:4 មានបន្ទូលថា “នោះទូលបង្គំនឹងទៅឯអាសនានៃព្រះ គឺដល់ព្រះដ៏ជាសេចក្តីអំណរ និងជាសេចក្តីរីករាយរបស់ទូលបង្គំ ឱព្រះអង្គដ៏ជាព្រះនៃទូលបង្គំអើយ ទូលបង្គំនឹងសរសើរដល់ទ្រង់ដោយចាប់ស៊ុង។”

2) ដ្បិតសេចក្តីសង្គ្រោះ និងព្រះគុណដែលបានសម្រេចដោយព្រះគ្រីស្ទជាការដែលពេញដោយអំណរ នោះយើងក៏អាចរីករាយនឹងការបៀតបៀនដែរ។

យ៉ូហាន 16:22 “ឥឡូវនេះ អ្នករាល់គ្នាមានសេចក្តីព្រួយដូច្នោះមែន ប៉ុន្តែខ្ញុំនឹងឃើញអ្នករាល់គ្នាម្តងទៀត នោះអ្នករាល់គ្នានឹងមានចិត្តអរសប្បាយវិញ ក៏នឹងឥតមានអ្នកណាដកយកសេចក្តីអំណរនោះ ចេញពីអ្នករាល់គ្នាបានឡើយ។”

កិច្ចការ16:25, “លុះពេលប្រហែលជាកណ្តាលអធ្រាត្រ ប៉ុល និងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ ឯពួកអ្នកទោសក៏ស្តាប់ដែរ។”

យ៉ូហាន16:33 “ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឱ្យអ្នករាល់គ្នា បានសេចក្តីសុខសាន្តដោយសារខ្ញុំ នៅលោកីយ៍នេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ។”

ព្រះអម្ចាស់មានបន្ទូលដូច្នោះ។ នាង ផានី ក្រសប៊ី បានក្លាយជាស្ត្រីម្នាក់ដែលងងឹតភ្នែកនៅសប្តាហ៍ទី៦បន្ទាប់ពីសម្រាល តែនាងជឿដល់ព្រះយេស៊ូវ ហើយមានអំណរជានិច្ច ហើយបានសរសេរទំនុកដំកើងជាង 6000 បទ។ នាងបានសរសេរចម្រៀងបន្ទាប់ពីនាងមានអាយុ 8 ឆ្នាំ។

“ព្រលឹងរបស់ខ្ញុំពិតជារីករាយខ្លាំងណាស់ បើទោះជាខ្ញុំមិនអាចមើលឃើញក៏ដោយ។ ខ្ញុំគិតថានៅក្នុងលោកិយនេះខ្ញុំនឹងបានស្កប់ស្កល់យ៉ាងណា។ តើមានព្រះពរដ៏សន្ធឹកយ៉ាងណាទៅដែលខ្ញុំរីករាយដែលមនុស្សជាច្រើនទៀតមិនមាននោះ។ ការយំនិងការដកដង្ហើមធំដោយសារតែខ្ញុំខ្វាក់ភ្នែកនោះ ខ្ញុំមិនអាចធ្វើបាបនទេ ហើយខ្ញុំក៏មិនធ្វើដែរ។”

លោក អហ្គើស្ទីន បាននិយាយថា “ព្រះអម្ចាស់អើយ ដ្បិតទ្រង់បានបង្កើតយើងមកសម្រាប់ទ្រង់ មុនពេលព្រលឹងរបស់យើងសម្រាប់នៅក្នុងទ្រង់ នោះយើងមិនអាចសម្រាកបានឡើយ។”

លោក សាំយ៉ូអែល រូហ្វត បានផ្ញើសំបុត្រចំនួន 220 រយៈពេលមួយឆ្នាំកន្លះនៅក្នុងគុកនៅក្នុងឃ្លាដំបូងនៃសំបុត្រសរសេរថា “ប្រសិនបើខ្ញុំមានក្រដាស់ធំដូចជាផែនដី និងមានទឹកជក់ដូចជាសមុទ្រ ហើយខ្ញុំសរសេរចុះពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ។” ហើយគាត់បានចង្អុលទៅគុក និងស្រែកវាថា “រាជវាំងរបស់ព្រះគ្រីស្ទ” ហើយ “ឈើឆ្កាងផ្អែម ចែងចាំង វាបានចាំងមក ហើយផ្តល់ការកំសាន្តចិត្តផង។” ហើយគាត់និយាយម្តងទៀតថា “បងប្អូនជាទីស្រឡាញ់អើយ ខ្ញុំសរសើរដល់ការដែលពេលដោយសិរីរុងរឿងរបស់ទ្រង់ ភាពស្មោះត្រង់របស់ខ្ញុំជាផលប្រយោជន៍របស់ខ្ញុំ គុករបស់ខ្ញុំជារាជវាំងរបស់ស្តេច ទុក្ខសោយសោករបស់ខ្ញុំជាអំណររបស់ខ្ញុំ។ ខ្ញុំដើរកាត់សូម្បីតែឋាននរក ហើយបាននៅក្បែរហ្វូងអារក្សជាច្រើនដើម្បីនឹងបានចូលរួមពិធីរបស់ព្រះគ្រីស្ទ។”

2. ហេតុផលដែលត្រូវពេញចិត្ត

ព្រះគម្ពីរមានបន្ទូលថា “អំណរដ៏អស្ចារ្យ” (កិច្ចការ 8:8) ហើយអំណរពេញលេញ (ទំនុកដំកើង 16:11) អំណរដែលរកថ្លែងពុំបាន “ ( ១ពេត្រុស 1:8), អំណរនៅអស់កល្ប “ (អេសាយ 35:10)។ អំណរដូច្នេះមិនត្រឹមតែរីករាយនៅក្នុងវីរៈបុរស និងមនុស្សអស្ចារ្យទេ គឺអស់អ្នកណាដែលជឿដល់ព្រះគ្រីស្ទដោយស្មោះត្រង់ក៏នឹងអាចរីករាយបានដែរ។

1) អ្នកដែលមិនរីករាយនឹងអំណរនេះគឺជាអំពើបាប។ ដូច្នេះ សាំយ៉ូអែល រូហ្វដ ដែលបានទទួលយកការពិតនេះដោយអំណរបាននិយាយថា "អំពើបាប ជាដុំនៃបាប ដែលធ្វើឱ្យអំណរទៅជាល្វីង និងប្តូរវាទៅជាថ្នាំពុលវិញ។" ហើយគាត់បានយំ។

2) ប្រសិនបើយើងបានស្លាប់នៅក្នុងព្រះគ្រីស្ទ យើងមិនអាចរីករាយនឹងសេចក្តីអំណរបានទេ។ ដូចជាមនុស្សមិនអាចដោះស្រាយបញ្ហានៃការស្លាប់បាន នោះគាត់នឹងនៅតែបារម្ភអំពីវាជានិច្ច។ បន្ទាប់ពីបានដោះស្រាយរួចមក នោះយើងនឹងមានអំណរ។ ដំណោះស្រាយដែលត្រឹមត្រូវទៅកាន់សេចក្តីស្លាប់ជាការសម្រេចចិត្តសេចក្តីស្លាប់នៅក្នុងព្រះគ្រីស្ទ។ ពីព្រោះត្រូវរងគ្រោះដោយសេចក្តីស្លាប់ដោយឥតការគ្រប់ពេល និងគ្រប់ទីកន្លែង។ អាស្ការុស ដែលជាវិចិត្រករបុរាណរបស់ក្រិក បានស្លាប់ដោយត្រូវបានវាយដោយសំបកអយស្ទ័រដែលធ្វើឱ្យឥន្ទ្រីធ្លាក់មក។ ការស្លាប់ដែលងាយនោះគឺជាការស្លាប់នៅក្នុងព្រះគ្រីស្ទ នោះគាត់នឹងទទួលបានជីវិតអស់កល្បជានិច្ច ហើយក៏ទទួលបានអំណរផងដែរ។

5:21-26)

## ការអធិប្បាយ 26 សេចក្តីស្អប់ដែលបង្ហាញមកដោយបណ្តាសាអាក្រក់ (ម៉ាថាយ 5:21-26)

“អ្នករាល់គ្នាបានឮសេចក្ដីដែលសំដែងដល់មនុស្សពីបុរាណ ថា«កុំឱ្យសំឡាប់មនុស្ស ឱ្យសោះ» បើអ្នកណាសំឡាប់មនុស្ស នោះត្រែងត្រូវជាប់ជំនុំជំរះហើយ។ តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នេះវិញ ថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន នោះត្រែងត្រូវជាប់ជំនុំជំរះដែរ ហើយអ្នកណា ដែលស្ដីឱ្យបងប្អូនថា «អាចោលម្សៀត» នោះត្រែងពួកក្រុមជំនុំធ្វើទោស តែចំណែកអ្នកណាដែលថា «អាឆ្កួត» នោះត្រែងធ្លាក់ទៅក្នុងភ្លើងនរក” នៅទីនេះ តើពាក្យ “បងប្អូន” នេះចង្អុលទៅកាន់អ្នកណា? ជាទូទៅ វាមិនចង្អុលទៅកាន់អ្នកផ្សេងទេ តែមានន័យថាជាគ្រីស្ទាន។ ពាក្យនេះមានន័យថា ការស្អប់ដែលទៅចំអកដល់បងប្អូន និងជេរប្រទេច នោះក៏ប្រៀបដូចជាអំពើបាបនៃការសម្លាប់គេដែរ។ វាពិបាកនឹងធ្វើការល្អដោយអំណាចរបស់មនុស្សណាស់ ( ពីព្រោះធ្វើដោយការអនុវត្ត) តែវាស្រួលក្នុងការធ្វើការអាក្រក់ដោយបបូរមាត់ និងអាចធ្វើអាក្រក់យ៉ាងខ្លាំងផង។ កាលដែលយើងឡូកឡឺយឱ្យអ្នកដទៃ និងជេរគេ តើគេនឹងត្រូវឈឺនៅក្នុងចិត្តប៉ុណ្ណាទៅ! តើវាមិនដូចជាបានចាក់មួយលំពែងទៅក្នុងចិត្តរបស់គេមែនទេ? ប្រសិនបើយើងធ្វើការរិះគន់អ្នកដទៃនៅទីលាក់កំបាំង តើវានឹងប៉ះពាល់អ្វីដែលគេទៅ? លោកបណ្ឌិត វ៉ាន ឌីកេ បាននិយាយថា មនុស្សដែលរិះគន់អ្នកដទៃ និងចំអកគេគឺប្រៀបដូចជាមនុស្សស៊ីសាច់មនុស្សអីចឹង។ អ្នកដែលរិះគន់អ្នកដទៃប្រៀបដូចជាសម្លាប់គេដោយធ្វើបាបដោយវិធីនេះ ឬវិធីនោះ។

1. ការស្អប់ជាឃាតករ

១យ៉ូហាន 3:15 មានបន្ទូលថា “អ្នកណាដែលមានចិត្តស្អប់ដល់បងប្អូន នោះឈ្មោះថាជាអ្នកសំឡាប់គេ ហើយអ្នករាល់គ្នាដឹងហើយ ថាគ្មានអ្នកណាសំឡាប់គេណាមួយ

ដែលមានជីវិតដ៏រស់អស់កល្បជានិច្ចនៅក្នុងខ្លួនឡើយ។” ពីព្រោះការធ្វើឃាតទាំងអស់ចាប់ផ្តើមពីការស្អប់ ការស្អប់ជាគ្រាប់ពូជនៃការសម្លាប់។ ការស្អប់ពិតណាស់ជាចិត្តដែលចង់ឱ្យអ្នកដទៃបាត់ទៅ គឺជាការសម្លាប់គេដោយចិត្ត។

2. ទំនាក់ទំនងរវាងការស្អប់បងប្អូន និងការថ្វាយបង្គំ

១យ៉ូហាន 4:20 មានបន្ទូលថា “បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក ដ្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូន ដែលបានមើលឃើញទៅហើយ នោះធ្វើដូចម្តេចឡើយ ឱ្យស្រឡាញ់ដល់ព្រះ ដែលមើលមិនឃើញទៅបាន។” យើងមិនអាចនិយាយបានថា ចិត្តរបស់ម្នាក់ដែលស្អប់បងប្អូនខ្លួន (យ៉ាងហោចណាស់ដោយស្អប់) មានសេចក្តីស្រឡាញ់ទៅកាន់ព្រះនោះទេ។ ពីព្រោះការស្រឡាញ់ព្រះត្រូវបានជំរុញដោយសេចក្តីស្រឡាញ់របស់ព្រះយ៉ាងបង្ខំ។ (២កូរិនថូស 5:14) សេចក្តីស្រឡាញ់របស់ព្រះមិនមែនផ្សេងទៀតទេ តែការរស់នៅក្នុងសេចក្តីស្រឡាញ់នៃលោហិតដ៏មានតម្លៃរបស់ទ្រង់។ មានតែគ្រីស្ទានដែលរស់នៅដោយលោហិតយ៉ាងមានតម្លៃរបស់ព្រះគ្រីស្ទដែលអាចស្រឡាញ់ដល់បងប្អូនពិតប្រាកដបាន។ អ្នកណាដែលមិនរស់នៅដូច្នោះ នោះនឹងមានឱកាសនឹងឈ្លោះប្រកែកជាមួយបងប្អូន និងមានឱកាសនឹងស្អប់បងគេ។ បើទោះជាគាត់អះអាងខ្លួនថាជាគ្រីស្ទានក៏ដោយ ប្រសិនបើគាត់មិនពឹងលើព្រះលោហិតដ៏មានតម្លៃ និងបន្ថែមផ្សេងទៀត នោះគាត់នឹងមានបញ្ហាដែលបន្ថែមផ្សេងទៀត នោះគាត់នឹងស្អប់បងប្អូន។ គ្រីស្ទានខ្លះមានការខ្វល់ខ្វាយខ្លាំងទៅនឹងបញ្ហានៃច្បាប់ជាលោហិតដ៏មានតម្លៃរបស់ព្រះគ្រីស្ទ ហើយបន្ថែមបញ្ហាផ្សេងទៀតផង។ ពួកគេមិនស្រឡាញ់បងប្អូន តែស្អប់វិញ ផ្តាច់ចេញពីគេ និងចាកចេញពីគេដោយសារបានជួបនឹងបញ្ហាមួយចំនួន។

**ការអធិប្បាយ 27 ភ្លើងឋាននរក (ម៉ាថាយ 5:22)**

1. ពាក្យថា “នរក” មានន័យថា ហ្គេ ហីននុម ( ) ជាភាសាហេព្រើ ជាជ្រោះហីននុម។

វាមានទីតាំងនៅភាពខាងកើត និងភាខាងត្បូងនៃយេរូសាឡិម។ (យ៉ូស្វេ 15:8, 18:16) ដ្បិតវាកន្លែងដែលគួរស្អប់ខ្ពើម (២ពង្សាវតារក្សត្រ 16:3, 21:6 ២របាក្សត្រ 28:3,33:6 យេរេមា 32:34, 35) , យ៉ូសេបានបំផ្លាញវា ហើយសង្ឃបានហៅវាថាជាកន្លែងដែលមិនស្អាត។ (២ពង្សាវតារក្សត្រ 23:10) យេរេមាបានទាយពីកន្លែងនេះថាជាកន្លែងនឹងក្លាយទៅជាជ្រោះនៃការសម្លាប់។ (យេរេមា 7:32, 19:6) ហើយសៀវភៅរបស់អេណុកបាននិយាយថា វានឹងក្លាយជាកន្លែងដែលទទួលការកាត់ទោសដល់មនុស្សទាំងអស់។ បន្ទាប់ពីនោះមកជ្រោះហីននុមត្រូវបានចាត់ទុកថាជាកន្លែងដែលមនុស្សទុច្ចរិតនឹងត្រូវទទួលការដាក់ទោសបន្ទាប់ពីស្លាប់។
យើងមិនត្រូវការសង្ស័យពីឋាននរកដែលនឹងមកទេ ពីព្រោះឈ្មោះរបស់ឋាននរកមានទាក់ទងនឹងឈ្មោះកន្លែងដែលនៅផែនដីនេះហើយ។ ពីព្រោះឈ្មោះនៃផែនដីដែលនឹងមកដល់អាចគិតដោយទស្សនៈនៃផែនដីនេះបាន។ មនុស្សនៅក្នុងលោកិយនេះគ្មានអ្នកក្រៅពីនោះឡើយ។ ដូច្នេះ កាលដែលយើងនិយាយពីលោកិយដែលនឹងមកដល់យើងអាចនិយាយបានដោយទស្សនៈនៃលោកិយនេះ។ ដូច្នេះគំនិតនៃចំណុចនេះ មិនបានទៅជាខ្សោយដោយសារឈ្មោះទេ។ ប្រសិនបើគំនិតរាប់បញ្ចូលបញ្ហាអាចកាត់បន្ថយបានដោយសារលក្ខណៈនៃឈ្មោះ នោះយើងមិនគួរនិយាយពីរឿងខាង

លោកិយដូចជាលោកិយដែលនឹងមកដល់នោះទេ។ យើងអាចនឹងមិននិយាយពីព្រះ។ នៅពេលយើងសង្កេតមើលពាក្យដើមនៃពាក្យ "ព្រះ" ព្រះនាមរបស់ព្រះ មិនមែនជាពាក្យដែលសមស្របទេ តែវាត្រូវបានប្រើដោយអ្នកកាន់សាសនានានាជាច្រើន។ មិនត្រឹមតែប៉ុណ្ណោះ ការបកប្រែរបស់យើង ហេ្គ ហ៊ីននុម ក៏មិនសមស្របដែរ។ ពាក្យថា ឋាននរក ជាគុកនៅផែនដី។ តើព្រលឹងដែលចាកចេញទៅមិននៅក្នុងគុកដែលធ្វើដោយដីទេ? ហើយតើអារក្ស និងពួកទេវតានៅក្នុងគុកមែនទេ? ដូច្នេះ យើងមិនត្រូវការកាត់បន្ថយគំនិតពីលោកិយដែលនឹងមកដល់ដែលលោកិយនេះចង្អុលទៅកាន់នោះទេ ពីព្រោះពាក្យដើមរបស់យើងពីឋាននរក "ជ្រោះហីននុម" មានទីតាំងនៅភាគត្បូងឆៀងខាងកើត។ បើទោះជាទ្រឹស្តីទាស់នឹងរូបរាងនៃឋាននរកក៏ដោយ ក៏មានការមួយចំនួនដែលត្រូវបានបង្ហាញមក ដែលពួកគេមិនអាចបង្កើតបានឡើយ។ រឿងមួយនៅក្នុងចំណោមនោះថា គោលលិទ្ធិនៃការដាក់ទោសនៃឋាននរកជាការបង្រៀនខុស ពីព្រោះវាវាយប្រហារដល់សេចក្តីស្រឡាញ់របស់ព្រះ និងធ្វើឱ្យព្រះទៅជាអ្នកគៀបសង្កត់។ ប៉ុន្តែដូចជាព្រះយេស៊ូវ គ្មានអ្វីដែលមានភាពជាមនុស្ស ហើយទ្រង់មានបន្ទូលពីឋាននរក។ មិនតែប៉ុណ្ណោះ ព្រះទ្រង់នឹងដាក់ទោសអំពើបាប ពីព្រោះទ្រង់មានសេចក្តីស្រឡាញ់ព្រមទាំងសេចក្តីសុចរិតផង។

2. អត្ថន័យនៃភ្លើង

ភ្លើងជានិមិត្តសញ្ញានៃសេចក្តីក្រោធរបស់ព្រះ។ (ចោទិយកថា 4:24, 9:3, អេសាយ 33:14)។ ឋាននរកជាគុកសម្រាប់ពួកអារក្ស និងពួកទេវតា។ (ម៉ាថាយ 25:41) មានសេចក្តីក្រោធដ៏ខ្លាំងរបស់ព្រះ។ (១ថែស្សាឡូនិក 1:10, ហេព្រើ 10:31)។

រួចមក នៅពេលយើងគិតពីឋាននរក យើងទទួលស្គាល់ការពិតមួយចំនួនដូចជាភ្លើង ភាពងងឹតសូន្យសុង (ម៉ាថាយ 8:12) ដង្កូវដែលមិនចេះស្លាប់ (ម៉ាកុស 9:48) និងការឈឺចាប់ដែលនៅអស់កល្ប (ម៉ាថាយ 25:46) ហើយយើងភ្លាចវា។ តែលើសពីនោះ យើងគួរចងចាំពីសេចក្តីក្រោធរបស់ព្រះដែលជាធាតុសំខាន់នៃការភ័យខ្លាច និងការឈឺចាប់ទាំងនោះ។ មនុស្សនៅក្នុងលោកិយទាំងអស់មានបទពិសោធន៍ពីកន្លែងនៃសេចក្តីក្រោធរបស់ព្រះ គ្រប់ទាំងបរិស្ថានត្រូវបានបង្ហាញដោយការព្រួយបារម្ភ និងការមិនសប្បាយចិត្ត។

ជាពិសេសវាមានបទពិសោធន៍នៅក្នុងពួកបរិសុទ្ធនៅក្នុងលោកិយនេះ។ ដូចនោះដែរ ការពិតដែលធាតុសំខាន់នៃមនុស្សមានបាបជាសេចក្តីក្រោធរបស់ព្រះនឹងដូចគ្នានៅក្នុងលោកិយដែលនឹងមកដល់។ ដូច្នេះ វិវរណៈ 6:15-17 មានបន្ទូលថា ពីព្រោះមនុស្សមានបាបដែលជួបនឹងសេចក្តីក្រោធរបស់ព្រះមិនអាចទទួលវាបាន គេបានសូមឱ្យថ្មបានធ្លាក់មកលើគេវិញ។

3. អំពើបាបដែលចូលទៅក្នុងឋាននរក

តើអំពើបាបអ្វីដែលត្រូវធ្លាក់ទៅក្នុងឋាននរកតាមដែលព្រះយេស៊ូវមានបន្ទូលនោះ? ដូចជា ម៉ាថាយ 5:22 មានបន្ទូលថា វាជាអំពើបាបដែលត្រូវធ្លាក់ទៅឋាននរក បើទោះវាជាអំពើបាបតូចក៏ដោយ។ អត្ថបទនៅខ 22 មានបន្ទូលថា “តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នេះវិញ ថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន នោះក្រែងត្រូវជាប់ជំនុំជំរះដែរ ហើយអ្នកណា ដែលស្តីឱ្យបងប្អូនថា «អាចោលម្សៀត» នោះក្រែងពួកក្រុមជំនុំធ្វើទោស តែចំណែកអ្នកណាដែលថា «អាឆ្កួត» នោះក្រែងធ្លាក់ទៅក្នុងភ្លើងនរក។”

ពាក្យនៅទីនេះ អំពើបាបពីរដំបូង ការទទួលការកាត់ទោស (ការកាត់ទោសស្រុក) និង ការចាប់នៅក្នុងការជំនុំជំរះ (ការទទួលនូវការកាត់ទោសដ៏ខ្ពស់នៅយូដា) មិនមានន័យ ថា ចៅក្រមនៅក្នុងលោកិយគួរតែគ្រប់គ្រងនោះទេ។ វាមានន័យថា ព្រះទ្រង់ចាត់ទុក ការស្អប់របស់យើងជាអំពើបាបដែលត្រូវទទួលទោស។ (D. Schlatter, Jesus will uns sagen, was Gott von unserm Hassen denkt. – Erlauterungen Zum neuen Testament, 1, p 48)

ការពិតដែលព្រះអម្ចាស់មានបន្ទូលបីអំពើបាបបី (ការខឹង ពាក្យ រ៉ាខា និងមនុស្សឆ្កួត) ហាក់ដូចជាមិនបង្ហាញកម្រិតបីនៃអំពើបាបទេ។ តែការបីនេះជាអំពើបាបនៃការស្អប់ ដែលចង្អុលទៅកាន់អំពើបាបដែលតូចដូចគ្នា ដែលស្ថិតនៅក្នុងអំពើបាបនៃការសម្លាប់ ហើយវាមានន័យថា បើទោះជាវាតូចក៏ដោយ គេនឹងទទួលនូវការដាក់ទោសស្មើគ្នានឹង ការសម្លាប់គេដែរ។ អត្ថបទមិនបានបង្រៀនថា អំពើបាបពីដំបូងមិនត្រូវទទួលការដាក់ ទោសនៅឋាននរកទេ ពួកគេក៏រាប់បញ្ចូលដែរ ហើយក៏នឹងត្រូវទទួលការដាក់ទោស ដោយនរកដូចជាអំពើបាបទីបីដែរ។ និយាយម្យ៉ាងទៀត អត្ថបទនេះបង្ហាញថា អំពើ បាបតូចដូច្នោះក៏នឹងត្រូវទទួលការដាក់ទោសដោយភ្លើងនៃឋាននរកដែរ។ (H. N Ridderbos, Korte Verklaring Der Schrift, Mattheus, p 109)

នៅទីនេះព្រះបន្ទូលដែលព្រះយេស៊ូវបង្រៀន អត្ថបទរាប់បញ្ចូលគំនិតថា កាលដែល មនុស្សធ្វើបាបតូច គេគួរទទួលការដាក់ទោសនៃឋាននរក។ អំពីគំនិតបែបនោះ មនុស្សមិនជឿលើការដាក់ទោសនៃឋាននរកដែលអះអាងដោយទ្រឹស្តីខុសនោះទេ។ គឺ ថា "ការដាក់ទោសនៅឋាននរកនឹងជួបនឹងសេចក្តីសុចរិតរបស់ព្រះ។ ពួកគេអះអាង

ថា វាមិនត្រឹមត្រូវទេដែលមនុស្សត្រូវទម្លាក់ទៅក្នុងឋាននរកអស់កល្បជានិច្ច ដោយសារអំពើបាបតូចដែលបានធ្វើនៅក្នុងលោកិយបណ្តោះអាសន្ននេះ។

1) ដូចជាលោក ហឺម៉ាន់ បាវីង និយាយថា "កាលដែលយើងឃើញប្រភពនៃអំពើបាប គឺអំពើបាបជាការទទឹងច្បាប់ វាផ្ទុយនឹងព្រះ ហើយបដិសេធនូវសិទ្ធិរបស់ទ្រង់ សិទ្ធិអំណាចរបស់ទ្រង់ និងវត្តមានរបស់ទ្រង់ផង។ ដោយសារអំពើបាប មនុស្សដែលមានដែនកំណត់និងមានពេលកំណត់ ខ្លួនគេមានដែនកំណត់។ តែអំពើបាប ដូចជា លោកអហ្គីស្ទីន និយាយយ៉ាងត្រឹមត្រូវថា មិនបង្កើតស្តង់ដារនៃការដាក់ទោសដោយពេលវែងឬខ្លីដែលធ្វើវាទេ តែគួរតែទទួលស្គាល់ស្តង់ដាដែលនៅខាងក្នុងវិញ។ មនុស្សស្រែកឡើងប៉ុន្មានឆ្នាំដោយការមិនយកចិត្តទុកដាក់មួយភ្លែត។ មួយរំពេចអំពើបាបអាចទទួលនូវសេចក្តីអាម៉ាសនិងកាដាក់ទោសពេញមួយជីវិត។ ដោយសារការបរាជ័យមួយ គេអាចនឹងត្រូវស្លុយ ហើយដោយការគ្រប់គ្រងនៅក្នុងលោកិយនេះ គេអាចនឹងត្រូវបញ្ជូនទៅកាន់សភាពមួយដែលមិនអាចស្តារបាន។ ព្រះទ្រង់ក៏ធ្វើដូច្នេះដែរ។.... ទ្រង់ដាក់ទោសដោយលក្ខណៈខាងក្នុងនៃអំពើបាបហេតុផលដែលអំពើបាបមិនគួរនឹងបញ្ចប់នូវដោយការដាក់ទោស ទទួលថាវាជាការបះបោរទាស់នឹងចេស្តានៃព្រះជាម្ចាស់ដែលមានគ្រប់ចេស្តា ដែលទ្រង់គួរត្រូវទទួលដោយសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់របស់យើង និងការថ្វាយបង្គំជារៀងរហូតដោយមិនឈប់ឈរ។ ក្រឹត្យវិន័យដែលទាមទារនូវការស្តាប់បង្គាប់របស់យើងគ្រប់គ្រងលើវាទាំងស្រុង។ ដូច្នេះ គ្រឹះនៃច្បាប់មកកាន់យើងគឺអស្ចារ្យជានិច្ច។ ដូច្នេះ កាលដែលយើងសង្កេតមើលបាបដែលប្រព្រឹត្តនៅខាងក្នុង វាពិតជាអាក្រក់ណាស់ ដែលយើងសមនឹងទទួលការដាក់ទោសដោយគ្មានឈប់។" (Geref. Dogmatiek IV p 793) យ៉ាកុប 2:10, 11 មានបន្ទូល

“បិតអ្នកណាដែលកាន់ក្រឹត្យវិន័យទាំងមូលតែភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រឡប់ជាមានទោសចំពោះក្រឹត្យវិន័យទាំងមូលនោះហើយ ១១ ពីព្រោះព្រះដែលមានព្រះបន្ទូលថា «កុំឱ្យផិតគ្នាឱ្យសោះ» ទ្រង់ក៏មានព្រះបន្ទូលថា «កុំឱ្យសំឡាប់មនុស្ស» ដែរ ដូច្នេះ បើអ្នកមិនបានប្រព្រឹត្តសេចក្ដីកំផិតទេ តែបានសំឡាប់វិញ នោះឈ្មោះថាអ្នកបានប្រព្រឹត្តអំពើរំលងក្រឹត្យវិន័យហើយ។” ដូច្នេះក្រិត្យវិន័យរបស់សាសនាគ្រឹះត្រូវបានផ្ដាច់ចេញពីគ្នា តែវាជាប្រព័ន្ធដែលទាក់ទងខាងវិញ្ញាណដែលគួរតែចាត់ទុកជារូបកាយតែមួយ។ វាជាបំណងរបស់ព្រះដែលមានព្រះជន្មរស់តែមួយអង្គគត់។ ដូច្នេះ បើគេធ្វើបាបនៅផ្នែកណាមួយ នោះវាជាការធ្វើបាបទាស់នឹងលក្ខណៈរបស់ព្រះហើយ ហើយអាចនិយាយបានថាគេបានធ្វើខុសនឹងបញ្ញាត្តិទាំងអស់ ពីព្រោះវាជាអំពើបាបបះបោរនឹងលក្ខណៈរបស់ព្រះ។ អ័ដាម ត្រូវទទួលបណ្ដាសាដោយសារធ្វើខុសនឹងបញ្ញាត្តិមួយ ដោយគាត់បានបរិភោគនូវផ្លែឈើដែលបានហាមប្រាម។

2) ហេតុផលមួយដែលត្រូវធ្លាក់ទៅក្នុងឋាននរក បើទោះជាគាត់ធ្វើបាប ជាអ្នកទោសផ្ទាល់ជាមនុស្សមានបាបដែលបានធ្វើបាប។ ការពិតដែលគាត់ធ្វើបាបនោះដោយសារគាត់ផ្ទាល់ជាប្រភពនៃអំពើបាប។ បើទោះជាបាបហាក់ដូចជាតូចតាច និងជាល្បែងមួយ គាត់មានប្រភពនៃអំពើបាបដ៏អាក្រក់ដូចជាពស់នៅក្នុងគាត់។ អ្នកដែលចាត់ទុកថាអំពើបាបតូចតាច គឺដូចជាម្នាក់ដែលបង្ខឹកសត្វព្រៃ និងបង្ហាញវា។ មានបុរសម្នាក់បានបង្ហាត់សត្វពស់ដ៏ធំមួយដែលមានប្រវែង 25 ហ្វីត ហើយបង្ហាញវា។ កាលដែលគាត់អោនដើម្បីនឹងផ្លុះ ពស់បានចេញមកហើយបានរុំជុំវិញខ្លួនគាត់ ហើយបានព្រលែងវាវិញ រួចមកគាត់ធ្វើដដែលទៀត ពល់បានរុំព័ទ្ធជុំវិញខ្លួនគាត់ តែមិនបានព្រលែងទេ ហើយជាចុងក្រោយគាត់បានស្លាប់ដោយសារការការរុះរឹតរបស់វា។ ប្រភព

នៃការអាក្រក់ដែលអំពើបាបតូចដែលត្រូវបានមើលរំលង ជាចុងក្រោយនឹងត្រូវបាន បំផ្លាញមនុស្សមានបាបដែលរាប់បញ្ចូលនៅក្នុងខ្លួនគេផ្ទាល់។

**ការអធិប្បាយ 28 អាសនា និងសេចក្ដីសុខសាន្ត (ម៉ាថាយ 5:23-26)**

អាសនានៅក្នុងគម្ពីរសញ្ញាចាស់បានទាមទារការបាចអំបិលដើម្បីនឹងបង្កើតសេចក្ដីសុខសាន្ត។ លេវីវិន័យ 2:13 មានបន្ទូលថា "ហើយអស់ទាំងដង្វាយម្សៅដែលឯងថ្វាយ នោះត្រូវបង់អំបិលផង ក៏មិនត្រូវឱ្យខាននឹងដាក់អំបិលនៃសេចក្ដីសញ្ញារបស់ព្រះនៃឯង ក្នុងដង្វាយម្សៅឡើយ ត្រូវតែបង់អំបិលចុះក្នុងគ្រប់ទាំងដង្វាយរបស់ឯង។" តើអ្វីជាការប្រៀបធៀបពីអំបិលនោះ? វាមានន័យថាការតាំងសញ្ញា និងសេចក្ដីសុខសាន្ត។ ដង្វាយដែលមនុស្សថ្វាយដល់ព្រះមិនមែនផ្ទាល់ខ្លួនទេ តែសម្រាប់ផលប្រយោជន៍សាធារណៈនៃរាស្ត្ររបស់ព្រះ។ ការថ្វាយដង្វាយនៅលើអាសនា និងទំនាក់ទំនងជិតស្និតនៃបងប្អូនគឺគិតពីការតាំងសញ្ញា ដែលជាចុងក្រោយអ្នកជឿមិនត្រូវបានទុកចោលពីសហគមន៍នៃរាស្ត្ររបស់ព្រះទេ។ វាប្រៀបដូចជាការពិតដែល ប៉ុលមិនទទួលស្គាល់អ្នកជឿទុកជាវត្តមានផ្ទាល់ខ្លួននៅក្នុងក្រុមជំនុំរបស់គាត់ទេ តែគាត់បានទទួលស្គាល់អ្នកដែលមានទំនាក់ទំនងនឹងរូបកាយ (សហគមន៍)។ នៅក្នុងការបម្រើព្រះ ហេតុផល

ដែលគាត់មិនគួរដកខ្លួនទៅតែឯងគឺ ដោយសារពួកគេត្រូវបានរាប់បញ្ចូលនៅក្នុងគោលការណ៍ដែលរើសពួកគេ និងតាំងឡើង។ ពីព្រោះអ្នកជឿជារាស្ត្ររបស់ព្រះ ពួកគេគួរធ្វើដោយគិតពីពួកគេជានិច្ច។ គាត់គួរតែធ្វើចលនា និងឈប់ជាមួយនឹងពួកគេ។ កាលដែលគាត់ត្រូវបានរើសតាំងរួចហើយជារាស្ត្ររបស់ទ្រង់។ លោក អេជ អ៊ែន រី ដែលបុស បានចង្អុលទៅកាន់ការពិតយ៉ាងល្អថា “នគរបច្ចុប្បន្នរបស់ព្រះគឺសម្រាប់មនុស្សរបស់ព្រះតាំងពីយូរមកហើយ ....នៅទីនេះការរើសតាំងមិនមែនជាធាតុផ្ទាល់ខ្លួននៃរាស្ត្ររបស់ព្រះទេ។”( De gave van het koninkrijk is voor her volk, dat God Zich van ouds verkoren heft…. Ook hier wordt de uitvekiezing dus niet individualistisch, maar ais de verkiezing dus niet individualistisch, maar als de verklezing van het volk Gods opgevat. –De Komst van Het Koninkrijk, Kampen, 1950, p. 185)

នៅកន្លែងនោះ សេចក្តីសុខសាន្តត្រូវបានបែក នោះគេមិនអាចថ្វាយដង្វាយទេ។ ការបំបែកសេចក្តីសុខសាន្ត មានន័យថា ទំនាក់ទំនងនៃការតាំងសញ្ញានៅក្នុងចំណោមរាស្ត្ររបស់ព្រះ។ ពីព្រោះដាវីដបានបង្ហូរឈាម ព្រះទ្រង់មិនបានអនុញ្ញាតឱ្យគាត់បានសង់ព្រះវិហារទេ។ (១របាក្សត្រ 22:8, ១ពង្សាវតារក្សត្រ 5:3) ១របាក្សត្រ 22:8 មានបន្ទូលថា “តែព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់អញថា ឯងបានកំចាយឈាមជាច្រើន ហើយបានច្បាំងចំបាំងយ៉ាងធំ មិនត្រូវឱ្យឯងស្អាងព្រះវិហារ សំរាប់ឈ្មោះអញទេ ពីព្រោះបានកំចាយឈាមជាច្រើន នៅលើផែនដី នៅចំពោះអញ។” ប៉ុន្តែ សាឡូម៉ូន បុត្ររបស់ដាវីដជាមនុស្សនៃសេចក្តីសុខសាន្តត្រូវបានប្រគល់នូវការសាងសង់ព្រះ

វិហារពីព្រះវិញ។ កាលដែលយើងមើលទៅ កាលដែលយើងមានទំនាក់ទំនងដោយស្អប់បងប្អូន នោះយើងមិនអាចថ្វាយដង្វាយដោយស្រឡាញ់ដល់ព្រះទេ។ ដូច្នេះ កាលដែលម្នាក់ចង់ថ្វាយដង្វាយ និងមកកាន់ព្រះ កាលដែលគាត់នឹងចាំពីការដែលគាត់នឹងស្តាប់ពីការរអ៊ូរទាំពីបងប្អូនគាត់ គាត់គួរតែទុកដង្វាយនៅអាសនា ហើយទៅកាន់គាត់នឹងបង្កើតឱ្យមានសេចក្តីសុខសាន្តជាមុនសិន។ ម៉ាថាយ 5:9 មានបន្ទូលថា "មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅជាកូនរបស់ព្រះ។" វាច្បាស់ណាស់ថាព្រះទ្រង់សព្វព្រះទ័យដែល អ្នកជឿលះបង់ខ្លួនដើម្បីនឹងបង្កើតសេចក្តីសុខសាន្ត។ នៅក្នុងក្រុមជំនុំចាស់ មុនពេលអ្នកជឿចូលរួមពិធីលៀងព្រះអម្ចាស់ ពួកគេស្វែងការអត់ទោសពីម្នាក់ទៀតសិន។ ដ្បិតនគររបស់ព្រះ ការគ្រប់គ្រងមនុស្សគឺតឹងរឹង អ្នកដែលស្តាប់ពីការរអ៊ូរទាំពីបងប្អូន ជាដំបូងត្រូវផ្សះផ្សាជាមួយគាត់សិន។ ព្រះទ្រង់ទទួលស្គាល់មនុស្សដូចៗគ្នា ទ្រង់មិនរើសអើងពួកគេទេ ហើយការគ្រប់គ្រងរបស់ទ្រង់នៅស្ថិតស្ថេរ។ កាលដែលប្រទេសបានប្រសើរឡើង សិទ្ធិអំណាចក៏រស់ឡើង ហើយប្រជារាស្រ្តក៏ត្រូវបានការពារ និងមានការថែរក្សាយ៉ាងល្អ។

**ការអធិប្បាយ 29 ការប្រែចិត្ត និងការថ្វាយដង្វាយ (ម៉ាថាយ 5:23-26)**

អ្វីជាការប្រែចិត្ត? វាចេញមកពី ២កូរិនថូស 7:11។ គឺថា “ដ្បិតមើល សេចក្តីនេះឯង គឺដែលអ្នករាល់គ្នាមានសេចក្តីព្រួយដ៏គាប់ដល់ព្រះហឫទ័យនៃព្រះ នោះបានបង្កើតឱ្យអ្នករាល់គ្នាមានសេចក្តីសង្វាត សេចក្តីដោះសា សេចក្តីគ្នាន់ក្នាញ់ សេចក្តីភ័យខ្លាច សេចក្តីនឹករឭក សេចក្តីឧស្សាហ៍ និងសេចក្តីសងសឹកជាខ្លាំងទាំងម្ល៉េះ អ្នករាល់គ្នាបានសំដែងយ៉ាងច្បាស់ថា ខ្លួនបរិសុទ្ធក្នុងដំណើរនេះគ្រប់ជំពូក។” គោលលិទ្ធិនៃការប្រែចិត្តចេញមកពីគោលលិទ្ធិរបស់យើងដែរ។ នៅក្នុងចំណោមនោះ យើងគួរចងចាំការមួយចំនួន។ វានិយាយថា “អំពើបាបដែលធ្វើទោសដល់មនុស្សគួរតែសារភាពទៅកាន់មនុស្ស ហើយអំពើបាបដែលធ្វើទោសដល់ក្រុមជំនុំគួរតែនិយាយទៅកាន់ក្រុមជំនុំ” ហើយក៏និយាយទៀតថា “ការប្រែចិត្តជាគោលលិទ្ធិនៃដំណឹងល្អ វាគួរប្រកសាដោយជំនឿ” “អំពើបាបមិនគួររំពឹងការអត់ទោសដោយគ្មានការប្រែចិត្តទេ។” (ការសារភាពសេចក្តីជំនឿវេសមីនស្ទើរ ជំពូក 15) យើងនៅក្នុងពេលបច្ចុប្បន្ននេះដោយសារអំពើបាបនៃក្រុមជំនុំរបស់យើង យើងគួរដឹងការទទួលការប្រៀនប្រដៅនៃការរងទុក្ខ។ នៅក្នុងក្រុមជំនុំសម័យកណ្តាលក៏បានទទួលការរងទុក្ខដោយសារអំពើបាបនៃអ្នកដឹកនាំក្រុមជំនុំ។ នៅសម័យមុននិងបន្ទាប់ពី ក្លេមិនទី៦ ក្រុមជំនុំពិតជាទុច្ចរិតណាស់ សម្តេចប៉ាប និងសង្ឃបានមានស្រី លក់ដំណែង និងកន្លែងខ្ពស់ដោយតម្លៃថ្លៃ។ ដោយសារឈ្នួលនៃអំពើបាប តើអឺរ៉ុបមិនបានទទួលនូវគ្រោះចង្រៃទេឬអី? នៅឆ្នាំ 1348-1349 ជំងឺខ្មៅបានរាតត្បាតនៅពេលអឺរ៉ុប មនុស្ស 80000 នាក់នៅសៀណា 10000 នាក់នៅបែនីស 2/3 នៅបាឡូណា 3/5 នៅហ្វ្លរ៉ែន ប្រជារាស្ត្រទាំងអស់ 57000នាក់នៅក្នុងមួយខែនៅម៉ាល់សេយូ និងពាក់កណ្តាលនៃប្រជាជន ( 2500000

នាក់) បានស្លាប់។ មានមនុស្សជាច្រើនស្លាប់ ហើយគ្មានមនុស្សដែលនៅធ្វើស្រែទេ។ គឺដូច្នោះដែលក្រុមជំនុំបានធ្វើបាប ការដាក់ទោសត្រូវបានបង្ហូរចុះមក។ អំពើបាបដែលពួកអ៊ីស្រាអែលត្រូវគេដាក់គុកគឺដោយសារមូលហេតុដូចគ្នា។ បរិទេវ 2:14 មានបន្ទូលថា “ពួកហោរារបស់នាងបានឃើញការជាក់ស្តែងក្លែងក្លាយ ហើយផ្តេសផ្តាស គេមិនបានបើកឱ្យឃើញសេចក្តីទុច្ចរិតរបស់នាង ប្រយោជន៍នឹងនាំពួកនាង ដែលនៅជាឈ្លើយឱ្យបានមកវិញទេ គឺគេបានឃើញតែសេចក្តីកំភូត និងសេចក្តីដែលបណ្តាលឱ្យត្រូវនិរទេសវិញប៉ុណ្ណោះ។” កាលដែលយើងលន់តួបាបរបស់យើង នោះយើងទទួលបានការឆ្លើយតបអធិស្ឋានរបស់យើង។ គ្រូធូរ៉េ បានអធិស្ឋានពីបញ្ហាលុយកាក់នៅពេលយប់។ តែគាត់មិនបានទទួលការឆ្លើយតបទេ។ ពេលគាត់លន់តួបាបដោយនឹកឃើញពីអំពើបាបផ្ទាល់ខ្លួនរបស់គាត់ទូទៅ នោះចិត្តរបស់គាត់បានស្វែងរកសេចក្តីសុខសាន្ត និងបានដេកលក់។ នៅថ្ងៃបន្ទាប់ពេលគាត់ក្រោកឡើង នោះលុយបានមករកគាត់។ ទំនុកដំកើង 66:18 មានបន្ទូលថា “បើសិនជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត

នោះព្រះអម្ចាស់ទ្រង់មិនព្រមស្តាប់ខ្ញុំទេ។” ដោយសារអំពើបាប នោះការទុក្ខលំបាកក៏មករកឃើញ ប្រសិនបើយើងមិនអាចប្រែចិត្តពីអំពើបាបរបស់យើងទេ តើទុក្ខវេទនានឹងចាក់ចេញពីយើងបានដូចម្តេច? ដូច្នេះ កាលដែលយើងដាក់អំពើបាបយើងនៅក្នុងចិត្តរបស់យើងដដែល ហើយអធិស្ឋានទៅព្រះ វាដូចជាការពិតដែលអ្នករត់ដែលរត់ដោយមានចិត្តនៃការបរាជ័យវិញ។